**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិនារីនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិត **ជី សិទ្ធិ**

សាស្ត្រាចារ្យណែនាំ
លោកគ្រូ **ជ័យ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២២**

ឆ្នាំសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ជី សិទ្ធិ** ជានិស្សិតបរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយប្រណិបត្តិ ដោយស្មោះត្រង់ និងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

– លោកឪពុក **ជី សាវ៉េត** និង អ្នកម្ដាយ **ពេន រ៉ុន** ដែលបានចិញ្ចឹមបីបាច់ថែរក្សាកូនបានយ៉ាងល្អ ប្រកបដោយព្រហ្មវិហារធម៌ លះបង់ទាំងកម្លាំងកាយចិត្ត ថវិកា និងពេលវេលាដោយឥតដែលរំពឹងប្រយោជន៍តបស្នង។ លោកទាំងពីរជាបុព្វការីជន ដែលបានបណ្ដុះបណ្ដាលកូនៗទាំងផ្នែកបញ្ញាស្មារតី ដោយបានជម្រុញឲ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ឧត្ដមសិក្សា និងអត្ដចរឹតតាមរយៈភាពជាគម្រូ។

– **ព្រះសង្ឃ ចៅធិការវត្តព្រៃបឹង វត្តថ្មី** និង **វត្តព្រែកជ្រៃ** ដែលលោកបានផ្ដល់កន្លែងស្នាក់នៅ អាហារ និងភាតរភាព នៅកំឡុងពេលបន្តការសិក្សាតាំងពីថ្នាក់ថ្នាក់វិទ្យាល័យ រហូតដល់ឧត្ដមសិក្សា។

– ស្ថិតក្នុងឱកាសនេះ ខ្ញុំបាទសូមអរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យទាំងអស់ដែលបម្រើការនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបំពេញមុខងារអស់ពីសមត្ថភាព ញ៉ាំងឲ្យខ្ញុំបាទមានសមត្ថភាពក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

– ស្ថិតក្នុងឱកាសនេះ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សាស្ត្រាចារ្យ **ជ័យ រិទ្ធី** ដែលបានណែនាំ ផ្ដល់អនុសាសន៍ លើកទឹកចិត្ត ព្រមទាំងលះបង់ពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំខ្ញុំបាទឲ្យបញ្ចប់សារណា ដោយអនុលោមតាមមាត្រដ្ឋាននៃសាកលវិទ្យាល័យ។

– ស្ថិតក្នុងឱកាសនេះ សូមអរគុណជាចំពោះ លោកគ្រូ អ្នកគ្រូទាំងឡាយដែលធ្លាប់បានបង្រៀនខ្ញុំបាទចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់ពេលនេះ។ វត្តមាននៃការចូលរួមរបស់លោកគ្រូ អ្នកគ្រូ បានបង្កើត និងបង្កើនធនធានមនុស្សច្រើនរាប់មិនអស់ ហើយក្នុងនោះក៏មានខ្ញុំបាទម្នាក់ដែរ។

– ស្ថិតក្នុងឱកាសនេះ សូមអរគុណចំពោះ តំណាងរបស់ **ក្រសួងកិច្ចការនារី អង្គការលីកាដូ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ** និង **NGO-CEDAW** ដែលបានផ្ដល់ឯកសារជាច្រើនសម្រួលដល់ការស្រាវជ្រាវនេះ។

ជាកិច្ចបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរបវរសិរីសួស្ដីជូនដល់ លោកឪពុក អ្នកម្ដាយ ព្រះសង្ឃ សាកលវិទ្យាធិការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្រុមគ្រួសារ មិត្តភក្តិ និងបុគ្គលទាំងឡាយដែលធ្លាប់បានពឹងពាក់កន្លងមក ឲ្យមានភ័ព្វសំណាង ជួបប្រទះសេចក្ដីសុខ ភាពចម្រុងចម្រើន និងសម្រេចតាមបំណងប្រាថ្នា។

# អារម្ភកថា

សួស្តីមិត្តអ្នកអាន អ្នកស្រាវជ្រាវជាទីមេត្រី ស្នាដៃដែលលោកអ្នកកំពុងអាននេះ គឺជាកម្រងនៃការស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការអាន ជាអន្តរការីមួយដ៏ចាំបាច់ និងមានសារៈសំខាន់ក្នុងការចាប់យកពុទ្ធិ ប៉ុន្តែបច្ចុប្បន្ន ការអានមិនបានក្លាយជាទីពេញនិយមរបស់ប្រជាជនកម្ពុជាទេ។

បច្ចុប្បន្ននេះ សកលលោកទាំងមូលក៏ដូចជាប្រទេសកម្ពុជា មានភាពអំណោយផលដល់ការស្រាវជ្រាវតាមរយៈលិខិតបទដ្ឋាននានា សៀវភៅ របាយការណ៍ ឯកសារ ឬក៏អាចស្វែងរកតាមរយៈគេហទំព័រផ្លូវការណាមួយជាខេមរភាសា ឬភាសាបរទេស។ ប៉ុន្តែទោះជាដូច្នេះក៏ដោយ ក្នុងការរៀបរៀងជាស្នាដៃមួយទាមទារនូវការយកចិត្តទុកដាក់ និងភាពអត់ធ្មត់ជាទីបំផុត។ សារណានេះ អាចលេចរូបរាងឡើងដោយផ្អែកលើបណ្តាឯកសារជាច្រើន ចំណេះដឹងពីការសិក្សាកន្លងមក និងដំបូន្មានពីសំណាក់សាស្ត្រាចារ្យណែនាំ។

កិច្ចការស្រាវជ្រាវនេះ ពុំមែនមានគោលដៅត្រឹមតែធានាការបញ្ចប់ឆ្នាំសិក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏មានបំណងចូលរួមវិភាគទានជាជំនួយដ៏ស្តួចស្តើងមួយដល់មិត្តអាន អ្នកស្រាវជ្រាវផងដែរ។

ខ្ញុំជឿជាក់ថា សារណានេះនៅមានភាពឆកល្វែង គឺតែងតែមានការផ្គាំផ្គួង និងកំហុសអចេតនាមួយចំនួនលើអក្ខរាវិរុទ្ធ និងផ្នែកណាមួយជាពុំខាន។

នៅចុងបញ្ចប់ ខ្ញុំបាទរីករាយត្រៀមខ្លួនទទួលស្វាគមន៍ជានិច្ចចំពោះការទិតៀនពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ ដោយមេត្រីភាព។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ........................................................ v

**សេចក្តីផ្តើម** ........................................................ ១

១. លំនាំនៃបញ្ហាស្រាវជ្រាវ ........................................................ ១

២. ចំណោទនៃបញ្ហាស្រាវជ្រាវ ........................................................ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........................................................ ១

៤. ទំហំនៃការស្រាវជ្រាវ ........................................................ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................................ ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................................ ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................ ២

**ជំពូកទី១**

**សិទ្ធិនារីអន្តរជាតិ**

**១.១. សញ្ញាណនៃសិទ្ធិនារី** ........................................................ ៤

**១.២. ប្រវត្តិ និងមូលហេតុនៃការទាមទារសិទ្ធិនារី** ........................................................ ៤

១.២.១. តេរេសា ម៉ាល់គៀល និង ក្លារ៉ា សេតគីន ........................................................ ៤

១.២.២. បដិវត្តន៍សង្គមនិយមរុស្ស៊ី ........................................................ ៥

១.២.៣. អង្គការសហប្រជាជាតិកំណត់ជាផ្លូវការ នៅឆ្នាំ១៩៧៥ ........................................................ ៦

**១.៣. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)ឆ្នាំ១៩៤៨** ........................................................ ៧

**១.៤. កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(OHCHR)ឆ្នាំ១៩៦៦** ........................................................ ៧

**១.៥. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ** ........................................................ ៩

**១.៦. សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន(AHRD)ឆ្នាំ២០១២** ........................................................ ៩

**ជំពូកទី២**

**សិទ្ធិនារីនៅប្រទេសកម្ពុជា**

**២.១. ស្ថានភាពក្នុងប្រវត្តិសាស្ត្រ** ........................................................ ១១

**២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣** ........................................................ ១១

**២.៣. សេដ្ឋកិច្ច** ........................................................ ១២

២.៣.១. ស្ត្រី និងអាជីវកម្ម ...................................................................................................................... ១២
២.៣.២. ស្ត្រីនៅក្នុងវិស័យកាត់ដេរ .............................................................................................................. ១៣
២.៣.២.១. កម្ចីប្រាក់ឥណទាន ............................................................................................................ ១៣
២.៣.២.២. កម្ចីប្រាក់ឯកជនក្រៅផ្លូវការណ៍............................................................................................១៥
**២.៤. ស្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ** ...............................................................................................១៦
២.៤.១. ស្ត្រីនៅក្នុងស្ថាប័នព្រឹទ្ធសភា............................................................................................... ១៦
២.៤.២. ស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភា ...............................................................................................១៧
**២.៥. ស្ត្រីនៅក្នុងស្ថាប័ននីតិប្រតិបត្តិ**.............................................................................................. ១៧
**២.៦. ស្ត្រីនៅក្នុងស្ថាប័នតុលាការ** ...............................................................................................១៧
**២.៧. ស្ត្រី និងបុរសជាមន្ត្រីរាជការ**..................................................................................................... ១៨
**២.៨. ស្ត្រី និងបុរសនៅថ្នាក់ក្រោមជាតិ** ......................................................................................... ១៨
២.៨.១. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ..................................................................................... ១៨
២.៨.២. ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ .................................................................................. ១៨
២.៨.៣. ការបោះឆ្នោតឃុំ-សង្កាត់..................................................................................................... ១៩
២.៨.៣.១. ការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០១២ ..................................................................................... ១៩
២.៨.៣.២. ការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០២២ ......................................................................................២០
**២.៩. ស្ត្រីនៅក្នុងវិស័យកិច្ចការអន្តរជាតិ**..........................................................................................២២
**២.១០. ស្ត្រីនៅក្នុងវិស័យយោធា**......................................................................................................២២
**២.១១. ស្ត្រីនៅក្នុងវិស័យអប់រំ** ...................................................................................................... ២៣
២.១១.១. ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ............................................................................២៣
២.១១.១.១. ការសិក្សាក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩.............................................២៦
២.១១.១.២. គោលនយោបាយ និងក្របខណ្ឌអភិវឌ្ឍន៍..................................................................២៧
២.១១.២. ការអប់រំកម្រិតឧត្តមសិក្សា ...................................................................................................២៩
២.១១.២.១. ការចុះឈ្មោះចូលរៀន........................................................................................................ ៣០
២.១១.២.២. និស្សិតកំពុងសិក្សាកម្រិតឧត្តម និងអាហារូបករណ៍(២០១៥-២០២០)........................................... ៣១
២.១១.២.៣. បញ្ហាប្រឈម .................................................................................................................. ៣១
២.១១.២.៤. កំណែទម្រង់ឧត្តមសិក្សា ...................................................................................................៣២

## ជំពូកទី៣

## បញ្ហាប្រឈមរបស់ស្ត្រីនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន

**៣.១. ការជួញដូរស្ត្រី និងក្មេងស្រី**..........៣៣

៣.១.១. ការជួញដូរមនុស្សបែបពាណិជ្ជកម្ម..........៣៥

៣.១.២. ការឆបោកតាមរយៈការរកការងារឲ្យធ្វើ..........៣៥

៣.១.៣. អាពាហ៍ពិពាហ៍ក្លែងក្លាយ..........៣៦

៣.១.៤. ស្នុំកូន..........៣៦

៣.១.៥. អាជីវកម្មលើពលកម្មកុមារ..........៣៦

៣.១..៦. អំពើហិង្សាក្នុងគ្រួសារ..........៣៦

**៣.២. អំពើហិង្សាប្រឆាំងនឹងស្ត្រី**..........៣៧

៣.២.១. អំពើហិង្សាផ្លូវកាយ..........៣៧

៣.២.២. អំពើហិង្សាផ្លូវចិត្ត..........៣៧

៣.២.៣. អំពើហិង្សាផ្លូវភេទ..........៣៨

៣.២.៣.១. ការរំលោភសេពសន្ថវៈជាទូទៅ..........៣៨

៣.២.៣.២. ការរំលោភសេពសន្ថវៈដោយសាច់ញាតិ..........៤០

**៣.៣. ទំនៀមទម្លាប់ប្រពៃណី**..........៤១

**៣.៤. បញ្ហាសុខភាព**..........៤៤

## ជំពូកទី៤

## ក្របខណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

**៤.១. គោលនយោបាយ និងក្របខណ្ឌច្បាប់នៅក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យនយោបាយ និងការធ្វើសេចក្តីសម្រេច**..........៤៧

**៤.២. ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥**(**២០១៩**-**២០២៣**)..........៤៨

៤.២.១. យុទ្ធសាស្ត្រទី១ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី..........៤៨

៤.២.២. យុទ្ធសាស្ត្រទី២ ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី..........៤៩

៤.២.៣. យុទ្ធសាស្ត្រទី៣ ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី..........៥១

៤.២.៤. យុទ្ធសាស្ត្រទី៤ កិច្ចគាំពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី..........៥២

៤.២.៥. យុទ្ធសាស្ត្រទី៥ ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ..........៥៣

៤.២.៦. យុទ្ធសាស្ត្រទី៦ ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ..........៥៤

**សេចក្តីសន្និដ្ឋាន**.......................................................................................................... ៥៦
**អនុសាសន៍**.......................................................................................................................៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

1. **គ.ជ.ប** ៖ គណៈកម្មការជាតិរៀបចំការបោះឆ្នោត
2. **គ.ជ.អ.ប** ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
3. **គ.ទ.ក** ៖ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា
4. **ប.ស.ស** ៖ បេឡាជាតិរបបសន្តិសុខសង្គម
5. **ស្ទែម** ៖ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM Science, technology, engineering and math.)
6. UDHR ៖ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
7. OHCHR ៖ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ
8. AHRD ៖ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន
9. EBA ៖ ប្រព័ន្ធអនុគ្រោះពន្ធលើទំនិញគ្រប់មុខលើកលែងតែសព្វាវុធ
10. GDP ៖ ផលិតផលសរុបក្នុងស្រុក
11. CMDG ៖ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា
12. GADC ៖ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (អង្គការហ្គេតស៊ី)
13. NGO-CEDAW ៖ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ
14. CAMBOW ៖ គណៈកម្មាធិការស្ត្រីកម្ពុជា
15. TWGG-WLG ៖ អភិបាលកិច្ចនៃក្រុមការងារបច្ចេកទេសយេនឌ័រ
16. GMAPs ៖ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
17. NAPVAWIII ៖ ផែនការសកម្មភាពជាតិលើកទី៣ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី
18. CMDG ៖ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំនៃបញ្ហាស្រាវជ្រាវ

មូលហេតុចម្បងដែលនាំទៅរកការប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺដោយសារប្រវត្តិសាស្ត្រដ៏ជូរចត់របស់មនុស្សជាតិក្នុងសម័យអតីតកាល ដែលលក្ខខណ្ឌរស់នៅរបស់មនុស្សក្នុងសម័យអតីតកាល មានការរើសអើងមនុស្សជាតិដូចគ្នា។ មនុស្សទន់ខ្សោយ ពួកស្បែកខ្មៅ និងវណ្ណៈអធន រាប់បញ្ចូលទាំងស្ត្រី មានលក្ខខណ្ឌរស់នៅក្នុងសភាពមិនមែនជាមនុស្ស។ ហេតុផលម្យ៉ាងទៀត គឺសង្គ្រាមដែលបង្កគ្រោះមហន្តរាយគួរឲ្យតក់ស្លុតជាទីបំផុត និងត្រូវបានគេចាត់ទុកថា ជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតមិនគួរអត់ឱនឲ្យបាន។

ភាពខ្លោចផ្សាហួសប្រមាណដែលកើតពីមហន្តរាយទាំងនេះ បានជម្រុញទឹកចិត្តអ្នកប្រាជ្ញដែលមានទឹកចិត្តស្រលាញ់មនុស្សជាតិ និងសន្តិភាព ធ្វើការតស៊ូយ៉ាងស្វិតស្វាញក្នុងការតាក់តែងឯកសារសិទ្ធិមនុស្សឡើងក្នុងគោលបំណងទប់ស្កាត់ការរំលោភបំពានសិទ្ធិមនុស្សនៅពេលអនាគត។

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើកតិកាសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើន ក្នុងនោះក៏មាន «**អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ**» ផងដែរ។ ក្រោយការបោះឆ្នោតជាតិ ឆ្នាំ ១៩៩៣ ដែលរៀបចំដោយ **អ៊ុន តាក់** នៅខែកញ្ញា ឆ្នាំ១៩៩៣ កម្ពុជាបានប្រកាសរដ្ឋធម្មនុញ្ញថ្មី ក្នុងនោះក៏មានចែងអំពីសិទ្ធិនារីផងដែរ។

## ២. ចំណោទនៃបញ្ហាស្រាវជ្រាវ

ធម្មជាតិបានបង្កើតមនុស្សឲ្យមានភេទផ្សេងគ្នា គឺប្រុស និងស្រី។ ក្នុងន័យនេះ មនុស្សត្រូវតែមានភាពថ្លៃថ្នូរ ចេះគោរពគ្នាទៅវិញទៅមក ពោលគឺ អ្នកខ្លាំងមិនត្រូវបំពានលើអ្នកទន់ខ្សោយ ដូចជាស្ត្រីជាដើមឡើយ។ ការស្រាវជ្រាវប្រធានបទនេះ ជាការឆ្លើយតបនឹងសំណួរដូចខាងក្រោម៖

- តើសិទ្ធិនារីជាអ្វី? សិទ្ធិនេះមានសារៈសំខាន់បែបណាចំពោះមនុស្សស្រី?
- តើស្ថានភាពស្ត្រីនៅកម្ពុជាបច្ចុប្បន្នដូចម្តេច?
- តើអ្វីខ្លះជាបញ្ហាប្រឈមរបស់ស្ត្រីនៅកម្ពុជា?
- តើរាជរដ្ឋាភិបាលកម្ពុជាមានគោលដៅបែបណាចំពោះស្ត្រី?

## ៣. គោលបំណងនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ ធ្វើឡើងក្នុងបំណងបង្ហាញពីស្ថានភាពរបស់ស្ត្រីនៅកម្ពុជាសម័យបច្ចុប្បន្ន និងបង្ហាញពីសារៈសំខាន់ និងការចូលរួមចំណែករបស់ស្ត្រីលើគ្រប់វិស័យ។ ជាមួយគ្នានេះ កិច្ចការស្រាវជ្រាវនេះធ្វើឡើងដើម្បីជាប្រយោជន៍ក្នុងការយល់ដឹង និងចែករំលែកពុទ្ធិដល់មិត្តអ្នកអាន ក្នុងការស្វែងយល់ពីវិស័យសិទ្ធិមនុស្ស។

## ៤. ទំហំនៃការស្រាវជ្រាវ

កិច្ចស្រាវជ្រាវនេះ ធ្វើការសិក្សាផ្តោតសំខាន់ពីបច្ចុប្បន្នភាព និងដែលមានវិសាលភាពស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ នឹងចូលរួមចំណែកសម្រាប់ការស្រាវជ្រាវរបស់បងប្អូននិស្សិត ក៏ដូចជាចូលរួមជាវិភាគទាននៅក្នុងការចែករំលែកពុទ្ធិដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងការយល់ដឹងពាក់ព័ន្ធនឹងសិទ្ធិនារី។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវដើម្បីសម្រេចប្រធានបទ «**សិទ្ធិនារីនៅកម្ពុជា**» នេះឡើង យើងពឹងផ្អែកលើវិធីសាស្ត្រមួយចំនួនដើម្បីធ្វើការស្រាវជ្រាវ និងប្រមូលទិន្នន័យចងក្រងជាឯកសារ មកពណ៌នាតាមលំដាប់លំដោយ ផ្អែកលើប្រភពដូចជា៖

– លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលជាធរមានដូចជាៈ ច្បាប់ អនុសញ្ញា កតិកាសញ្ញា សេចក្តីប្រកាស សៀវភៅ និងរបាយការណ៍ជាដើម។

– ឯកសារដែលមានប្រភពចេញពី បណ្តាញសង្គម គេហទំព័រផ្លូវការណ៍របស់ស្ថាប័នពាក់ព័ន្ធ ជាពិសេសអង្គការក្រៅរដ្ឋាភិបាល។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ ត្រូវបានបែងចែកជាបួន(៤)ជំពូកដូចខាងក្រោម៖

- សេចក្តីផ្តើម៖ ផ្នែកនេះនិយាយពី លំនាំនៃបញ្ហាស្រាវជ្រាវ ចំណោទនៃបញ្ហាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូកទី១ សិទ្ធិនារីអន្តរជាតិ៖ ចង់បង្ហាញឲ្យឃើញពីស្ថានភាពរបស់នារីមុនពេលទទួលបានសិទ្ធិ ដំណើរការទាមទារសិទ្ធិ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងស្ត្រី។
- ជំពូកទី២ សិទ្ធិនារីនៅកម្ពុជា៖ ជំពូកនេះនិយាយពីស្ថានភាពនារីក្នុងប្រវត្តិសាស្ត្រខ្មែរ និងអំពីស្ថានភាពជាក់ស្តែងរបស់នារីខ្មែរសម័យបច្ចុប្បន្ន។
- ជំពូកទី៣ បញ្ហាប្រឈមរបស់ស្ត្រីនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន៖ បង្ហាញពីអ្វីខ្លះដែលស្ត្រីខ្មែរកំពុងជួបប្រទះ និងឧបសគ្គដែលរារាំងស្ត្រីមិនឲ្យសម្រេចបានតាមគោលដៅ។
- ជំពូកទី៤ ក្របខណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល៖ បង្ហាញពីគោលការណ៍អភិវឌ្ឍ និងគោលដៅរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបានគោលដៅសមភាពរវាងបុរស និងស្ត្រី។

# ជំពូកទី១

# សិទ្ធិនារីអន្តរជាតិ

# ជំពូកទី១
# សិទ្ធិនារីអន្តរជាតិ

## ១.១. សញ្ញាណនៃសិទ្ធិនារី

**តើសិទ្ធិនារីជាអ្វី?**

**ក. សិទ្ធិ** គឺជាអំណាចពិសេសរបស់មនុស្សដែលធម្មជាតិផ្តល់ឲ្យតាំងពីកំណើតសម្រាប់ឲ្យមនុស្សការពារខ្លួនពីការរំលោភបំពាននៃអ្នកដទៃ និងអាចឲ្យមនុស្សធ្វើនេះ ឬធ្វើនោះក្នុងករណីស្របច្បាប់។

**ខ.សិទ្ធិនារី** សិទ្ធិនារី គឺជាសិទ្ធិរបស់នារីរាប់ពីការចាប់កំណើត និងសិទ្ធិនារីដែលទាមទារជាសកលដើម្បីការពារការរំលោភបំពាន និងធ្វើអ្វីៗមានសិទ្ធិស្មើនឹងបុរសក្នុងលក្ខណៈស្របច្បាប់[1]។

## ១.២. ប្រវត្តិ និងមូលហេតុនៃការទាមទារសិទ្ធិនារី

### ១.២.១. តេរេសា ម៉ាល់គៀល និង ក្លារ៉ា សេតគីន

ថ្ងៃទី៨ មីនា គឺជាទិវាអន្តរជាតិនៃសិទ្ធិនារី ដែលបច្ចុប្បន្នត្រូវបានគេប្រារព្ធធ្វើឡើងជាទូទៅក្នុងពិភពលោកយើង។ ទិវានេះ គឺជានិមិត្តរូបនៃការតស៊ូ ទាមទារ សិទ្ធិសេរីភាពរបស់ស្ត្រីប្រឆាំងនឹងការរើសអើងផ្លូវភេទ ព្រមទាំងវិសមភាពទាំងអស់រវាងបុរស និងស្ត្រី។ មុននឹងមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិរហូតសព្វថ្ងៃនេះ គឺមានការតស៊ូប្រឹងប្រែងអស់ប្រមាណមួយសតវត្សពីសំណាក់សកម្មជន ដើម្បីឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតសង្គមក្នុងការទទួលស្គាល់សិទ្ធិរបស់ស្ត្រី។

ការតស៊ូទាមទារសិទ្ធិស្ត្រី ទម្រាំតែមានទិវាអន្តរជាតិ ៨ មីនានេះ គឺជាលទ្ធផលនៃការតវ៉ាទាមទាររបស់សកម្មជនអស់រយៈពេលរាប់សិបឆ្នាំ បន្តិចម្តងៗទម្រាំតែមានថ្ងៃនេះ។

នៅសតវត្សទី១៩ ប្រទេសមួយចំនួននៅទ្វីបអឺរ៉ុប និងអាមេរិកមានការរីកចម្រើនយ៉ាងខ្លាំងក្នុងផ្នែកឧស្សាហកម្ម។ កំណើនយ៉ាងឆាប់រហ័សនូវរោងចក្រសហគ្រាសទាំងឡាយ បានស្រូបយកកម្លាំងកម្មករជាច្រើនសន្ធឹកសន្ធាប់ទាំងបុរស នារី និងកុមារ។ ប៉ុន្តែម្ចាស់រោងចក្រទាំងនោះ ពុំបានផ្តល់តម្លៃសមស្របចំពោះនារីភេទឡើយ។ ក្នុងមួយថ្ងៃៗ នារីត្រូវធ្វើការពី១២ ទៅ ១៤ម៉ោងក្នុងរោងចក្រ តែទទួលបានប្រាក់បៀវត្សទាបជាទីបំផុត ស្ទើរតែមិនអាចរស់នៅបាន គឺទាបជាងតម្លៃពលកម្មបុរស។ ដូច្នេះហើយ ទើបពីមួយថ្ងៃទៅមួយថ្ងៃសុខភាពស្ត្រីទាំងនោះចេះតែទ្រុឌទ្រោមទៅ។ ទីបំផុត គេបញ្ឈប់ពីការងារជាបន្តបន្ទាប់ ដោយមានទស្សនៈថា នារីជាភេទទន់ខ្សោយមិនអាចធ្វើការបានដូចបុរស។ អំពើកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរលើកម្លាំងពលកម្មនេះ ធ្វើឲ្យស្ត្រីឈឺចាប់ជាខ្លាំងរហូតមិនអាចទ្រាំទ្រតទៅទៀតបាន[2]។

[1] សិទ្ធិនារីជាអ្វី? https://www.khsearch.com/qna/3206

[2] គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, សៀវភៅគ្រូ សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ (ឆ្នាំ២០១១)

អ្វីៗបានចាប់ផ្តើមក្នុងឆ្នាំ១៩០៩ នៅទីក្រុងញូយ៉ក គឺនៅថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ១៩០៩ ដែលគេបានរៀបចំទិវាមួយ ហៅថា “ទិវាជាតិនៃស្ត្រី” ដែលត្រូវបានផ្តួចផ្តើមគំនិតដោយគណបក្សសង្គមនិយមអាមេរិក កាលជំនាន់នោះ និងជាពិសេសនោះ គឺក្រោមការប្រឹងប្រែងរបស់ស្ត្រីសកម្មជនទាមទារសិទ្ធិម្នាក់ឈ្មោះ តេរេសា ម៉ាល់គៀល[3]។ គាត់មានដើមកំណើតនៅប្រទេសអ៊ុយក្រែននាឆ្នាំ១៨៧៤ ហើយបានធ្វើការតស៊ូ ទាមទារឲ្យមានការកែលម្អលក្ខខណ្ឌការងាររបស់ពលការិនី កម្មការិនីនៅតាមរោងចក្រ កាលពីជំនាន់នោះ។ ក្រោមការប្រឹងប្រែងនេះ គេបានរៀបចំកម្មវិធីជួបជុំ ធ្វើមិទ្ទិញជាច្រើននៅទីក្រុងញូយ៉ក ដើម្បីនិយាយអំពីការលំបាករបស់ស្ត្រី។

ក្រោយមកនៅឆ្នាំ១៩១០ លោកស្រី តេរេសា ម៉ាល់គៀល បានសរសេរសៀវភៅប្រលោមលោកមួយ មានចំណងជើងថា “ជីវិតរបស់ស្ត្រីធ្វើកូដកម្មម្នាក់” ដែលសៀវភៅនេះបានក្លាយទៅជាមូលដ្ឋានគ្រឹះនៃការតស៊ូរើបម្រះដើម្បីបញ្ចប់ការជិះជាន់លើស្ត្រី។ ហើយក្នុងឆ្នាំ១៩១០ ដដែលនេះដែរ នៅទីក្រុងកូប៉េនហាហ្គ ប្រទេសដាណឺម៉ាក មានសន្និបាទនៃចលនាសង្គមនិយមអន្តរជាតិ។ ស្ត្រីសកម្មជនម្នាក់ទៀត ជាជនជាតិអាល្លឺម៉ង់ ឈ្មោះ ក្លារ៉ា សេតគីន[4] បានយកឱកាសនោះជម្រុញឲ្យមានការផ្តួចផ្តើមទិវាមួយសម្រាប់ស្ត្រី ដើម្បីលើកកម្ពស់សមភាពរវាងភេទ និងជាពិសេសនោះ គឺដើម្បីឲ្យស្ត្រីអាចមានសិទ្ធិបោះឆ្នោតដូចបុរស។ តែកាលនោះ គេមិនទាន់កំណត់ថា យកថ្ងៃណាឲ្យប្រាកដ ដើម្បីប្រារព្ធទិវាសិទ្ធិនារីទេ។

### ១.២.២. បដិវត្តន៍សង្គមនិយមរុស្ស៊ី

ជាបន្តបន្ទាប់ មាននារីអ្នកដឹកនាំចលនាតស៊ូបីរូបបានលេចឡើង គឺលោកស្រី រ៉ូហ្សា លុចសំបួ[5] ជនជាតិប៉ូឡូញ លោកស្រី ក្លារ៉ា សេតគីន ជនជាតិអាល្លឺម៉ង់ និងលោកស្រី គ្រូប ស្កាយ៉ា[6] ជនជាតិរុស្ស៊ី ដែលជាភរិយារបស់លោក លេនីន បានដឹកនាំក្រុមតស៊ូនារីលុះត្រាតែទទួលបាននូវជោគជ័យជាប្រវត្តិសាស្ត្រក្នុងឆ្នាំ១៩១០[7]។

កាលពីដំបូងគេបានប្រារព្ធទិវាសិទ្ធិនារីលើកទីមួយ គឺនៅថ្ងៃទី១៩ មីនា ឆ្នាំ១៩១១ ដោយកាលនោះ មានមនុស្សចូលរួមដង្ហែក្បួនជាងមួយលាននាក់ នៅក្នុងប្រទេសអូទ្រីស ប្រទេសដាណឺម៉ាក អាល្លឺម៉ង់ និងស្វីសជាដើម។ ក្រោយមក ថ្ងៃទី៨ មីនា មានហេតុការណ៍មួយទៀតកើតឡើងនៅឆ្នាំ១៩១៤ នៅទីក្រុងប៉ែរឡាំង ដែលកាលនោះ ស្ត្រីសកម្មជននយោបាយសង្គមនិយមអាល្លឺម៉ង់ បាននាំគ្នាធ្វើបាតុកម្មយ៉ាងធំធេងដើម្បីទាមទារសិទ្ធិបោះឆ្នោត។

[3] Theresa Serber Malkiel(1874-1949)
[4] Clara Zetkin(1857-1933)
[5] Rosa Luxemburg(1871-1919)
[6] Nadezhda Konstantinovna Krupskaya(1869-1939)
[7] គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, សៀវភៅគ្រូ សីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ (ឆ្នាំ២០១១)

ហើយបន្ទាប់មកទៀត នៅថ្ងៃទី៨ មីនា ឆ្នាំ១៩១៧ នៅទីក្រុងសាំងប៉េតេសបួរ ប្រទេសរុស្ស៊ី មានព្រឹត្តិការណ៍បាតុកម្មមួយទៀតរបស់ស្ត្រីរុស្ស៊ី។ បរិបទពិភពលោកយើងពេលនោះ គឺស្ថិតក្នុងសង្គ្រាមលោកលើកទី១ ហើយដែលប្រុសៗត្រូវគេបញ្ជូនឲ្យទៅធ្វើសង្គ្រាមអស់ ទុកឲ្យស្ត្រីនៅផ្ទះចិញ្ចឹមកូនផង ធ្វើការនៅតាមរោងចក្រ ផលិតសព្វាវុធ ផលិតស្បៀងអាហារយកទៅឲ្យកងទ័ពផង។

ស្ថានភាពនៅរុស្ស៊ីពេលនោះជួបការលំបាកខ្លាំង ដោយសារតែគ្រោះអត់ឃ្លាន។ គឺការបះបោររបស់ស្ត្រីរុស្ស៊ី នៅថ្ងៃទី ៨ មីនា ឆ្នាំ១៩១៧ នេះហើយ ដែលបានធ្វើឲ្យអំណាចរបស់ព្រះចៅត្សារ នៃអាណាចក្ររុស្ស៊ីចាប់ផ្តើមរង្គោះរង្គើ ហើយឈានទៅមានបដិវត្តន៍សង្គមនិយមរបស់ពួកកុម្មុយនីស្តសូវៀត។ យ៉ាងណាមិញ បក្សបុលឆេវិកសូវៀត បានចាត់ទុកថ្ងៃទី៨ មីនា ឆ្នាំ១៩១៧ គឺជាថ្ងៃចាប់ផ្តើមទីមួយនៃបដិវត្តរុស្ស៊ី។ ហេតុដូច្នេះហើយ បានជាក្រោយមក នៅតាមប្រទេសកុម្មុយនីស្តដែលស្ថិតក្រោមឥទ្ធិពលសូវៀត គឺគេបានប្រារព្ធពិធីបុណ្យ ៨ មីនា នេះជាប្រចាំ។

### ១.២.៣. អង្គការសហប្រជាជាតិកំណត់ជាផ្លូវការ នៅឆ្នាំ១៩៧៥

ក្នុងទសវត្សឆ្នាំ១៩៧០ប្លាយ មានចលនាមួយឈ្មោះ "ចលនាហ៊ីបពី" បានរីកសាយភាយនៅតាមប្រទេសធំៗ ដើម្បីរំដោះរនាំងប្រពៃណីដែលរុំព័ទ្ធយុវជនមិនថាប្រុសមិនថាស្រី។ មនុស្សម្នាក់ៗចាប់ផ្តើមយល់ថា សិទ្ធិសេរីភាព សមភាព គឺជាកម្មវត្ថុ និងជាខ្លឹមសារចម្បងសម្រាប់ជីវិត។ ក្នុងបរិបទនេះហើយ គឺនៅឆ្នាំ១៩៧៥ ទើបអង្គការសហប្រជាជាតិបានសម្រេចកំណត់ថ្ងៃទី៨ មីនា ជាទិវាសិទ្ធិនារីអន្តរជាតិតែម្តង។ ជាទិវាដែលអង្គការសហប្រជាជាតិ រៀបចំដើម្បីកំណត់កម្មបទថ្មីៗជារៀងរាល់ឆ្នាំ ស្តីពីការរីកចម្រើននៃសិទ្ធិស្ត្រីនៅទូទាំងពិភពលោក មិនថាសិទ្ធិសង្គម សេដ្ឋកិច្ច និងសិទ្ធិនយោបាយ។

ទិវាសិទ្ធិនារីអន្តរជាតិ៨ មីនានេះ មិនមែនត្រូវបានគេប្រារព្ធជាទូទៅភ្លាមៗទេ។ ការផ្លាស់ប្តូរផ្នត់គំនិត បានប្រសើរឡើងបន្តិចម្តងៗ ដោយការប្រឹងប្រែងរបស់អ្នកនយោបាយខ្លះ និងសកម្មជនខ្លះផង។ ជាក់ស្តែងនៅបារាំងទាល់តែឆ្នាំ១៩៨២ ទើបបានមានការកំណត់ជាផ្លូវការណ៍ ស្តីពី ទិវា៨ មីនានេះ។

ដូច្នេះមុននឹងមានថ្ងៃទី៨ មីនានេះ គឺឆ្លងកាត់ការតស៊ូច្រើនដំណាក់ណាស់។ ទោះបីជាយ៉ាងណា ប្រមាណមួយសតវត្សមកនេះ សមភាពឥតខ្ចោះក្នុងគ្រប់វិស័យរវាងបុរស និងស្ត្រី គឺនៅតែមិនអាចទៅរួចនោះទេ។ មនុស្សជំនាន់ក្រោយ មិនមែនត្រឹមតែត្រូវថែរក្សាលទ្ធផលនៃការតស៊ូទាំងនេះទេ តែត្រូវតែបន្តការប្រឹងប្រែង ដើម្បីសមភាព និងប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី[8]។

---

[8] ម៉ម ពិសី, *តើទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា មានប្រភពមកពីណា?* ,https://www.rfi.fr/km

## ១.៣. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)ឆ្នាំ១៩៤៨

ធម្មនុញ្ញសហប្រជាជាតិ ជាលិខិតូបករណ៍មួយដ៏សំខាន់ក្នុងការធានា និងការពារនូវការគោរពសិទ្ធិមនុស្សសម្រាប់ប្រជាជាតិទាំងមូល។ គួរកត់សម្គាល់ថា ប្រទេសទាំងអស់ដែលជាសមាជិកអង្គការសហប្រជាជាតិ គឺជារដ្ឋហត្ថលេខីដ៏សំខាន់ដែលបានសន្យាថា ខ្លួននឹងធានានូវការគោរព និងអនុវត្តនូវសិទ្ធិមនុស្សជាមូលដ្ឋានឲ្យបានដាច់ខាត។ ប៉ុន្តែក្នុងដំណាក់កាលនោះ បញ្ហានៃការរំលោភសិទ្ធិមនុស្សនៅតែកើតមានក្នុងចំណោមបណ្តាប្រទេសមួយចំនួនដែលជាសមាជិកអង្គការសហប្រជាជាតិដដែល។ ដោយយល់ឃើញថា ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេសគឺសមភាពរវាងបុរស និងស្ត្រីដែលជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងលោកដើម្បីលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង។

អាស្រ័យហេតុនេះ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានចែងអំពីទស្សនៈជារួមនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៃសិទ្ធិមនុស្ស ដែលបានបញ្ញត្តិអំពីការទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាប់ពីកំណើតរួមមាន សិទ្ធិស្មើគ្នាដែលមិនអាចលក់ ដូរ ផ្ទេរ និងមិនអាចបែងចែកបាន។ ដូចមានចែងនៅក្នុងអារម្ភកថានៃសេចក្តីប្រកាសនេះ បានរៀបរាប់ពីឧត្តមគតិយ៉ាងសំខាន់នៃសិទ្ធិមនុស្សថា *"មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ"*។

លើសពីនេះទៅទៀត សេចក្តីប្រកាសនេះត្រូវបានបញ្ញត្តិផ្តល់តម្លៃទៅលើសេចក្តីថ្លៃថ្នូរ និងគោលការណ៍សមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ដែលជាការប្តេជ្ញាលើកស្ទួយនូវវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង។ យោងតាមគោលការណ៍សមភាពនេះ បានសេចក្តីថា បុរស និងស្ត្រី មានសិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់ និងពិតជាមានឱកាសទទួលបានសេវាផ្សេងៗ និងចូលរួមកិច្ចការសាធារណៈដូចៗគ្នានៅក្នុងសង្គម[9]។

## ១.៤. កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(OHCHR)ឆ្នាំ១៩៦៦

កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានមហាសន្និបាទអង្គការសហប្រជាជាតិអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងបានចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញានេះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ហើយបានផ្តល់សច្ចាប័ននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ និងចូលជាធរមាននៅប្រទេសកម្ពុជា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។

[9] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)ឆ្នាំ១៩៤៨

គោលការណ៍ទូទៅនៅក្នុងកតិកាសញ្ញានេះរួមមាន៖

– សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនទាំងអស់ ដើម្បីធ្វើសេចក្តីសម្រេចពីឋានៈនយោបាយរបស់ខ្លួន ដោយសេរី និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

– គោលការណ៍នៃការមិនរើសអើង ក្នុងការអនុវត្តសិទ្ធិតាមកតិកាសញ្ញា

– គោលការណ៍សមភាពរវាងបុរស និងស្ត្រី ក្នុងការអាស្រ័យសិទ្ធិទាំងនេះ។

សិទ្ធិភាគច្រើននៅក្នុងកតិកាសញ្ញានេះ គឺជាសិទ្ធិដាច់ខាត ហើយត្រូវតែអនុវត្តភ្លាម និងទាំងស្រុងខណៈដែលសិទ្ធិទាំងនេះចូលជាធរមាន។

សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញានេះរួមមាន៖

– **សិទ្ធិមានជីវិត** រួមមានគោលការណ៍ណែនាំពីពេលវេលា និងរបៀបនៃការដាក់ទោសប្រហារជីវិត

– **សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀត** ដែលឃោរឃៅ អមនុស្សធម៌ និងការបន្ថោកបន្ទាប ព្រមទាំងសេរីភាពរួចផុតពី ទាសភាព ភាពជាខ្ញុំកញ្ជះគេ និងការងារដោយបង្ខំ

– **សិទ្ធិមានសេរីភាព និងសន្តិសុខបុគ្គល** រួមមានសេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត និងសិទ្ធិការពារមួយចំនួន ក្នុងកំឡុងពេលនៃការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ពន្ធនាគារតាមផ្លូវច្បាប់

– **សេរីភាពនៃការដើរហើរ** រួមមានសិទ្ធិចាកចេញពីប្រទេសណាមួយ និងសិទ្ធិរបស់ជនបរទេស ទទួលបាននីតិវិធីត្រឹមត្រូវមុននឹងត្រូវបណ្តេញចេញពីប្រទេសណាមួយ

– **សិទ្ធិទទួលបានភាពស្មើគ្នាចំពោះមុខច្បាប់ និងតុលាការ និងសិទ្ធិទទួលបានសវនាការប្រកបដោយភាពយុត្តិធម៌ជាមូលដ្ឋាន** រួមមានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានសវនាការមួយប្រកបដោយភាពយុត្តិធម៌ពីតុលាការមួយឯករាជ្យ សិទ្ធិការពារខ្លួន សិទ្ធិមានមេធាវី និងសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

– **សិទ្ធិក្នុងការទទួលស្គាល់ថាជាមនុស្សនៅចំពោះមុខច្បាប់**

– **សិទ្ធិមានជីវិតឯកជន និងទទួលបានការការពារពីការវាយប្រហារលើកិត្តិយស ឬកិត្តិស័ព្ទរបស់ខ្លួន**

– **សេរីភាពនៃគំនិត មនសិការ និងសាសនា សេរីភាពនៃការបញ្ចេញមតិ និងយោបល់** តែត្រូវហាមឃាត់ចំពោះការឃោសនាឲ្យមានសង្គ្រាម និងការតស៊ូមតិឲ្យមានការស្អប់ជាតិ ពូជសាសន៍ ឬសាសនា

– **សិទ្ធិជួបប្រជុំដោយសន្តិវិធី** ជួនកាលហៅថា សេរីភាពនៃការជួបប្រជុំ ព្រមទាំងសេរីភាពសមាគមន៍ រួមទាំងសិទ្ធិបង្កើត និងចូលរួមសហជីព

– **សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ និងសិទ្ធិការពារកុមារ**

– **សិទ្ធិប្រជាធិបតេយ្យ** រួមមាន សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត និងសិទ្ធិចូលរួមកិច្ចការសាធារណៈ

– **សិទ្ធិរបស់ជនជាតិភាគតិច**[10]។

## ១.៥. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

អនុសញ្ញានេះ ត្រូវបានធនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៧៩ និងចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨១។ ដោយឡែកប្រទេសកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញានេះ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ តុលា ឆ្នាំដដែលដោយឥតលក្ខខណ្ឌ។

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហៅកាត់ជាភាសាអង់គ្លេសថា CEDAW ត្រូវបានគេចាត់ទុកថាជា “ច្បាប់អន្តរជាតិស្តីពីសិទ្ធិ” សម្រាប់ស្ត្រី។ អនុសញ្ញានេះ គឺជាឯកសារយ៉ាងក្បោះក្បាយទាក់ទងទៅនឹងការរំលោភបំពានសិទ្ធិមនុស្ស ដែលកើតមានលើមូលដ្ឋានការរើសអើងលើយេនឌ័រ។ អនុសញ្ញានេះបញ្ជាក់បន្ថែមជាវិជ្ជមានមកលើគោលការសមភាព ដែលតម្រូវឲ្យរដ្ឋភាគីចាត់វិធានការសមរម្យទាំងឡាយ ដើម្បីធានាការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី ក្នុងគោលបំណងធានាឲ្យពួកគេអាចប្រើ និងទទួលផលប្រយោជន៍ពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានលើមូលដ្ឋានសមភាពជាមួយបុរស។

## ១.៦. សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន(AHRD)ឆ្នាំ២០១២

នៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន ដែលត្រូវបានអនុម័តឡើងនៅរាជធានីភ្នំពេញនាថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១២ ក៏មានចែងពីចំណុចមួយចំនួនទាក់ទងនឹងសិទ្ធិនារី និងវិស័យសិទ្ធិមនុស្សជាទូទៅក្នុងតំបន់អាស៊ាន ដូចជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងតំបន់អាស៊ាន សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌នៅក្នុងតំបន់អាស៊ាន សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិទទួលបានសន្តិភាព និងកិច្ចសហការក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងតំបន់ជាដើម។

សិទ្ធិនារីដែលមានចែងនៅក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានរួមមាន៖

**គោលការណ៍ទូទៅ**

– (២) មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានសិទ្ធិនិងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការបែងចែកអំពីជាតិសាសន៍ ភេទ អាយុ ភាសា សាសនា មតិនយោបាយឬមតិឯទៀត ប្រភពដើមនៃជាតិឬសង្គម ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពកំណើត ស្ថានភាពពិការភាព ឬស្ថានភាពអ្វីផ្សេងទៀតឡើយ។

[10] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម

– (៤) សិទ្ធិរបស់ស្ត្រី កុមារ ជនចាស់ជរា ជនមានពិការភាព ពលករទេសន្តរប្រវេសន៍ និងក្រុមជនងាយរងគ្រោះ និងក្រុមជនដែលគេបោះបង់ចោលគឺជាផ្នែករួមបញ្ចូលដែលមិនអាចដកបាន និងមិនអាចបំបែកបានពីសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។

**សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

– (១៣) គ្មានមនុស្សណាម្នាក់ត្រូវស្ថិតនៅក្រោមទម្រង់ណាមួយនៃសេវគតិភាពឬទាសភាព ឬជាកម្មវត្ថុនៃការរត់ពន្ធមនុស្ស ឬការជួញដូរមនុស្ស រាប់បញ្ចូលទាំងការរត់ពន្ធឬជួញដូរមនុស្សក្នុងគោលបំណងនៃការជួញដូរសរីរាង្គ។

– (១៩) គ្រួសារ ជាធាតុធម្មជាតិនិងជាធាតុមូលដ្ឋានរបស់សង្គម មានសិទ្ធិទទួលបានការការពារដោយសង្គម និងដោយរដ្ឋជាសមាជិកអាស៊ាននីមួយៗ។ បុរសនិងស្ត្រីដែលពេញវ័យមានសិទ្ធិរៀបអាពាហ៍ពិពាហ៍លើមូលដ្ឋាននៃសេរីភាព និងការព្រមព្រៀងពេញលេញរបស់ខ្លួន ដើម្បីបង្កើតគ្រួសារមួយ និងផ្តាច់ចំណងអាពាហ៍ពិពាហ៍ដូចដែលមានចែងដោយច្បាប់។

**សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌**

– (២) ការគាំពារជាពិសេសត្រូវបានផ្តល់ជូនទៅមាតាក្នុងកំឡុងពេលសមស្របដូចបានចែងក្នុងច្បាប់ជាតិនិងវិធានផ្សេងៗ មុននិងក្រោយពេលសម្រាលបុត្រ។ ក្នុងកំឡុងពេលពិសេសនេះ ម្តាយដែលកំពុងបំពេញការងារ ត្រូវទទួលបានការឈប់សម្រាកដោយទទួលបានប្រាក់បៀវត្សន៍ ឬការឈប់សម្រាកដោយមានរបបសន្តិសុខសង្គមគ្រប់គ្រាន់។

– (៣) ទាំងមាតុភាព និងកុមារភាពផងត្រូវទទួលបានការថែទាំនិងជំនួយជាពិសេស។ កុមារគ្រប់រូបទោះកើតមកមានខាន់ស្លាក្តីឬគ្មានខាន់ស្លាក្តីត្រូវទទួលបានការគាំពារសង្គមនេះដូចគ្នា[11]។

[11] សេចក្តីថ្លែងការណ៍ភ្នំពេញ អំពីការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន(ថ្ងៃទី១៨ វិច្ឆិកា ២០១២),អាចរកបាននៅ https://aichr.org/wp-content/uploads/2019/02/Cambodia_-_AHRD_and_PP_Statement.pdf ។

# ជំពូកទី២
# សិទ្ធិនារីនៅប្រទេសកម្ពុជា

# ជំពូកទី២
# សិទ្ធិនារីនៅប្រទេសកម្ពុជា

## ២.១. ស្ថានភាពក្នុងប្រវត្តិសាស្ត្រ

តាមរយៈវប្បធម៌ និងអរិយធម៌ខ្មែរ យើងសង្កេតឃើញថា ស្ត្រីខ្មែរមានតួនាទីសំខាន់ណាស់ក្នុងសង្គមជាតិ។ ស្ត្រីមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ចាប់តាំងពីសម័យនគរភ្នំមកម្ល៉េះ។ ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញពីវីរភាពរបស់ស្ត្រីខ្មែរ ក្នុងការដឹកនាំប្រទេសជាតិតាំងពីសម័យនគរភ្នំ នាសតវត្សទី១។ ក្នុងពេលនោះ ប្រទេសជាតិបានគ្រប់គ្រងដោយស្ដេចស្រីមួយអង្គព្រះនាម **លីវ យី** ឬ **សោមា** ។ ព្រះនាង លីវ យី បានបង្កើតស្ថាប័ននានាដើម្បីជានាស្ថេរភាពនយោបាយ និងសង្គមក្នុងការគ្រប់គ្រងនគរហ្វូណន។

គួរបញ្ជាក់ផងដែរថា របបគ្រប់គ្រងរបស់ព្រះនាងលីវ យី នៅពេលនោះគឺ **របបមាតាធិបតេយ្យ** ជារបបមួយឲ្យតម្លៃទៅលើស្ត្រីជាធំ ជាមេដឹកនាំ ជាមេគំនិតក្នុងការដោះស្រាយបញ្ហាគ្រួសារ និងសង្គមជាតិ។ របបមាតាធិបតេយ្យបានលើកតម្កើងស្ត្រីជាធំ ទាំងក្នុងគ្រួសារ និងក្នុងសង្គមជាតិ ហើយបានទទួលស្គាល់នូវតួនាទី និងសិទ្ធិរបស់ស្ត្រីខ្មែរថែមទៀតផង។ រហូតដល់សម័យអង្គរ(សតវត្សទី៩ ដល់សតវត្សទី១៤) ការផ្ទេររាជសម្បត្តិ គឺធ្វើតាមរយៈខ្សែលោហិតខាងម្ដាយ ហើយទោះជាព្រះមហាក្សត្រខ្លះឡើងសោយរាជ្យតាមរយៈខ្សែលោហិតខាងឪពុកក្ដី ក៏ព្រះអង្គនៅតែអះអាងថា មានជាប់ខ្សែលោហិតខាងម្ដាយជាមួយក្សត្រមុន ឬក៏បានអភិសេកជាមួយបុត្រីព្រះមហាក្សត្រមុនដែរ។ ទាំងនេះ គឺជាការផ្ទេររាជសម្បត្តិតាម **មតេយ្យការ** ។ ចំណុចនេះបញ្ជាក់ថា ស្ត្រីមានអំណាចជាងបុរសនៅក្នុងរាជវង្ស និងបញ្ជាក់ពីតួនាទីបន្ថែមទៀតរបស់ស្ត្រីខ្មែរ ដែលមានលទ្ធភាពដឹកនាំប្រទេសជាតិ មានសេរីភាពធ្វើការដូចបុរសតាំងពីមិនទាន់មានកម្រងឯកសារសិទ្ធិមនុស្សមកម្ល៉េះ។

## ២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តនៅថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានប្រកាសឲ្យប្រើជាផ្លូវការណ៍ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៣។ ក្នុងនោះមានមាត្រាមួយចំនួនចែងទាក់ទងនឹងការលើកកម្ពស់សមភាពរវាងបុរស និងស្ត្រី និងការលុបបំបាត់ការរើសអើងស្ត្រីនៅគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីធ្វើការបកស្រាយឆ្លើយតបទៅនឹងបញ្ហានេះ យើងសូមបង្ហាញមាត្រាដែលពាក់ព័ន្ធដូចតទៅ៖

មាត្រា៣១ វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថាៈ

“ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។... ”

មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថាៈ

“ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល(១)។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់(២)។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ(៣)។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ(៤) ”។

មាត្រា៤៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថាៈ

“អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាក នៅពេលសម្រាលកូនដោយទទួលបានប្រាក់បៀវត្ស និងដោយមានការធានារក្សាអតីតភាពក្នុងការងារ និង អត្ថប្រយោជន៍សង្គមផ្សេងៗទៀត។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ”[12]។

## ២.៣. សេដ្ឋកិច្ច

### ២.៣.១. ស្ត្រី និងអាជីវកម្ម

តាមរយៈឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា(២០១៤-២០១៨)ដោយសារតែនិន្នាការសកលភាវូបនីយកម្ម ស្ត្រីជួបបញ្ហាប្រឈមទៅនឹងការវិវត្តនៃបច្ចេកវិទ្យា។ ដើម្បីធ្វើឲ្យស្ថានភាពស្ត្រីប្រសើរជាងមុននៅក្នុងសេដ្ឋកិច្ច កត្តាចាំបាច់គឺត្រូវកសាងសមត្ថភាពរបស់ស្ត្រីលើការអប់រំ និងបច្ចេកវិទ្យា។

សកលភាវូបនីយកម្ម និងការវិវត្តបច្ចេកវិទ្យាត្រូវបានគេប៉ាន់ស្មានថាមិនអាចបញ្ឈប់បាន និងមានល្បឿនលឿនក្នុងក្របខណ្ឌអាជីវកម្មដែលជះឥទ្ធិពលចំពោះគ្រប់មជ្ឈដ្ឋាន។ បាតុភូតនេះអាចធ្វើឲ្យស្ត្រីដើរថយក្រោយនៅក្នុងប្រតិបត្តិការអាជីវកម្ម ឬចូលរួមនៅក្នុងវិស័យការងារនានា។ ដូច្នេះពត៌មានទាក់ទងទៅនឹងការវិវត្តន៍ទាំងនេះ គួរត្រូវបានបង្ហាញតាមរយៈស្ថិតិយេនឌ័រ ដើម្បីផ្តល់ពត៌មានកាន់តែប្រសើរឡើង សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកតាក់តែងច្បាប់ក្នុងវិធានការឆ្ពោះទៅបង្កើនសមត្ថភាពស្ត្រី និងជម្រុញឲ្យមានស្ត្រីកាន់តែច្រើនចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល។ យ៉ាងណាមិញ មិនទាន់មានការអង្កេតថ្នាក់ជាតិស្តីពីស្ថិតិស្ត្រី និងបុរសនៅក្នុងអាជីវកម្មឌីជីថលនៅឡើយទេ។

[12] អគ្គនាយកដ្ឋានរដ្ឋសភា, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ១៩៩៣) ។

យោងតាមការអង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជាឆ្នាំ២០១៤ សហគ្រាសត្រូវបានបែងចែកជាបីផ្នែកធំៗគឺ៖ សហគ្រាសខ្នាតធំ តូច និងមធ្យម និងសហគ្រាសមីក្រូ។ សហគ្រាសទាំងនោះក៏រួមបញ្ចូលផងដែរនូវសហគ្រាសដែលមានកម្មសិទ្ធិករជាជនជាតិបរទេស និងអង្គការក្រៅរដ្ឋាភិបាល។ តាមរយៈការអង្កេតនេះបានឲ្យដឹងថា ចំនួនសហគ្រាសសរុបមាន ៥១៣,៧៥៩ សហគ្រាស។ ស្ត្រី និងបុរសដែលតំណាងឲ្យសហគ្រាសនីមួយៗត្រូវបានចុះបញ្ជីថាជាម្ចាស់ ឬជាប្រធានសហគ្រាសទាំងនោះ។ អង្កេតចន្លោះជំរឿនសហគ្រាសកម្ពុជានេះបានបង្ហាញថា សហគ្រាសដែលមានចំនួនច្រើនជាងគេបំផុត គឺសហគ្រាសមីក្រូ ដែលមានចំនួន ៥០១,៦១២ បន្ទាប់មក គឺសហគ្រាសខ្នាតូច និងមធ្យម ដែលមានចំនួន ១១,២៥៩ និងតិចជាងគេបំផុត គឺសហគ្រាសខ្នាតធំ ដែលមានចំនួន ៨៨៩សហគ្រាស[13]។

**២.៣.១.១. ស្ត្រីនៅក្នុងវិស័យកាត់ដេរ**

**ក. កម្ចីប្រាក់ឥណទាន**

កម្មករ កម្មការិនីនៃវិស័យកាត់ដេរក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងរងគ្រោះយ៉ាងធ្ងន់ធ្ងរពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលបណ្ដាលមកពីការរីករាលដាលនៃវីរុសកូវីដ-១៩។ ដោយសារកម្មករ កម្មការិនីនៅក្នុងវិស័យមួយនេះនៅតែទទួលបានប្រាក់ខែតិចអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ ទើបជម្រុញឲ្យពួកគាត់ពឹងផ្អែកលើការខ្ចីប្រាក់ដើម្បីជួយផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ដែលភាគច្រើននៃប្រាក់កម្ចីទាំងនេះ គឺផ្ដល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយត្រូវដាក់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លីរបស់ម្ចាស់ទ្រព្យដើម្បីជាទ្រព្យធានា។

កម្មករ កម្មការិនីរាប់សែននាក់ដែលកំពុងជំពាក់បំណុលគេយ៉ាងច្រើន បានបាត់បង់ការងារជាបន្តបន្ទាប់ក្រោយពីរោងចក្រកាត់ដេររាប់រយរោងចក្របានផ្អាកដំណើរការ។ បញ្ហានេះធ្វើឲ្យពួកគាត់ប្រឈមនឹងហានិភ័យនៃការបាត់បង់ដីធ្លី និងការរំលោភសិទ្ធិមនុស្សដទៃទៀត។ វិស័យមួយនេះក៏បានទទួលរងផលប៉ះពាល់ដោយសារការសម្រេចដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើទំនិញគ្រប់មុខលើកលែងតែសព្វាវុធ(EBA) កាលពីខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅនេះផងដែរ។ សេចក្ដីសម្រេចនេះធ្វើឡើងបន្ទាប់ពី សហភាពអឺរ៉ុបដែលជាទិសដៅនាំចេញធំបំផុតមួយរបស់វិស័យកាត់ដេរនេះ បានរកឃើញថា “*មានការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធនៅប្រទេសកម្ពុជា*”។

លទ្ធផលនៃការស្រាវជ្រាវនេះ បានមកពីការស្ទង់មតិទៅលើកម្មករ កម្មការិនីកាត់ដេរចំនួន១៦២នាក់(ស្ត្រី ១៥៨នាក់) ហើយការស្ទង់មតិនេះធ្វើឡើងនៅចន្លោះខែមីនា និងខែឧសភា ឆ្នាំ២០២០។ កម្មករ កម្មការិនីដែលបានចូលរួមក្នុងការសិក្សានេះ មកពីរោងចក្រកាត់ដេរចំនួនបីផ្សេងគ្នា ដែលរោងចក្រខ្លះបានព្យួរការងារដោយ

[13] អគ្គលេខាធិការដ្ឋានរដ្ឋសភា, បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ: លទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ ។

ផ្នែក និងខ្លះទៀតបានព្យួរការងារទាំងស្រុង។ អ្នកស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ពីរភាគបី(២/៣) នៃកម្មករ កម្មការិនី ត្រូវបានសងកម្ចីឥណទានយ៉ាងតិចណាស់ក៏មួយកន្លែងដែរ។ ពួកគាត់ត្រូវយកប្រាក់ចំណូលភាគច្រើនដែលរកបាននៅមុនពេលព្យួរការងារ ដើម្បីសងកម្ចីឥណទានទាំងនេះ។ គិតជាមធ្យម ចំនួនប្រាក់បង់សងបំណុល និងប្រាក់សម្រាប់ចំណាយលើថ្លៃម្ហូបអាហារប្រចាំខែ មានចំនួនច្រើនជាងប្រាក់ខែរបស់ពួកគាត់ទៅទៀត ដូច្នេះពួកគាត់ត្រូវកាត់បន្ថយការចំណាយលើថ្លៃម្ហូបអាហារ ដើម្បីសន្សំប្រាក់ទុកបង់សងបំណុលវិញ។ ៩៦ ភាគរយនៃអ្នកផ្តល់បទសម្ភាសន៍ដែលជាប់ជំពាក់បំណុលឥណទានខ្នាតតូចបាននិយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "លំបាកខ្លាំង"(៨០ភាគរយ) ឬ "លំបាកតិចតួច"(១៦ភាគរយ) នៅពេលបច្ចុប្បន្ន បើប្រៀបធៀបទៅនឹងពេលដែលពួកគាត់មិនទាន់ជាប់ជំពាក់កម្ចីឥណទានខ្នាតតូច។ អ្នកផ្តល់បទសម្ភាសន៍ត្រឹមតែ ២ភាគរយប៉ុណ្ណោះដែលនិយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "ប្រសើរជាងមុនបន្តិច" និងគ្មានអ្នកណាម្នាក់និយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "ប្រសើរខ្លាំង" នោះទេ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជកម្ម និងដៃគូវិនិយោគ ដែលភាគច្រើនគឺជាទីភ្នាក់ងារអភិវឌ្ឍន៍ ឬជាធនាគាររដ្ឋរបស់ប្រទេសនៅទ្វីបអឺរ៉ុប គឺជាអ្នកទទួលខុសត្រូវចំពោះការជំពាក់បំណុលច្រើនលើសលប់ស្ទើរតែគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា។ ស្ថាប័នទាំងនេះ នៅតែបន្តផ្តល់មូលនិធិដើម្បីពង្រីកយ៉ាងគំហុកនូវវិស័យឥណទានខ្នាតតូច និងទំហំកម្ចីផលប័ត្រឥណទាន បើទោះបីជាអ្នកសេដ្ឋកិច្ច និងអង្គការសិទ្ធិមនុស្សធ្លាប់បានព្រមានពីការផ្តល់ប្រាក់កម្ចីច្រើនហួសហេតុ និងការរំលោភបំពាននៅក្នុងវិស័យនេះក៏ដោយ។ គិតត្រឹមបំណាច់ឆ្នាំ២០១៩ ប្រជាពលរដ្ឋកម្ពុជាជាង ២លាន ៦សែននាក់ កំពុងជាប់កម្ចីឥណទានខ្នាតតូចជាង១០ពាន់លានដុល្លារ ជាមួយនឹងអត្រាកម្ចីជាមធ្យម ៣.៨០៤ដុល្លារ ដែលជាចំនួនច្រើនជាងគេនៅលើពិភពលោក និងខ្ពស់ជាងផលិតផលសរុបក្នុងស្រុក(GDP) ឬចំណូលប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់។

នៅក្នុងកំឡុងពេលនៃការរីករាលដាលនៃវីរុសកូវីដ-១៩ ដៃគូអភិវឌ្ឍន៍គួរអនុវត្តកម្មវិធីសម្រាលបន្ទុកបំណុលដល់ប្រជាពលរដ្ឋកម្ពុជាដែលកំពុងជួបការលំបាក។ ផ្ទុយទៅវិញ ដៃគូអភិវឌ្ឍន៍ទាំងនេះ បែរជាបន្តពង្រីកវិស័យឥណទានខ្នាតតូច ដែលមានទំហំធំហួសហេតុស្រាប់ទៅវិញ។

គោលបំណងនៃការផ្តល់មូលនិធិនេះ គឺដើម្បីលើកកម្ពស់ឱកាសទទួលបានហិរញ្ញវត្ថុដល់ស្ត្រីនៅកម្ពុជា។ ប៉ុន្តែអ្វីដែលប្រជាពលរដ្ឋកម្ពុជាអ្នកខ្ចីប្រាក់ត្រូវការនាពេលបច្ចុប្បន្ននេះ គឺកម្មវិធីសម្រាលបន្ទុក មិនមែនជាទឹកប្រាក់រាប់លានដុល្លារដែលប្រើសម្រាប់បង្កើនប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលភាគច្រើន ជាកម្មសិទ្ធិរបស់ជនបរទេស ដើម្បីពង្រីកទំហំផលប័ត្រឥណទានរបស់ខ្លួននោះឡើយ។

ការស្រាវជ្រាវនេះមិនបានរកឃើញភស្តុតាងណាមួយ ដែលគាំទ្រនូវការអះអាងថា ឥណទានខ្នាតតូចចូលរួមជួយបង្កើនប្រាក់ដំណូលរបស់អ្នកខ្ចីប្រាក់នោះទេ។ ហេតុផលចម្បងដែលគេជំពាក់ប្រាក់កម្ចីឥណទានគឺ

ដើម្បី "សង់ផ្ទះ" ដើម្បី "សងបំណុល" និងដោយសារ "ហេតុផលផ្សេងៗ" (ភាគច្រើន គឺយកទៅទិញទ្រព្យសម្បត្តិដូចជាម៉ូតូ ឬដីធ្លីជាដើម)។ ការខ្ចីប្រាក់ឥណទាន "ដើម្បីធ្វើអាជីវកម្ម" និង "ដើម្បីព្យាបាលជំងឺ" និង "ដើម្បីធ្វើកសិកម្ម" មានតិចតួចបំផុត។ ការរកឃើញនេះ បានចោទជាសំណួរថា តើមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប៉ុន្មានភាគរយ ដែលមិនតម្រូវថា កម្ចីឥណទាន គឺផ្ដល់សម្រាប់យកទៅប្រើប្រាស់ដើម្បីបង្កើនប្រាក់ចំណូល ប៉ុន្តែបែរជាពឹងផ្អែកលើសុវត្ថិភាពប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លីរបស់អ្នកខ្ចី ដើម្បីធានាការបង់សងកម្ចីឥណទានត្រលប់មកវិញ។ កម្មករ កម្មការិនីរោងចក្រ ១៦នាក់ ដែលជាអ្នកជំពាក់ឥណទានខ្នាតតូចបានលក់ដីរបស់ពួកគាត់ដើម្បីសងបំណុល ហើយកម្មករ កម្មការិនី ៣៣នាក់ផ្សេងទៀត គ្រោងនឹងលក់ដីដើម្បីសងបំណុលនៅក្នុងពេលឆាប់ៗខាងមុខនេះ។

វិធីសាស្ត្រផ្សេងទៀតដែលកម្មករ កម្មការិនីតែងអនុវត្ត ដើម្បីសន្សំប្រាក់ទុកបង់សងកម្ចីឥណទាន រួមមានកាត់បន្ថយចំណាយលើថ្លៃម្ហូបអាហារ ការខ្ចីប្រាក់បន្ថែម និងការធ្វើចំណាកស្រុកដើម្បីរកការងារធ្វើជាដើម។ កម្មករ កម្មការិនី ដែលផ្ដល់បទសម្ភាសន៍ភាគច្រើននិយាយថា ពួកគាត់នឹងអនុវត្តវិធីសាស្ត្របែបនេះនៅពេលខាងមុខ ដែលការអនុវត្តបែបបនេះធ្វើឲ្យពួកគាត់ប្រឈមនឹងហានិភ័យកាន់តែខ្ពស់។ វិបត្តិសិទ្ធិមនុស្សនេះនឹងកាន់តែធ្ងន់ធ្ងរឡើង ប្រសិនបើគ្រឹស្ថានមីក្រូហិរញ្ញវត្ថុ នៅតែបន្តធ្វើឲ្យពួកគាត់ប្រឈមនឹងការរងសម្ពាធផ្នែកសេដ្ឋកិច្ចនេះ។

**ខ. កម្ចីប្រាក់ឯកជនក្រៅផ្លូវការណ៍**

ក្រៅពីជាប់ជំពាក់កម្ចីឥណទានខ្នាតតូច កម្មករ កម្មការិនីរោងចក្រ ដែលចូលរួមក្នុងការស្ទង់មតិនេះ ក៏បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ឬសាច់ញាតិ ទោះបីករណីបែបនេះពុំសូវមានច្រើនដូចឥណទានក្ដី។

ប្រាក់កម្ចីក្រៅផ្លូវការណ៍ទាំងនេះ មានទំហំតូចជាងកម្ចីឥណទាន និងជាទូទៅមិនទាមទារឲ្យមានទ្រព្យធានានោះទេ ហើយអ្នកខ្ចីភាគច្រើនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបំណុលប្រភេទនេះ។ លើសពីនេះទៅទៀត មូលហេតុទូទៅនៃការចងការប្រាក់ឯកជន គឺដើម្បីយកទៅ "បង់សងបំណុលដែលមានស្រាប់" ដែលមូលហេតុនេះបង្ហាញឲ្យឃើញថា អ្នកជំពាក់ប្រាក់កម្ចីជាញឹកញាប់ត្រូវចងការប្រាក់ឯកជនដើម្បសងកម្ចីឥណទានផ្លូវការណ៍។ ជាការពិត មូលហេតុសំខាន់ជាងគេនៃការចងការប្រាក់ឯកជន នៅក្នុងទម្រង់ណាក៏ដោយ គឺដើម្បីយកទៅសងបំណុលដែលមានស្រាប់ ដែលការអនុវត្តបែបនេះបង្ហាញឲ្យឃើញថា ទីផ្សារឥណទាននៅក្នុងប្រទេសកម្ពុជាមានបរិមាណធំហួសហេតុគួរឲ្យព្រួយបារម្ភ។

បំណុលមីក្រូហិរញ្ញវត្ថុទំនងជាកត្តាជម្រុញបន្ថែម ឲ្យអ្នកខ្ចីប្រាក់កាន់តែពឹងផ្អែកលើអ្នកចងការប្រាក់ឯកជនមិនផ្លូវការណ៍ ដែលផ្ទុយពីការអះអាងរបស់អ្នកផ្តល់កម្ចីឥណទានខ្នាតតូច[14]។

## ២.៤. ស្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ

កម្ពុជាសម្រេចបានស្នាដៃគួរកត់ឲ្យសម្គាល់ចាប់ពីនីតិកាលទី១នៃរដ្ឋសភា ដល់នីតិកាលទី៦។ យោងទៅតាមរបាយការណ៍គម្លាតយេនឌ័រពិភពលោកឆ្នាំ២០២០ ដែលចេញផ្សាយដោយវេទិការសេដ្ឋកិច្ចពិភពលោក គម្លាតយេនឌ័រកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទី៨៩ ក្នុងចំណោមប្រទេស១៥៣ ក្នុងឆ្នាំ២០១៩។ ក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះ ការដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅកម្ពុជាទទួលបានលទ្ធផលជាវិជ្ជមានដោយកម្ពុជាធ្លាប់ជាប់ចំណាត់ថ្នាក់ហូតដល់ទី១០៨។ ប៉ុន្តែយ៉ាងណាមិញ ការចូលរួមរបស់ស្ត្រីនៅក្នុងការពង្រឹងភាពអង់អាចខាងនយោបាយ គឺឈរនៅលំដាប់ថ្នាក់ទី១១៩ ក្នុងចំណោម១៥៣ប្រទេស ដែលទាមទារឲ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ចធ្វើការសហការគ្នាដើម្បីឲ្យស្ថានភាពស្ត្រីនៅក្នុងវិស័យនយោបាយបានល្អប្រសើរឡើង[15]។

សភាកម្ពុជាបានអនុម័តប្រព័ន្ធសភាពីរ ដែលមានព្រឹទ្ធសភា និងរដ្ឋសភា។ រដ្ឋសភា ជាស្ថាប័នជាប់ឆ្នោតដែលមានអាណត្តិ៥ឆ្នាំ រីឯព្រឹទ្ធសភា មានអាណត្តិ៦ឆ្នាំ។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជា រដ្ឋសភាមានសមាជិកយ៉ាងតិច ១២០រូប។ សមាជិករដ្ឋសភាទាំងអស់តំណាងឲ្យប្រជាពលរដ្ឋកម្ពុជាទាំងមូល មិនកំណត់ត្រឹមតែជាតំណាងឲ្យពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនប៉ុណ្ណោះទេ។ រដ្ឋធម្មនុញ្ញកម្ពុជាក៏បានបញ្ជាក់ផងដែរថា សមាជិកព្រឹទ្ធសភាត្រូវមានពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភា ដែលសមាជិក២រូប តែងតាំងដោយព្រះមហាក្សត្រ និង ២រូបទៀតត្រូវជ្រើសតាំងដោយរដ្ឋសភា។

### ២.៤.១. ស្ត្រីនៅក្នុងស្ថាប័នព្រឹទ្ធសភា

នៅក្នុងនីតិកាលទី៤(២០១៨-២០២៤)ចំនួនសមាជិកព្រឹទ្ធសភាសរុបមាន៦២រូប ក្នុងនោះមានសមាជិកជាស្ត្រីចំនួន១០រូប។

ចំនួនស្ត្រីនៅក្នុងព្រឹទ្ធសភាមានការកើនឡើង១ភាគរយក្នុងរយៈពេល២ទសវត្សរ៍។ ក្នុងអាណត្តិទី១(១៩៩៩-២០០៦)ស្ត្រីមានចំនួន១៥ភាគរយ ហើយក្នុងអាណត្តិទី៤(២០១៨-២០២៤) ស្ត្រីមានចំនួន១៦ភាគរយ។ ទិន្នន័យនេះអាចសន្និដ្ឋានបានថា ចំនួនស្ត្រីនៅក្នុងព្រឹទ្ធសភានៅតែមានការផ្លាស់ប្តូរ ដែលទំនងជាត្រូវ

[14] សហព័ន្ធសហជីពកម្ពុជា, ធ្វើការងាររហូតដំពាក់បំណុលវ័ណ្ឌកៈ ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា (ឆ្នាំ២០២០) ។

[15] អគ្គលេខាធិការដ្ឋានរដ្ឋសភា, បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំៈ លទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ។

ធ្វើការពិនិត្យឡើងវិញទៅលើគោលនយោបាយ និងយន្តការដែលមានស្រាប់ក្នុងការជម្រុញ និងទាក់ទាញស្ត្រីឲ្យចូលរួមកាន់តែច្រើននៅក្នុងស្ថាប័នព្រឹទ្ធសភា និងការបោះឆ្នោតនាអាណត្តិខាងមុខ។

### ២.៤.២. ស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភា

នៅក្នុងនីតិកាលទី៦នេះ រដ្ឋសភាមានសមាជិកចំនួន១២៥រូប ក្នុងនោះដែរមានស្ត្រីចំនួន២៦រូប។ ចំនួនសមាជិកសភាស្ត្រីមានការកើនឡើងគួរឲ្យកត់សម្គាល់ ប្រមាណ៦ភាគរយក្នុងអាណត្តទី១ ដល់ ២១ភាគរយនៅក្នុងអាណត្តិទី៦។ គួរឲ្យកត់សម្គាល់ផងដែរថា ចំនួនស្ត្រីកាន់តែច្រើនដែលកំពុងកាន់តួនាទីខ្ពស់នៅក្នុងរដ្ឋសភាបើប្រៀបធៀបទៅនឹងអាណត្តិទី១។ ជាក់ស្តែងមានស្ត្រី១រូបជាអនុប្រធានរដ្ឋសភា ២រូបជាគណៈកម្មាធិការ និង៤រូបទៀតជាអនុប្រធានគណៈកម្មការ។

## ២.៥. ស្ត្រីនៅក្នុងស្ថាប័ននីតិប្រតិបត្តិ

តំណាងស្ត្រីនៅក្នុងតួនាទីជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាលនៅមានកម្រិតទាបក្នុងឆ្នាំ២០១៩។ តួនាទីជាអនុរដ្ឋលេខាធិការឈរនៅលំដាប់ខ្ពស់ជាងគេបំផុតបើប្រៀបធៀបនឹងមុខដំណែងផ្សេងៗទៀត ដែលរួមមានស្ត្រី៥៥ភាគរយក្នុងចំណោមស្ត្រីទាំងអស់ និងបុរស៥២ភាគរយនៃបុរសទាំងអស់។ រដ្ឋលេខាធិការ គឺជាតំណែងខ្ពស់ទី២ ដែលមានស្ត្រីចំនួន៤២ភាគរយក្នុងចំណោមស្ត្រីទាំងអស់ និងបុរស៤១ភាគរយនៃបុរសទាំងអស់។ យ៉ាងណាមិញ ប្រសិនបើយើងធ្វើការប្រៀបធៀបចំនួនស្ត្រី និងបុរសដែលមានមុខដំណែងដូចគ្នា នោះយើងនឹងឃើញថាវាមានគម្លាតខ្លាំង។

អត្រាស្ត្រីមានចំនួនតិចជាង២០ភាគរយនៅក្នុងមុខតំណែងនីមួយៗបើធៀបទៅនឹងបុរស ម៉្យាងវិញទៀតពុំទាន់មានស្ត្រីណានៅក្នុងតំណែងជាទេសរដ្ឋមន្ត្រីនៅឡើយទេ។

## ២.៦. ស្ត្រីនៅក្នុងស្ថាប័នតុលាការ

តុលាការនៅកម្ពុជាចែកជាបីកម្រិតគឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប្រទេសកម្ពុជាមានតុលាការពិសេសមួយទៀតគឺ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តុលាការនេះមានតួនាទីសម្រាប់កាត់ក្តីលើករណីប្រល័យពូជសាសន៍ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

ផ្នែកនេះនឹងបង្ហាញពីទិន្នន័យចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងទិន្នន័យមេធាវីដែលបានកត់ត្រាទុកដោយគណៈមេធាវីកម្ពុជា។ លើសពីនេះ តួនាទីអាជ្ញាសាលាត្រូវបានកត់ត្រាផ្លូវការណ៍នៅឆ្នាំ២០១៦ ដូច្នេះទើបទិន្នន័យនេះត្រូវបានលើកយកមកបង្ហាញដោយឡែក។ គួរបញ្ជាក់ផងដែរថា អាជ្ញាសាលាសរុបគិតតាំងពីការកត់ត្រាដំបូងដល់ឆ្នាំ២០១៩ នៅមានចំនួនដដែលគឺមាន ២៧រូប ដែលមានស្ត្រី២រូប។ ទន្ទឹមនេះដែរ ចំនួនសាការីសរុបមាន ៦៦រូប មានស្ត្រី៨រូប ស្មើនឹង១២ភាគរយ។

ស្ត្រីមានតួនាទីជាចៅក្រម មានចំនួន១៤ភាគរយក្នុងឆ្នាំ២០១៣ និងមានកើនដល់១៥ភាគរយក្នុងឆ្នាំ ២០១៩។ រីឯមេធាវីស្ត្រី មានការកើនឡើងគួរឲ្យកត់សម្គាល់ ពី១៨ភាគរយក្នុងឆ្នាំ២០១៣ ដល់ ២២ភាគរយក្នុង ឆ្នាំ២០១៩។ ដោយឡែកចំនួនមេធាវីសរុបមានការកើនឡើងខ្ពស់ជាងមុនទ្វេរដង ពី៨៦៦នាក់ក្នុងឆ្នាំ២០១៣ ដល់ ២.០៥០នាក់ក្នុងឆ្នាំ២០១៩។ បើប្រៀបធៀបទៅនឹងវិជ្ជាជីវៈខាងលើ តួនាទីក្រឡាបញ្ជីមានស្ត្រីច្រើនជាងគេ ប្រមាណ ២២ភាគរយក្នុងឆ្នាំ២០១៣ និង ២៣ភាគរយក្នុងឆ្នាំ២០១៩។

យើងអាចសន្និដ្ឋានបានថា ការចូលរួមរបស់ស្ត្រីក្នុងស្ថាប័នតុលាការនៅមានកម្រិតទាបក្នុងរយៈពេល៧ ឆ្នាំនេះ ដែលគួរតែត្រូវបានគិតគូរសិក្សាបន្ថែមទៀតនាពេលក្រោយ។ អាចជាការសិក្សាស្វែងយល់អំពីទស្សនៈ របស់ស្ត្រី និងបុរសចំពោះវិជ្ជាជីវៈច្បាប់ ឬស្វែងយល់ពីដំណើរការនៃការប្រកាសជ្រើសរើសឲ្យធ្វើការនៅក្នុងមុខ តំណែងទាំងនោះ ដើម្បីអាចដឹងថា តើត្រូវធ្វើយ៉ាងណាដើម្បីឲ្យការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យច្បាប់កាន់តែ ប្រសើរ។

## ២.៧. ស្ត្រី និងបុរសជាមន្ត្រីរាជការ

ដោយពិនិត្យឃើញចំនួនស្ត្រីក្នុងវិស័យនយោបាយ និងថ្នាក់ជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលនៅមានចំនួនទាប រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងមុខងារសាធារណៈ បានចេញសេចក្តីណែនាំដើម្បីកំណត់ចំនួនស្ត្រីចូល បម្រើការជាមន្ត្រីសាធារណៈ ដោយត្រូវបញ្ចូលស្ត្រីប្រមាណពី២០ ទៅ ៥០ភាគរយ នៅក្នុងការប្រលងជ្រើសរើស មន្ត្រីរាជការប្រចាំឆ្នាំនៅតាមស្ថាប័នសាធារណៈ។

ជាការពិតណាស់ ចំនួនមន្ត្រីរាជការជាបុរសមានច្រើនជាងស្ត្រី ប៉ុន្តែស្ត្រីដែលត្រូវបានជ្រើសរើសមានការ កើនឡើងពី៣២ភាគរយ ស្មើនឹង(៥៧,១១៤រូប)ក្នុងឆ្នាំ២០១៧ ដល់ ៤១ភាគរយ ស្មើនឹង(៨៩,៥៣២រូប)ក្នុងឆ្នាំ ២០១៩

## ២.៨. ស្ត្រី និងបុរសនៅថ្នាក់ក្រោមជាតិ

### ២.៨.១. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គណៈអភិបាលត្រូវបានបង្កើតឡើងនៅថ្នាក់ក្រោមជាតិទាំងអស់ ថ្នាក់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានស្ត្រីចំនួន៤ភាគរយ(១រូប) នៃមុខតំណែងអភិបាលខេត្តក្នុងឆ្នាំ២០១៩ និងតំណែងជាអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួន៣ភាគរយ(៦រូប)។ អត្រាស្ត្រីហាក់មានចំនួនខ្ពស់ក្នុងមុខដំណែងទាប។ តំណាងស្ត្រី អភិបាលសរុបជាភាគរយនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី៤ភាគរយក្នុងឆ្នាំ២០០៧ ដល់ ២០ភាគរយ ក្នុងឆ្នាំ២០១៩ បើប្រៀបធៀបនឹងបុរស។

### ២.៨.២. ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មានអាណត្តិ៥ឆ្នាំ អាណត្តិនៃក្រុមប្រឹក្សានឹងចាប់ផ្តើមពីថ្ងៃបោះឆ្នោត និងចប់នៅថ្ងៃក្រុមប្រឹក្សាបានជ្រើសតាំង ក្រុមប្រឹក្សាបោះឆ្នោតដោយប្រយោល សេរី និងស្មើភាពគ្នាដោយសម្ងាត់។

ភាពជាតំណាងស្ត្រីបានកើនឡើងយ៉ាងស្តួចស្តើងពី១២ភាគរយ ទៅ ១៧ភាគរយ[16]។

### ២.៨.៣. ការបោះឆ្នោតឃុំ-សង្កាត់

#### ២.៨.៣.១. ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២

ស្ត្រីដែលបានចូលរួមក្នុងនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ កន្លងមក ត្រូវបានរកឃើញថា នៅមានភាពប្រឈមរាប់ចាប់ពីមានការចូលរួមបោះឆ្នោត ឱកាសក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត។ តាំងពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់២០០២ មានការកើនឡើងចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ជាបន្តបន្ទាប់ ជាពិសេសស្ត្រីក្នុងកិច្ចការនយោបាយ និងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។

រាប់ចាប់ពីឆ្នាំ២០០២ នៃការចាប់ផ្តើមអនុវត្តគោលនយោបាយវិមជ្ឈការរបស់ប្រទេសកម្ពុជាតាមរយៈការបោះឆ្នោត ស្ត្រីចូលរួមក្នុងនយោបាយ និងស្ត្រីជាប់ឆ្នោតនៅតែមានការកើនឡើងតិចតួចបើគិតត្រឹមពាក់កណ្តាលឆ្នាំ២០១២។ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តទី១(២០០២-២០០៧) ក្នុងចំណោមអាសនៈក្រុមប្រឹក្សាឃុំ-សង្កាត់សរុប ១១,២៦១អាសនៈ(១៦២១ ឃុំ-សង្កាត់) ស្ត្រីនៅចុងអាណត្តិមានសរុប ៨.៧២ភាគរយ ហើយនៅចុងអាណត្តិទី២(២០០៧-២០២) ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់កើនដល់ ១៦.៨ភាគរយ នៃអាសនៈសរុប ១១,៣៥៣អាសនៈ។ តាមលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣(ឆ្នាំ២០១២-២០១៧)ដែលបានប្រកាសជាផ្លូវការដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ មានស្ត្រីប្រមាណ២,០៣៨នាក់(ស្មើនឹង ១៧.៧៨ភាគរយ) បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ស្ត្រីអាណត្តិទី៣ ក្នុងចំណោមមន្ត្រីជាប់ឆ្នោតទាំងបុរស-ស្ត្រីសរុប ១១,៤៥៩នាក់(១៦៣៣ ឃុំ-សង្កាត់)។ តួលេខនេះបង្ហាញថា កម្ពុជាមានការប្រឈមមុខក្នុងការធ្វើឲ្យបានសម្រេចតាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា(CMDG) ដែលកម្ពុជាបានកំណត់ថា នៅឆ្នាំ២០១៥ មន្ត្រីជាប់ឆ្នោតស្ត្រីនៅឃុំ-សង្កាត់យ៉ាងតិច២៥ភាគរយ។

ការកើនឡើងចំនួនស្ត្រីក្នុងកិច្ចការនយោបាយនេះ ដោយសារមានការខិតខំរួមចំណែកពីគណបក្សនយោបាយ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ សហគមន៍អន្តរជាតិ ក្នុងការបង្កើនសមត្ថភាព និងគាំទ្រស្ត្រី។ ម្យ៉ាងទៀត សង្គមកម្ពុជាក៏មានការកែប្រែឥរិយាបថខ្លះក្នុងការមិនរើសអើងប្រឆាំងនឹងស្ត្រី។ មុន

[16] អគ្គលេខាធិការដ្ឋានរដ្ឋសភា, បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំៈ លទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ និងមុនការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត លោកនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវទៅគណបក្សនយោបាយ ដាក់ស្ត្រីឈរឈ្មោះបោះឆ្នោតនៅលេខរៀងខាងលើ។ ប៉ុន្តែការប្រឈមរបស់ស្ត្រីក៏បន្តនៅមានក្នុងការចូលរួមបោះឆ្នោត និងកិច្ចការនយោបាយ[17]។

**២.៨.៣.២. ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០២២**

អង្គការខុមហ្រ្វែល បានសហការជាមួយអង្គការសីលការកម្ពុជា អង្គការហ្គេតស៊ី(GADC) អង្គការបន្ទាយស្ត្រី និងគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ដើម្បីរៀបចំសន្និសីទសារព័ត៌មានស្តីពីលទ្ធផលអង្កេតចំនួនបេក្ខជនស្ត្រី និងស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២។

បើតាមទិន្នន័យផ្តល់ដោយអង្គការទាំងនោះ នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់អាណត្តិទី៥ ដែលធ្វើឡើងកាលពីដើមខែមិថុនា មេឃុំចៅសង្កាត់ជាប់ឆ្នោតជាស្ត្រីមាន១៧៣នាក់ គឺស្មើ១០,៤៧ភាគរយតែប៉ុណ្ណោះនៃមេឃុំចៅសង្កាត់សរុបចំនួន ១.៦៥២នាក់នៅទូទាំងប្រទេស។ នៅក្នុងអាណត្តិទី៤ មេឃុំចៅសង្កាត់ជាស្ត្រី មានចំនួន១៤១នាក់ គឺស្មើនឹង៨,៥៧ភាគរយ។

នៅក្នុងអាណត្តិទី៥នេះ ចំនួនស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មកពីខាងគណបក្សប្រជាជនកម្ពុជា មានប្រមាណ២៥ភាគរយ នៃចំនួនក្រុមប្រឹក្សាឈ្នះឆ្នោតសរុបចំនួន ៩.៣៧៦នាក់។ ចំណែកគណបក្សភ្លើងទៀន ដែលជាគណបក្សប្រឆាំងទទួលសំឡេងច្រើនបន្ទាប់ មានចំនួនស្ត្រីប្រមាណ៩ភាគរយ នៃចំនួនក្រុមប្រឹក្សាឈ្នះឆ្នោតសរុបចំនួន២.១៩៨នាក់។

នៅក្នុងសន្និសីទសារព័ត៌មាន អ្នកស្រី សេង រាសី នាយិកាប្រតិបត្តិនៃអង្គការសីលការ បានថ្លែងថា បើប្រៀបធៀបកំណើនស្ត្រីរវាងអាណត្តិទី៤និងទី៥ មានតែប្រមាណ២ភាគរយប៉ុណ្ណោះ។ អ្នកស្រីបារម្ភអំពីការមិនសម្រេចបានទៅតាមការប្តេជ្ញាចិត្តសម្រាប់សមភាពយេនឌ័រនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងឆ្នាំ ២០៣០។

អ្នកស្រីបញ្ជាក់ថា៖ *"សំណួរសួរមកវិញថារយៈពេល៥ឆ្នាំហើយ ហេតុអីបានការកើនឡើងមានតិច? ការកើនឡើងតិចតួចបែបនេះ ហើយប្រសិនបើកម្ពុជាឈានឆ្ពោះទៅរកគោលដៅប្រកបដោយចីរភាពក្នុងឆ្នាំ២០៣០ ហើយប្រសិនបើ៥ឆ្នាំឡើងតែ២ភាគរយ សួរថា ២០២៣ យើងនឹងទទួលបានទិន្នន័យដែលមានភាពស្មើគ្នាឬភាពជាតំណាងរបស់ស្ត្រីនៅក្នុងជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នេះ តំណាងឲ្យប្រជាពលរដ្ឋជាស្ត្រីជាង៥០ភាគរយនឹងសម្រេចបានឬយ៉ាងណា"?*

[17] ខុមហ្វ្រែល, *ស្ត្រីចូលរួមនយោបាយក្នុងការបោះឆ្នោត*, https://comfrel.org/wp-content/uploads/2018/03/412_905455Women_in_Election_2012_KH.pdf ។

បើតាមអ្នកស្រី សេង រាសី កាលពីអាណត្តិទី៥ កម្ពុជាមានឃុំ-សង្កាត់ដែលមិនមានស្ត្រីជាក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ២០៩ឃុំ-សង្កាត់។ អ្នកស្រីបន្ថែមថា អង្គការពាក់ព័ន្ធនឹងសិក្សាបន្ថែមទៀតថាតើឃុំ-សង្កាត់ចំនួន ២០៩ មានការប្រែប្រួលយ៉ាងដូចម្តេចសម្រាប់អាណត្តិទី៥នេះ។

បន្ថែមពីការជម្រុញគណបក្សនយោបាយឲ្យមានការដាក់ស្ត្រីជាបេក្ខជនឈរឈ្មោះលេខរៀងខាងលើ ដើម្បីមានឱកាសជាប់ឆ្នោត អង្គការសង្គមស៊ីវិលក៏បានស្នើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ត្រង់មាត្រា៣៥ នៃជំពូកទី៦ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា២៧ និងមាត្រា២៨ នៃជំពូកទី៤ ស្តីពីការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត។ វិសោធនកម្មច្បាប់ទាំងពីរនេះធ្វើឡើងក្នុងគោលបំណងឲ្យមានការធានានូវបេក្ខភាពស្ត្រីត្រូវបានឈរឈ្មោះក្នុងន័យធានានូវសមភាពរវាងបេក្ខភាពស្ត្រី និងបុរសក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ។

អ្នកស្រី សឺនកេត សិរីលក្ខណ៍ កត់សម្គាល់ថា រចនាសម្ព័ន្ធនៃអំណាច ឬការកាន់តួនាទីរដ្ឋតាំងពីថ្នាក់ក្រោមដល់ថ្នាក់ជាតិ ចាប់ពីមេឃុំ រដ្ឋមន្ត្រី ដល់ប្រធានសភា គឺភាគច្រើនជាបុរស ហើយពួកគេមិនចង់ចុះចេញពីតំណែង។ អ្នកស្រីជម្រុញឲ្យមានវិសោធនកម្ម ដើម្បីធានាចំនួនស្ត្រីក្នុងការចូលរួមវិស័យនយោបាយ។

អ្នកស្រីថ្លែងថា៖ *"យើងនៅតែចង់ឲ្យអ្នកពាក់ព័ន្ធសំខាន់ៗហ្នឹង គិតគូរអំពីរឿងធ្វើវិសោធនកម្មបោះឆ្នោត ដើម្បីឆ្លើយតបនឹងយេនឌ័រ ដើម្បីឲ្យស្ត្រីចូលរួមដោយស្មើភាពជាមួយបុរស ជាពិសេសទាក់ទងនីតិវិធីនៃការដាក់បេក្ខជនឆ្លាស់គ្នាស្រីប្រុសៗហ្នឹង ទើបស្ត្រីអាចមានឱកាសបានជាប់ឆ្នោត។ ហើយចុងក្រោយ គឺនៅតែត្រូវការការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំទាំងគណបក្សនយោបាយ ទាំងរដ្ឋាភិបាល។ ការប្តេជ្ញាចិត្តខ្ពស់ គឺសំខាន់មែនទែន"* ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ថ្លែងថាគណបក្សកាន់អំណាចបានយកចិត្តទុកដាក់លើការបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសធនធានស្ត្រីឲ្យចូលរួមវិស័យនយោបាយ ប៉ុន្តែលោកថាលក្ខណៈសម្បត្តិរបស់ស្ត្រីដូចជា ចំណេះដឹង និងបទពិសោធន៍ការងាររបស់ស្ត្រី គឺមិនទាន់បានឆ្លើយតបតាមតម្រូវការជាក់ស្តែងគ្រប់គ្រាន់នៅឡើយ ដែលជាហេតុធ្វើឲ្យសមាសភាពស្ត្រីក្នុងជួរនយោបាយនៅមានកម្រិត ឬនៅក្រោមបុរស។

លោកថ្លែងថា៖ *"យើងមិនមែនទូងស្គរ ដើម្បីបញ្ចូលស្ត្រីក្នុងតួនាទីនយោបាយសេដ្ឋកិច្ច សង្គម ទាំងមិនគ្រប់លក្ខណៈសម្បត្តិទេ។ អ៊ីចឹងវាផ្អែកទៅលើសភាពការណ៍ជាក់ស្តែងផង ហើយវាផ្អែកទៅលើលក្ខណៈសម្បត្តិរបស់ស្ត្រីផង។ បាទ! អាហ្នឹងយើងក៏កសាងឲ្យវាស្របគ្នា ឲ្យស្របតាមសំណូមពរត្រូវការ ក៏ប៉ុន្តែយើងថាបើសំណូមពរត្រូវការហើយ យើងមិនគិតគូរអំពីលក្ខណៈសម្បត្តិទេ យកបានតែចំនួនបរិមាណតែគុណភាពមិនធានាទេ"* ។

លោកបន្ថែមថាដើម្បីឲ្យស្ត្រីចូលរួមក្នុងវិស័យនយោបាយមានចំនួនច្រើន គឺពាក់ព័ន្ធការសម្រេចចិត្ត និងការឈ្មុសឈ្មុលរបស់ស្ត្រីដោយផ្ទាល់ ព្រោះវាជារឿងសំខាន់ និងពាក់ព័ន្ធសិទ្ធិរបស់មនុស្សម្នាក់ៗ ហើយបូករួមឆន្ទៈរបស់គណបក្ស និងគោលនយោបាយរបស់រដ្ឋាភិបាល។ ប៉ុន្តែលោកថាការចូលរួមរបស់ស្ត្រី កំពុងមានការកើនឡើងជាបណ្តើរៗ[18]។

## ២.៩. ស្ត្រីនៅក្នុងវិស័យកិច្ចការអន្តរជាតិ

កន្លងមកនេះ ពុំមានស្ត្រីជាឯកអគ្គរដ្ឋទូតតំណាងកម្ពុជានៅបរទេសទេ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់កំហុសទៅលើវប្បធម៌ និងតម្លៃសង្គមហួសហេតុ ដែលធ្វើឲ្យស្ត្រីពិបាកក្នុងការចាកចេញពីស្រុកដើម្បីទទួលតំណែងនៅក្រៅប្រទេសនោះ។

ស្ត្រីហាក់ដូចជាមានតំណាងច្រើនគួរសមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា។ មុខងារទាំងនេះ ជាចំណុចចាប់ផ្តើមសម្រាប់ស្ត្រីបន្តការងារនៅក្នុងឆាកអន្តរជាតិ ដូចជា ចូលរួមក្នុងសន្និសីទ និងជាប្រតិភូជាដើម[19]។

## ២.១០. ស្ត្រីនៅក្នុងវិស័យយោធា

ស្ត្រីកម្ពុជាមានចំនួនតិចជាង៣ភាគរយនៅក្នុងចំណោមថ្នាក់ដឹកនាំយោធា។ នេះបើតាមការបញ្ជាក់របស់ក្រសួងការពារជាតិ និងក្រសួងកិច្ចការនារីនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៨។

មានតែស្ត្រី៨៨នាក់ប៉ុណ្ណោះដែលកាន់តំណែងផ្កាយមួយ និងលើនេះ ហើយមានស្ត្រីតែម្នាក់ប៉ុណ្ណោះដែលមានឋានៈផ្កាយបួន និងមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទកម្ពុជា។ ក្នុងប្រទេសកម្ពុជា មានឧត្តមសេនីយ៍យ៉ាងហោចណាស់ ៣០០០នាក់ ដែលមានន័យថា ស្ត្រីមានចំនួនតែ២,៩ភាគរយក្នុងចំណោមថ្នាក់ដឹកនាំយោធា។

ក្រសួងកិច្ចការនារីបានថ្លែងថា មានឧត្តមសេនីយ៍ឯកស្ត្រីចំនួន៧នាក់ ឧត្តមសេនីយ៍ទោ១៩នាក់ និងឧត្តមសេនីយ៍ត្រី៦១នាក់។

[18]លាស់ លីបលីប, *សង្គមស៊ីវិលបារម្ភអំពីការកើនឡើងតិចតួចនៃចំនួនស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់,* https://khmer.voanews.com/a/civil-society-organizations-worry-about-fewer-increase-of-women-representatives-in-local-election/6640181.html ។

[19] Natalie Hacks, ស្ថានភាពស្ត្រីនៅកម្ពុជា, https://www.licadho-cambodia.org/reports/files/56kWReport2004Khmer.pdf

នៅក្នុងព្រឹត្តិការណ៍មួយ នៅមុនទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា រដ្ឋមន្ត្រីការពារជាតិ លោក ទៀ បាញ់ បាន ជម្រុញយោធាជំឡើងឋានៈស្ត្រីឲ្យមានឋានៈខ្ពស់ជាងមុនដោយហៅស្ត្រីថាជា “*ឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គម* ” និងជា “*អំណាចមួយ ដែលមិនអាចខ្វះបាន*” នៅក្នុងការអភិវឌ្ឍន៍ប្រទេស។

ប៉ុន្តែលោកក៏បានប្រាប់ស្ត្រីយោធាឲ្យលើកកម្ពស់ “*តម្លៃប្រពៃណី*” នៃស្ត្រីខ្មែរផងដែរ ដើម្បីកែលម្អសីលធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរជានិច្ច។

លោកស្រី រស់ សុភាព នាយិកាអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា បានថ្លែងថា “*ភាសាដែលជាធម្មតានិយាយថា ស្ត្រីនៅផ្ទះ ចិញ្ចឹមកូន និងយកចិត្តទុកដាក់ចំពោះប្ដីរបស់ខ្លួន ទំនងជាមិនលើកទឹកចិត្តស្ត្រីសម្រាប់តួនាទីជាមេបញ្ជាការយោធាទេ*”។

លោកស្រី សុភាព បានថ្លែងថា៖ “*យោធា គឺផ្ទុយនឹងវប្បធម៌នោះ*”។ លោកស្រីបន្ថែមថា “*ស្ត្រីត្រូវការផ្ដល់ឲ្យនូវឱកាសស្មើគ្នា ក្នុងការអប់រំ និងការបណ្ដុះបណ្ដាល ដើម្បីទទួលបានតំណែងយោធា*”។

អ្នកនាំពាក្យក្រសួងការពារជាតិ លោក ឈុំ សុជាតិ បានថ្លែងថា “*មានស្ត្រីសរុបចំនួន៦៥០០នាក់នៅក្នុងកងកម្លាំងការពារជាតិ ប៉ុន្តែមិនអាចដឹងអំពីចំនួនភាគរយ ឬចំនួនសរុប នៃមេដឹកនាំយោធាដែលជាស្ត្រីនោះទេ*”។

លោក សុជាតិ បានថ្លែងថា៖ “*យើងនៅតែត្រូវការលើកកម្ពស់ស្ត្រី។ យើងត្រូវការស្ត្រីនៅក្នុងយោធា*” [20] ។

## **២.១១. ស្ត្រីនៅក្នុងវិស័យអប់រំ**

ព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងការទទួលបានការអប់រំ រៀនសូត្រគ្រប់ទម្រង់ និងស្ថានភាពទាំងអស់ដូចមានចែងក្នុងមាត្រា៦៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[21]។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការគ្រប់បែបយ៉ាងដើម្បីធានាបាននូវសមភាពក្នុងការសិក្សារបស់សិស្សស្រី និងសិស្សប្រុសនៅគ្រប់កម្រិតសិក្សា តាំងពីមតេយ្យសិក្សារហូតដល់ឧត្តមសិក្សា និងថ្នាក់បណ្ដុះបណ្ដាលជំនាញគ្រប់ផ្នែក។

ក្រសួងអប់រំយុវជន និងកីឡា គឺជាស្ថាប័នរដ្ឋដែលមានតួនាទីទទួលបន្ទុកវិស័យអប់រំនៅកម្ពុជា។ ការអប់រំជាមូលដ្ឋាន ត្រូវបានចែកចេញជាពីរកម្រិតសំខាន់គឺ ការអប់រំកម្រិតបឋម និងមធ្យមសិក្សា។

### **២.១១.១. ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា**

ការអប់រំកម្រិតបឋមសិក្សា សម្ដៅទៅលើឆ្នាំសិក្សា៦ឆ្នាំដំបូង(ថ្នាក់ទី១ ដល់ថ្នាក់ទី៦) បន្ទាប់មកកម្រិតមធ្យមសិក្សា៦ឆ្នាំទៀត(ថ្នាក់ទី៧ ដល់ថ្នាក់ទី១២)។ ស្ថិតិ និងសូចនាករអប់រំសាធារណៈបានបង្ហាញថាមាន

[20] បែន សុខហ៊ាន និង Erin Handley, *ស្ត្រីកម្ពុជា មានតិចជាង៣ភាគរយក្នុងចំណោមថ្នាក់ដឹកនាំយោធា* http://bit.ly/2FesVh7 ។

[21] អគ្គនាយកដ្ឋានរដ្ឋសភា, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ១៩៩៣) ។

សាលារៀនសរុបចំនួន១៤.៥២២ នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា២០១៨-២០១៩។ សាលាចំនួន១៣.៣០០ ជាសាលារបស់រដ្ឋ និង ១.២២២ ជាកម្មសិទ្ធិរបស់ឯកជន។ ប្រមាណ៨០ភាគរយនៃសាលាឯកជន(៩៩៤ សាលារៀន)មានទីតាំងនៅតំបន់ទីក្រុង ចំណែកឯនៅសល់(២២៨)ទៀតស្ថិតនៅតំបន់ជនបទ។ សាលារដ្ឋភាគច្រើនត្រូវបានគេមើលឃើញថានៅតំបន់ជនបទ។ សាលារៀនចំនួន១១.៨៧៨ ត្រូវបានគេរកឃើញនៅតាមទីជនបទ ហើយមានត្រឹមតែ១.៤២២ ប៉ុណ្ណោះនៅក្នុងទីប្រជុំជន។ ក្នុងចំណោមសាលារដ្ឋចំនួន១៣.៣០០ មានសាលាចំនួន១.៧៧១ ជាអនុវិទ្យាល័យ និងនៅសល់ជាសាលាបឋមសិក្សា។ សមាមាត្រសិស្ស-គ្រូ គឺជាមធ្យម ៣៤ ។ ទោះយ៉ាងណាសមាមាត្រសិស្ស-គ្រូ មានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងតំបន់ជនបទ និងទីក្រុង ដែលតំបន់ជនបទមាន ៣៦,៩ និងតំបន់ទីក្រុង ២៥,៤ ។

## ស្ថិតិស្តីពីសាលាបឋមសិក្សាកម្ពុជាក្នុងឆ្នាំ ២០១៨-២០១៩

| ឈ្មោះខេត្ត | ចំនួនសាលាបឋមសិក្សា | ចំនួនសាលាដែលខ្វះខាត | ចំនួនថ្នាក់សិក្សា | ចំនួនបន្ទប់សិក្សា | បុគ្គលិកបង្រៀន |
|---|---|---|---|---|---|
| ទូទាំងប្រទេស | 7,228 | 55 | 62,208 | 44,385 | 45,836 |
| តំបន់ទីប្រជុំជន | 675 | 0 | 9,168 | 6,503 | 9,565 |
| តំបន់ជនបទ | 6,553 | 55 | 53,040 | 37,892 | 36,271 |
| បន្ទាយមានជ័យ | 410 | 4 | 3,213 | 2,275 | 2,911 |
| បាត់ដំបង | 644 | 4 | 5,543 | 3,762 | 3,627 |
| កំពង់ចាម | 408 | 2 | 3,867 | 2,855 | 2,601 |
| កំពង់ឆ្នាំង | 278 | 0 | 2,237 | 1,511 | 1,779 |
| កំពង់ស្ពឺ | 313 | 1 | 2,903 | 2,130 | 2,225 |
| កំពង់ធំ | 487 | 2 | 3,309 | 2,396 | 2,425 |
| កំពត | 311 | 0 | 2,451 | 1,944 | 2,305 |

*ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០១៨-២០១៩(ក្រសួងអប់រំ)*

ការសិក្សាកម្រិតបឋមសិក្សា ត្រូវបានគេចាត់ទុកថាជាការអប់រំមូលដ្ឋានមួយដែលមនុស្សម្នាក់ៗត្រូវការដើម្បីអាចឲ្យពួកគេអភិវឌ្ឍខ្លួនឯង។ ក្រសួងអប់រំបានផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍ការអប់រំកម្រិតបឋម ហើយថវិកាមួយចំនួនធំត្រូវបានផ្តល់សម្រាប់កែលម្អកម្រិតអប់រំមួយនេះផងដែរ។ ព្រះរាជាណាចក្រកម្ពុជា ជិតបានសម្រេចគោលដៅនៃការទទួលបានការអប់រំបឋមសិក្សាជាសកល រដ្ឋាភិបាលកំពុងព្យាយាមដើម្បីសម្រេចឲ្យ

បាននូវគោលការណ៍នេះតាមរយៈការអនុវត្ត**គោលនយោបាយការអប់រំពេញមួយជីវិត** និង **គោលនយោបាយការអប់រំសម្រាប់ទាំងអស់គ្នា**។ អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាសម្រាប់កុមារកម្ពុជាមានប្រមាណ៩៧ភាគរយនៅក្នុងឆ្នាំសិក្សា២០១៧-២០១៨ ។ យូនីសេហ្វបានរកឃើញថា កុមារប្រហែល៤៣ភាគរយដែលមានអាយុចាប់ពីអាយុ៣ឆ្នាំដល់ ៥ឆ្នាំ បានចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សា។ អត្រាអ្នកបោះបង់ការសិក្សានៅកម្រិតអប់រំនេះត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល៦,៧ភាគរយក្នុងឆ្នាំសិក្សា២០១៦ ហើយត្រូវបានគេកត់សម្គាល់ឃើញថា កើតមានជាញឹកញាប់នៅតំបន់ជនបទជាងតំបន់ទីក្រុង។ មូលហេតុចម្បងដែលធ្វើឲ្យមានអត្រាខ្ពស់នៃការបោះបង់ការសិក្សានៅកម្រិតដំបូង គឺដោយសារមានការរៀនត្រួតថ្នាក់ច្រើន និងកត្តាភាពក្រីក្រ។ ការអប់រំកម្រិតមធ្យមសិក្សាមានអត្រាអ្នកបោះបង់ចោលការសិក្សាខ្ពស់ជាង ប្រហែល២០ភាគរយក្នុងឆ្នាំ២០១៤។ សិស្សចាស់ៗជាច្រើនបានសម្រេចបោះបង់ចោលការសិក្សា ដើម្បីរកការងារធ្វើរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ។

### ២.១១.១.១. ការសិក្សាក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩

ខណៈពេលមានជំងឺរាតត្បាតកូវីដ-១៩វិស័យអប់រំត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅក្នុងឆ្នាំសិក្សា២០១៩-២០២០ ។ សាលារៀនត្រូវបានបញ្ជាឲ្យផ្អាកដំណើរការដោយសារការភ័យខ្លាចនៃការចម្លងកូវីដ-១៩ នៅក្នុងសហគមន៍។ ការប្រលងថ្នាក់ជាតិថ្នាក់ទី១២ ដែលត្រូវបានគេចាត់ទុកថាជាការប្រលងធំបំផុតមួយសម្រាប់ការអប់រំមូលដ្ឋានក៏ត្រូវបានលុបចោល។ ក្រសួងអប់រំ យុវជន និងកីឡាបានណែនាំការអប់រំឌីជីថលតាមរយៈការសិក្សាពីចម្ងាយ និងតាមអ៊ិនធឺណេតក្នុងពេលមានជំងឺរាតត្បាតជាដំណោះស្រាយ។

ដោយធ្វើការជាមួយអង្គការយូនីសេហ្វ ក្រសួងបានណែនាំ**កម្មវិធីអប់រំតាមវិទ្យុ** ដែលអនុញ្ញាតឲ្យសិស្សបឋមសិក្សានៅតំបន់ជនបទ ជាពិសេសកុមារជនជាតិដើមភាគតិចអាចទទួលបានការអប់រំ ក្នុងកំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩ តាមរយៈឧបករណ៍វិទ្យុ។ ទោះយ៉ាងណាកុមារប្រហែល ១,៤លាននាក់មិនអាចចូលរៀនតាមបែបឌីជីថលបានទេក្នុងកំឡុងពេលមានជំងឺរាតត្បាត។ ទាំងសិស្ស និងគ្រូបានជួបប្រទះនូវបញ្ហាជាមួយនឹងវិធីសាស្ត្ររៀនអេឡិចត្រូនិចដែលភាគច្រើនបណ្តាលមកពីអក្ខរកម្មឌីជីថលនៅទាប។ សិស្សនៅតំបន់ដាច់ស្រយាលភាគច្រើនត្រូវបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារតែពួកគេមិនមានឧបករណ៍ចាំបាច់សម្រាប់ការរៀននៅលើប្រព័ន្ធអនឡាញ[22]។

ឯកឧត្តមបណ្ឌិតសភាចារ្យបានលើកឡើងថា បច្ចុប្បន្នកុមារអាយុ៥ឆ្នាំ បានចូលរៀននៅមត្តេយ្យសិក្សាគ្រប់រូបភាពមានចំនួន៦៣.១ភាគរយ កុមារី៦៣.៦ភាគរយ។ ជាមួយគ្នានេះ អត្រាពិតនៃការសិក្សានៅបឋម

[22] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, *ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា* ,https://opendevelopmentcambodia.net/km/topics/primary-and-secondary-education/ ។

សិក្សាសាធារណៈ និងឯកជនមានចំនួន៩៨.០ភាគរយ(ស្រី៩៨.៥ភាគរយ)ស្ថិតក្នុងស្តង់ដារ និងក្នុងកម្រិតប្រហាក់ប្រហែលប្រទេសក្នុងតំបន់។

ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានស្វាគមន៍ចំពោះលទ្ធផលដែលក្រសួងអប់រំ យុវជន និងកីឡាទទួលបាននាពេលកន្លងមកបន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំក្នុងការកែលំអគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាឲ្យកាន់តែមានភាពល្អពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ ឯកឧត្តមក៏បានជម្រុញដល់លោកគ្រូ អ្នកគ្រូ ត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀន ទោះបីមានមជ្ឈដ្ឋានមួយចំនួនថាគុណភាពអប់រំនៅកម្ពុជានៅមានកម្រិតក៏ដោយ។

សូមបញ្ជាក់ថា បច្ចុប្បន្នសិស្សសរុបនៅគ្រប់ភូមិសិក្សាសាធារណៈ និងឯកជន ចាប់ពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សាមានចំនួន៣.៥៦៧.១០៥នាក់ ក្នុងនោះស្រី១.៧៦៦.៣៧៩នាក់ ស្មើនឹង៤៩.៥ភាគរយ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមានចំនួន១២៥ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន៤៨ និងឯកជនចំនួន៧៧។ ដោយឡែកនិស្សិតកំពុងសិក្សានៅថ្នាក់ឧត្តមសិក្សាមានចំនួន២១១.៤៨៤នាក់ ស្រី៩៨.៦៣០នាក់ ស្មើនឹង៤៦.៦៣ភាគរយ ក្នុងនោះនិស្សិតបរទេសអាហារូបករណ៍មានចំនួន១៥៨នាក់ ស្រី៦០នាក់ ស្មើនឹង៣៧.៩៧ភាគរយ។ ចំណែកបុគ្គលិកអប់រំសរុបនៅទូទាំងប្រទេសមានចំនួន១២០.២៩៩នាក់ ស្រី៥៤.៩៥៨នាក់ (ត្រូវជា៤៥.៧ភាគរយ) ក្នុងនោះ ថ្នាក់ជាតិចំនួន៣.៤១៦នាក់ ស្រី៩៣៩នាក់(ត្រូវជា២៧.៥ភាគរយ) និងថ្នាក់ក្រោមជាតិចំនួន១១៦.៨៨៣នាក់ ស្រី៥៤.០១៩នាក់(ត្រូវជា៤៦.២ភាគរយ)[23]។

### ២.១១.១.២. គោលនយោបាយ និងក្របខ័ណ្ឌអភិវឌ្ឍន៍

ប្រព័ន្ធអប់រំនៅកម្ពុជាបានឆ្លងកាត់កំណែទម្រង់ជាច្រើនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ជាពិសេសជុំវិញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ កំណែទម្រង់នេះផ្តោតលើការលើកកម្ពស់គុណភាព និងការអប់រំប្រកបដោយបរិយាបន្ន ក្នុងការអប់រំប្រកបដោយសុវត្ថិភាព និងអនាម័យសម្រាប់កុមារ តម្លាភាពរដ្ឋបាល និងហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក។ គោលនយោបាយ និងក្របខ័ណ្ឌជាច្រើនត្រូវបានអនុម័ត និងអនុវត្តដើម្បីកែលម្អប្រព័ន្ធអប់រំដូចជា **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គោលដៅលេខ ៤ លើផែនការវិស័យអប់រំឆ្នាំ២០៣០ គោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា គោលនយោបាយស្តីពីគ្រូ**

[23] ក្រសួងពត៌មាន, *រដ្ឋមន្ត្រីក្រសួងអប់រំ៖ បច្ចុប្បន្នកម្ពុជាមានសាលារៀនចំណេះដឹងទូទៅសរុបជិត១៥.០០០កន្លែងនៅទូទាំងប្រទេស,* https://www.information.gov.kh/articles/24614 ។

**បង្រៀន ផែនការសកម្មភាព គោលនយោបាយជាតិស្ដីពីសុខភាពសិក្សា គោលនយោបាយសាលាកុមារល្អ។** ការអភិវឌ្ឍន៍សមត្ថភាព បានក្លាយជាគោលដៅចម្បងនៃការកែទម្រង់គោលនយោបាយ និងច្បាប់។ នៅឆ្នាំ ២០២០ កម្មវិធីអប់រំនៅកម្រិតថ្នាក់ដំបូងនៃបឋមសិក្សាថ្មីមួយដែលមានឈ្មោះថា "កម្មវិធីកុមាររៀនកុមារចេះ" ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការណ៍។ ដោយមានការសហការជាមួយអ្នកពាក់ព័ន្ធដទៃទៀត ក្រសួងអប់រំបានអនុវត្តកម្មវិធីនេះដើម្បីពង្រឹងកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាសម្រាប់កុមារតូចៗ។ កម្មវិធីនេះក៏គូសបញ្ជាក់ជាពិសេសលើការបណ្តុះបណ្តាលសមត្ថភាពរបស់គ្រូ ដើម្បីបង្ហាញពីយុទ្ធសាស្ត្របង្រៀនថ្មីនេះដោយជោគជ័យផងដែរ។ មានសិស្សប្រមាណ១៥០.០០០ នាក់នៅក្នុងសាលាចំនួន២.១០០ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ បានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ។

**យោងតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្របខ័ណ្ឌសសរស្តម្ភទាំង៥ គឺៈ**

- **សសរស្តម្ភទី១ ៖** ការអនុវត្តន៍ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន
- **សសរស្តម្ភទី២ ៖** ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា
- **សសរស្តម្ភទី៣ ៖** ការដាក់ឲ្យអនុវត្តអធិការកិច្ច
- **សសរស្តម្ភទី៤ ៖** ការពង្រឹងវង្វាយតម្លៃសិក្សា ដូចជាការប្រលង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- **សសរស្តម្ភទី៥ ៖** ការកែទម្រង់ឧត្តមសិក្សា។

ក្រសួងអប់រំក៏បានបញ្ចូលបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងការអប់រំបែបស្ទែម(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា)ទៅក្នុងគរុកោសល្យបង្រៀន និងកម្មវិធីសិក្សាផងដែរ។ ការចូលប្រើបច្ចេកវិទ្យាបើកទូលាយនៅក្នុងការអប់រំបឋម និងមធ្យមសិក្សាបានក្លាយជាចក្ខុវិស័យមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់នៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងវិស័យអប់រំ។ ការរៀន និងការបង្រៀនដោយប្រើឧបករណ៍បច្ចេកវិទ្យាព័ត៌មាន កំពុងត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងដើម្បីតាមឲ្យទាន់ប្រទេសជិតខាង។ យោងទៅតាមក្រសួងអប់រំ សាលាអនុវិទ្យាល័យចំនួន១៤១ នៅក្នុងខេត្តចំនួន៨ ផ្សេងគ្នាត្រូវបានបំពាក់ដោយបន្ទប់កុំព្យូទ័រ។ ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាជំហានឈានឆ្ពោះទៅរកការរៀនសូត្រតាមបែបទំនើបនៅក្នុងប្រទេស។ បច្ចុប្បន្នមានគម្រូសាលាជំនាន់ថ្មីសាកល្បងប្រមាណ ១១សាលាដែលកំពុងដំណើរការនៅទូទាំងប្រទេសដោយមានគោលដៅពង្រីកគម្រូដល់១០០សាលា នៅឆ្នាំ ២០២២ ។

### ២.១១.២. ការអប់រំកម្រិតឧត្តមសិក្សា

អត្ថន័យនៃពាក្យ "ការអប់រំជាន់ខ្ពស់" ឬ អាចហៅម្យ៉ាងទៀតថា "ឧត្តមសិក្សា" និយាយឲ្យសាមញ្ញ វាជាកម្រិតសិក្សា ដែលយើងត្រូវបន្តការសិក្សាបន្ទាប់ពីចប់វិទ្យាល័យគឺ សិក្សានៅវិទ្យាស្ថាន មហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ ឬ ស្ថាប័នបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈផ្សេងៗទៀត។

យើងអាចទាញទ្រឹស្តីជាមូលដ្ឋានបានថា ឧត្តមសិក្សា គឺស្ថិតក្នុងកម្រិតមួយដែលផ្តល់លក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់បុគ្គលណាម្នាក់ ដើម្បីធ្វើការនៅកន្លែងដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់មួយ ហើយវាជាធម្មតានឹងត្រូវបានបង្រៀននៅក្នុងមជ្ឈដ្ឋាន ដែលមានរួមបញ្ចូលនូវសកម្មភាពស្រាវជ្រាវដ៏ទំនើបមួយ។ កម្រិតថ្នាក់ឧត្តមសិក្សាទាំងនេះត្រូវបានទទួលស្គាល់នៅទូទាំងពិភពលោកថា ជាកម្រិតដែលមានជំនាញឯកទេសទូលំទូលាយ ហើយដែលនិយោជកបានរកឃើញថាមានប្រយោជន៍ជាខ្លាំងណាស់ចំពោះគេ។ វិស័យអប់រំនៅឧត្តមសិក្សា គឺផ្តោតជាចម្បងទៅលើកម្មវិធីសិក្សាដែលបានរៀបចំសិស្សឲ្យរួចរាល់សម្រាប់អាជីពផ្នែកវិទ្យាសាស្ត្រ និងការស្រាវជ្រាវតម្រង់ទិសដែលតម្រូវឲ្យមានជំនាញកម្រិតខ្ពស់។ វគ្គសិក្សាមួយចំនួនកំពុងត្រូវបានតម្រង់ទិសឆ្ពោះទៅរកការលើកកម្ពស់ជំនាញជាក់លាក់ ជាក់ស្តែង និងជំនាញបច្ចេកទេស។ ការអប់រំជាន់ខ្ពស់ គឺការអប់រំជាផ្លូវការណ៍ដែលផ្តល់ដោយស្ថាប័នឧត្តមសិក្សា ហើយការបញ្ចប់ដោយជោគជ័យត្រូវបានសម្គាល់ដោយការប្រគល់សញ្ញាបត្រពីសាកលវិទ្យាល័យ ពោលគឺមានសញ្ញាបត្របរិញ្ញាបត្រ សញ្ញាបត្រអនុបណ្ឌិត សញ្ញាបត្របណ្ឌិត ឬសញ្ញាបត្រផ្សេងទៀត។ ការចូលរៀនក្នុងស្ថាប័នអប់រំកម្រិតឧត្តមសិក្សា(ឧទាហរណ៍ៈមហាវិទ្យាល័យ សាកលវិទ្យាល័យ ឬស្ថាប័នដែលមានកម្រិតស្មើ) ដែលជាទូទៅតម្រូវឲ្យមានវិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ[24]។

ការអប់រំកម្រិតឧត្តមសិក្សា ជាទូទៅសម្តៅលើការអប់រំលើសពីកម្រិតមធ្យមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាអាចបែងចែកជាបីប្រភេទគឺៈ រាជបណ្ឌិត្យសភា សាកលវិទ្យាល័យ និងមហាវិទ្យាល័យ។ ការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា រួមមានសញ្ញាបត្របរិញ្ញាបត្ររង បរិញ្ញាបត្រ៤ឆ្នាំ ថ្នាក់អនុបណ្ឌិត២ឆ្នាំ និងបណ្ឌិត ៣ឆ្នាំ ដល់ ៦ឆ្នាំ[25]។

មុនពេលមានការអភិវឌ្ឍន៍ដូចពេលបច្ចុប្បន្ននេះ ប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាត្រូវបានកម្ទេចចោលក្នុងរបបខ្មែរក្រហម(១៩៧៥-១៩៧៩)ហើយទើបតែអាចកសាងឡើងវិញបានបន្ទាប់ពីសម័យកាលនោះបានបញ្ចប់។

---

[24] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, *ការអប់រំកម្រិតឧត្តមសិក្សា*, https://opendevelopmentcambodia.net/km/topics/higher-education ។

[25] តើអ្វីទៅដែលហៅថាឧត្តមសិក្សា( ការអប់រំជាន់ខ្ពស់ ? ), https://www.palmhub.com ។

សម័យនេះឃើញមានការបើកឡើងវិញនូវសាកលវិទ្យាល័យមួយចំនួន ដែលបានសាងសង់មុនសម័យខ្មែរក្រហម ដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញជាដើម។ ចាប់តាំងពីពេលនោះមក ព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមពង្រីក និងរៀបចំរចនាសម្ព័ន្ធឧត្តមសិក្សាឡើងវិញដោយបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជន និងណែនាំកម្មវិធីបង់ថ្លៃសម្រាប់គ្រឹះស្ថានសាធារណៈ និងឯកជន។ នៅឆ្នាំ១៩៩៧ គ្រឹះស្ថានឧត្តមសិក្សាឯកជនដំបូងគេត្រូវបានបង្កើតឡើងក្រោមគោលនយោបាយនេះ។ ក្រោយមក ឧត្តមសិក្សាទាំងសាធារណៈ និងឯកជនបានចាប់ផ្តើមកើនឡើងពី ៨ ក្នុងឆ្នាំ១៩៩៧ ដល់ ៧០ ក្នុងឆ្នាំ២០០៩ ដល់ ១២៨ ក្នុងឆ្នាំ២០២០ ដែលមាននៅក្នុងខេត្ត និងរាជធានីចំនួន ២០។ ជាងនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡា ត្រួតពិនិត្យគ្រឹះស្ថានឧត្តមសិក្សាចំនួន៨០ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង១២៨។

**២.១១.២.១. ការចុះឈ្មោះចូលរៀន**

ការចុះឈ្មោះចូលរៀនរបស់សិស្សនៅថ្នាក់ឧត្តមសិក្សាបានកើនឡើងពី២៨,០៨០នាក់ក្នុងឆ្នាំ២០០០ ដល់ ២២៣,២២១នាក់ក្នុងឆ្នាំ២០១០ និង ២០១,៩០០ រួមទាំងនិស្សិតអន្តរជាតិចំនួន១៥៥នាក់ក្នុងឆ្នាំ ២០២០-២១។ ប៉ុន្តែដោយសារតែជំងឺរាតត្បាតកូវីដ-១៩ មានការធ្លាក់ចុះនៃការចុះឈ្មោះសិស្សក្នុងថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំសិក្សា២០១៩-២០ ប៉ុន្តែមានការកើនឡើងនៃការចុះឈ្មោះចូលរៀននៅថ្នាក់បណ្ឌិត។ អត្រាចុះឈ្មោះចូលរៀនសរុប(អាយុពី១៨ ទៅ ២២ឆ្នាំ)ក៏បានកើនឡើងពី ៦ភាគរយក្នុងឆ្នាំ២០០៦ ដល់ ១០ភាគរយក្នុងឆ្នាំ២០១៨។ ទោះជាយ៉ាងណាក៏ដោយ អត្រានេះនៅមានកម្រិតទាបនៅឡើយដោយសារមិនទាន់ឈានដល់គោលដៅ២៣ភាគរយ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ អត្រាចុះឈ្មោះចូលរៀនទាបអាចបណ្តាលមកពីកង្វះសាកលវិទ្យាល័យនៅតាមខេត្ត ដែលបង្កការលំបាកដល់សិស្សក្នុងការធ្វើចំណាកស្រុកទៅរាជធានី។ ជាងនេះទៅទៀត ឧបសគ្គភាសាគឺជាកត្តាមួយក្នុងចំណោមបញ្ហាដែលរារាំងដល់ទឹកចិត្តរបស់សិស្សនៅជនបទក្នុងការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ដោយសារសិស្សនៅតាមបណ្តាខេត្តយល់ថា វាពិបាកក្នុងការចូលរៀនវគ្គសិក្សាជាភាសាបរទេស។ ហេតុផលមួយទៀតគឺ សិស្សមួយចំនួនមិនបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិដោយសារកំណែទម្រង់ប្រឡងតឹងរ៉ឹង ដូច្នេះហើយសិស្សមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះចូលរៀននៅឆ្នាំមូលដ្ឋានគ្រឹះនៃថ្នាក់ឧត្តមសិក្សា។ ប៉ុន្តែផ្ទុយទៅវិញ ពួកគេមួយចំនួនជ្រើសរើសសិក្សាសញ្ញាបត្របរិញ្ញាបត្ររង។ យ៉ាងណាក្តី គេរំពឹងថាចំនួនសិស្សដែលបានចុះឈ្មោះចូលរៀននៅឧត្តមសិក្សានៅឆ្នាំ២០៣០ នឹងកើនឡើងទ្វេដងបើធៀបទៅនឹងឆ្នាំ២០១៨។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលដៅនៃការចុះឈ្មោះត្រឹម២២,៧ភាគរយក្នុងឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ និង ២៥ភាគរយនៅឆ្នាំ២០៣០។

ទាក់ទងនឹងការរើសជំនាញសិក្សានៅថ្នាក់ឧត្តមសិក្សា និស្សិតភាគច្រើនជ្រើសរើសជំនាញវិទ្យាសាស្ត្រសង្គម ហើយមានតែប្រហែល៣០ភាគរយប៉ុណ្ណោះដែលចុះឈ្មោះចូលរៀនជំនាញស្ទែម។ ដោយសារចំនួនសិស្សដែលសិក្សាជំនាញស្ទែមមានតិចតួច ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការលើកកម្ពស់ និងបង្កើនលទ្ធភាពចូលរៀនជំនាញស្ទែមរបស់និស្សិតក្នុងកម្រិតឧត្តមសិក្សាដោយបង្កើតវគ្គបណ្តុះបណ្តាល និងកម្មវិធីថ្មីៗផ្តោតលើជំនាញនេះ។ ជាងនេះទៅទៀត កម្ពុជាក៏ប្រឈមមុខនឹងបញ្ហាគម្លាតនៅថ្នាក់អនុបណ្ឌិតដែលទាមទារការវិនិយោគបន្ថែមលើមុខជំនាញទាក់ទងនឹងស្ទែម។

**២.១១.២.២. និស្សិតកំពុងសិក្សាកម្រិតឧត្តមសិក្សា និងអាហារូបករណ៍**(**២០១៥-២០២០**)

គ្រឹះស្ថានឧត្តមសិក្សាសាធារណៈផ្តល់អាហារូបករណ៍ជាច្រើនដល់សិស្សក្នុងទម្រង់នៃការពុំបាច់បង់ថ្លៃសិក្សា។ អាហារូបករណ៍រដ្ឋាភិបាលគ្របដណ្តប់ប្រហែល១៥ភាគរយ នៃការចុះឈ្មោះរបស់សិស្សសរុប។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតកម្មវិធីដែលផ្តល់អាហារូបករណ៍ពេញលេញដល់និស្សិតឆ្នាំទី១ នៅថ្នាក់ឧត្តមសិក្សា។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសគឺផ្អែកលើ ភេទ ទីតាំងតំបន់ និងសមិទ្ធផលរបស់សិស្ស ដែលផ្អែកលើការរួមបញ្ចូលគ្នាដូចជា៖ សិស្សក្រីក្រ(២០ភាគរយ) សិស្សស្រី(១៥ភាគរយ) តំបន់ជួបការលំបាក(៥ភាគរយ) សិស្សពូកែ(៦០ភាគរយ) និងការចុះឈ្មោះចូលរៀនជំនាញអាទិភាព។ ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូ ព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ជូននិស្សិតអាហារូបករណ៍កម្ពុជាចំនួន៤៣៧នាក់(ស្រី១៤៣នាក់)ទៅក្រៅប្រទេសដែលចាប់ពីវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈរហូតដល់ថ្នាក់បណ្ឌិត។ ផែនការអនាគតក៏នឹងត្រូវបានធ្វើឡើងផងដែរ ដើម្បីជួយដល់និស្សិតអាហារូបករណ៍ ខណៈដែលក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំគោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ និងក្រេឌីតសម្រាប់សិស្សានុសិស្សក្នុងកម្រិតឧត្តមសិក្សាជាមួយនឹងការបង្កើនទីស្នាក់អាស្រ័យសម្រាប់និស្សិតស្រីផងដែរ។

**២.១១.២.៣. បញ្ហាប្រឈម**

ទោះបីជាមានការរីកចម្រើន និងសមិទ្ធផលក៏ដោយ ការអប់រំឧត្តមសិក្សានៅកម្ពុជានៅតែប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនរួមមាន លទ្ធភាពទទួលបាន គុណភាព សមធម៌ ភាពពាក់ព័ន្ធ ការផ្តល់មូលនិធិ ការគ្រប់គ្រង និងរដ្ឋបាល។ ក្រសួង និងស្ថាប័នជាច្រើនចូលរួមពាក់ព័ន្ធនឹងការអប់រំឧត្តមសិក្សា ដែលធ្វើឲ្យការសម្របសម្រួលមានបញ្ហាដោយសារការត្រួតពិនិត្យគុណភាព ការងារស្ទួនគ្នាផ្នែករដ្ឋបាល និងការផ្លាស់ប្តូរព័ត៌មាន។ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន ការគ្រប់គ្រងការបង្រៀន និងឧបករណ៍នៅខ្វះខាតនៅឡើយ។ មានគ្រូបង្រៀនកម្រិតឧត្តមសិក្សាប្រមាណ១,៦៦២នាក់នៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ប៉ុន្តែពួកគេខ្វះ

ប្រវត្តិសិក្សាគ្រប់គ្រាន់។ លើសពីនេះទៀត គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនខ្វះធនធានចាំបាច់សម្រាប់ការស្រាវជ្រាវដែលរារាំងសមាជិកមហាវិទ្យាល័យពីការស្រាវជ្រាវសម្រាប់ការបោះពុម្ពផ្សាយ។

ជាលទ្ធផល ការវិនិយោគសំខាន់គឺត្រូវបានទាមទារដើម្បីបង្កើនចំនួនសាស្ត្រាចារ្យពេញម៉ោង ដែលមានសញ្ញាបត្របណ្ឌិតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា។ នេះនឹងផ្តល់ឲ្យពួកគេនូវពេលវេលាគ្រប់គ្រាន់ និងសមត្ថភាពកម្រិតខ្ពស់ក្នុងការបង្កើតនិស្សិតបញ្ចប់ការសិក្សាដែលមានគុណភាពខ្ពស់ដែលបំពេញតម្រូវការទីផ្សារការងារ និងស្តង់ដារអន្តរជាតិ។ ទន្ទឹមនឹងនោះ ដំណើរការផ្តល់ស្វ័យភាពគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សមិនទាន់ត្រូវបានបញ្ចប់ដូចការរំពឹងទុកនោះទេ។ ការដោះស្រាយបញ្ហាអភិបាលកិច្ចនេះគឺមានសារៈសំខាន់សម្រាប់ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស និងការធានាស្ថិរភាពហិរញ្ញវត្ថុ និរន្តភាព និងកម្លាំងធនធានរបស់គ្រឹះស្ថានឧត្តមសិក្សា។

ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ការរាតត្បាតក៏បានរារាំងដល់ការសិក្សារបស់សិស្សគ្រប់កម្រិតរួមទាំងសិស្សថ្នាក់ឧត្តមសិក្សាផងដែរ។ ជាការឆ្លើយតប ក្រសួងអប់រំ យុវជន និងកីឡា បានសម្របសម្រួលដំណើរការផ្តល់សេវាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដូចជា Microsoft Office 365, Google Meet, Google Classroom, ZOOM និងឧបករណ៍ផ្សេងទៀតដើម្បីជួយសិស្សក្នុងការរៀនសូត្ររបស់ពួកគេ។

### ២.១១.២.៤. កំណែទម្រង់ឧត្តមសិក្សា

កម្ពុជាមិនទាន់ក្លាយជាសង្គមដែលផ្អែកលើចំណេះដឹងនៅឡើយទេ ប៉ុន្តែប្រទេសនេះសង្ឃឹមថានឹងផ្លាស់ប្តូរពីសង្គមដែលពឹងផ្អែកលើកម្លាំងពលកម្មទៅជាសង្គមផ្អែកលើចំណេះដឹង។ ដោយមើលឃើញថាឧត្តមសិក្សានៅកម្ពុជាកំពុងមានការរីកចម្រើន ប្រទេសនេះបានជាប់ចំណាត់ថ្នាក់ទី៧៥ ក្នុងចំណោមប្រទេស១០០ ទាក់ទងនឹងគុណភាពឧត្តមសិក្សា បើយោងតាមរបាយការណ៍ត្រៀមខ្លួនសម្រាប់អនាគតនៃផលិតកម្មឆ្នាំ ២០១៨ ដោយវេទិកាសេដ្ឋកិច្ចពិភពលោក ចំណែកឯប្រទេសផ្សេងទៀតនៅក្នុងតំបន់ ដូចជាប្រទេសឥណ្ឌូនេស៊ីជាប់ចំណាត់ថ្នាក់ទី២៣ ប្រទេសហ្វីលីពីនទី២៧ និងប្រទេសថៃទី២៨។ ក្រៅពីគុណភាព និងលទ្ធផលនៃសាកលវិទ្យាល័យកម្ពុជាក៏នៅខ្វះខាតសមត្ថភាពស្រាវជ្រាវក្នុងវិស័យឧត្តមសិក្សាផងដែរ។ ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់ទី៨ ក្នុងចំណោមសមាជិកអាស៊ានទាំង១០ ទាក់ទងនឹងលទ្ធផលនៃការបោះពុម្ពផ្សាយស្រាវជ្រាវនៅក្នុងឧត្តមសិក្សារវាងឆ្នាំ២០១០ ដល់២០១៩។ ហេតុដូច្នេះហើយ កំណែទម្រង់គឺចាំបាច់ខ្លាំងណាស់ដើម្បីជួយកម្ពុជាសម្រេចបាននូវគោលដៅនេះ។

កំណែទម្រង់ឧត្តមសិក្សាភាគច្រើនក៏ផ្តោត និងឆ្លុះបញ្ចាំងលើការលើកកម្ពស់គុណភាពអប់រំ និងប្រសិទ្ធភាពនៃអភិបាលកិច្ច និងការគ្រប់គ្រងក្នុងឧត្តមសិក្សា។ ដោយទទួលស្គាល់សារៈសំខាន់នៃការអប់រំឧត្តមសិក្សាជាយុទ្ធសាស្ត្រគន្លឹះដើម្បីសម្រេចបាននូវគោលដៅ ក៏ដូចជាតម្រូវការសម្រាប់សមាហរណកម្មក្នុងតំបន់ និងអន្តរ

ជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានណែនាំគោលនយោបាយ និងកំណែទម្រង់សំខាន់ៗមួយចំនួនដូចជា **គោលនយោបាយស្ដីពីចក្ខុវិស័យឧត្ដមសិក្សាឆ្នាំ២០៣០ គោលនយោបាយស្ដីពីអភិបាលកិច្ច និងហិរញ្ញវត្ថុនៃឧត្ដមសិក្សាសម្រាប់កម្ពុជា** និង **ផែនទីបង្ហាញផ្លូវនៅឧត្ដមសិក្សាកម្ពុជាឆ្នាំ២០៣០ និងក្រោយឆ្នាំ២០៣០។** ដើម្បីសម្រេចបាននូវគោលបំណងដែលបានរាយនៅក្នុងគោលនយោបាយទាំងនេះ កម្រិតរចនាសម្ព័ន្ធចំនួនបីត្រូវបានជម្រុញឲ្យធ្វើការរួមគ្នា រួមមានឧត្ដមក្រុមប្រឹក្សាជាតិអប់រំ គណៈកម្មាធិការក្រុមការងារបច្ចេកទេសឧត្ដមសិក្សា និងការអនុវត្តក្រសួង/ស្ថាប័ន/វិទ្យាស្ថាន/មាតាបិតានិងសិស្ស/ដៃគូអភិវឌ្ឍន៍។

នៅឆ្នាំ ២០០៣ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា(គទក) ដែលជាអង្គភាពឯករាជ្យមានភារកិច្ចត្រួតពិនិត្យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាពសិក្សារបស់ស្ថាប័នដែលមានបំណងចង់ផ្ដល់ជំនួយថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិតនៅកម្ពុជា។ គណៈកម្មាធិការនេះក៏បង្កើតគោលនយោបាយ និងបទប្បញ្ញត្តិស្ដីពីការទទួលស្គាល់ដើម្បីបង្កើនគុណភាពនៃគ្រឹះស្ថានអប់រំទាំងអស់នៅក្នុងប្រទេស។

បន្ទាប់ពីការពិនិត្យឡើងវិញនៅពាក់កណ្ដាលអាណត្តិក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលគោលនយោបាយអប់រំ និងពង្រឹងគុណភាពនៃឧត្ដមសិក្សានៅកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡា បានកាត់បន្ថយចំនួនគោលនយោបាយអប់រំពី ៣ ទៅត្រឹម ២ ដើម្បីឲ្យស្របតាម**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤**។ គោលនយោបាយទាំងពីរនោះគឺ (១)ធានាការអប់រំប្រកបដោយគុណភាពបរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប និង (២)ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាក់ថ្នាក់។ លទ្ធផលពីវឌ្ឍនភាពនៃអនុវិស័យបានកត់សម្គាល់ថាការអប់រំឧត្ដមសិក្សាក្រោមគោលនយោបាយទាំងពីរនេះសម្រេចបានលទ្ធផលជាក់លាក់មួយចំនួនដូចជា ភាគរយអាយុនៃសិស្សដែលបានចុះឈ្មោះក្នុងកម្មវិធីស្នែម ចំនួនមជ្ឈមណ្ឌលឧត្ដមភាព ចំនួនគ្រឹះស្ថានឧត្ដមសិក្សាដែលអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុង និងចំនួនគ្រឹះស្ថានឧត្ដមសិក្សាដែលផ្ដល់ទិន្នន័យបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្ដមសិក្សា រីឯវត្ថុបំណងដែលនៅសល់ផ្សេងៗទៀតទំនងជាត្រូវបានសម្រេច។ របាយការណ៍វឌ្ឍនភាពនេះមានសារៈសំខាន់ណាស់ព្រោះវានឹងត្រូវបានប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការណែនាំ និងរៀបចំផែនការថវិកាអនាគតសម្រាប់ការអប់រំឧត្ដមសិក្សា[26]។

[26] អង្គការទិន្នន័យអំពីការអភិវឌ្ឍ, *ការអប់រំកម្រិតឧត្ដមសិក្សា*, https://opendevelopmentcambodia.net/km/topics/higher-education ។

# ជំពូកទី៣
# បញ្ហាប្រឈមរបស់ស្ត្រីនៅកម្ពុជា
# ក្នុងពេលបច្ចុប្បន្ន

# ជំពូកទី៣
# បញ្ហាប្រឈមរបស់ស្ត្រីនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន

## ៣.១. ការជួញដូរស្ត្រី និងក្មេងស្រី

ការជួញដូរស្ត្រី គឺជាសកម្មភាពមួយដែលខុសច្បាប់ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងការលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស(មាត្រា២) និងក្រោមរដ្ឋធម្មនុញ្ញ(មាត្រា៥៦)។ នាពេលបច្ចុប្បន្ននេះ ច្បាប់នេះមានអំណាចផ្តល់ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការចាប់ខ្លួន និងវិនិច្ឆ័យទោសអ្នកជួញដូរមនុស្ស និងផ្តល់នូវការការពារចំពោះជនរងគ្រោះរបស់ខ្លួន។ អាជ្ញាធររាជធានីភ្នំពេញបានបង្កើតគណៈកម្មាធិការចម្រុះមួយ ដើម្បីអនុវត្តគោលការណ៍ណែនាំនៃគោលនយោបាយស្តីពីការបង្ការការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលមានទិសដៅស្វែងរក និងនាំខ្លួនអ្នកជួញដូរមនុស្សទៅវិនិច្ឆ័យទោស។

កម្ពុជា នៅតែប្រឈមនឹងការជួញដូរទៅប្រទេសចិនទាំងខុសច្បាប់ បើទោះបីជាអាជ្ញាធរ មានវិធានការផ្សេងៗក្នុងការរឹតបន្តឹងក្តី។ កាលពីចុងខែមិថុនា ឆ្នាំ២០២១ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានចេញរបាយការណ៍ស្តីពីការជួញដូរមនុស្ស ដោយបានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីពីរក្នុងបញ្ជីប្រឆាំងការជួញដូរមនុស្សសម្រាប់ឆ្នាំ២០១៧។ ចំណែកមន្ត្រីជំនាញផ្នែកប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃបញ្ជាក់ថា ករណីជួញដូរមនុស្សក្នុងរយៈពេល៦ខែដើមឆ្នាំ២០២១ កើនឡើង៣ដង បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២០។ លោកស្រី ម៉ៅ ម៉ាប់ ប្រធានផ្នែកស្ត្រីរបស់សមាគមសិទ្ធិមនុស្សអាដហុក ថ្លែងក្នុងកម្មវិធី Hello VOA ស្តីពីពលករចំណាកស្រុកថា "ការកើនឡើងនៃការជួញដូរមនុស្ស បង្ហាញពីកម្សោយនៃការអនុវត្តការងាររបស់អាជ្ញាធរ"[27]។

អំពើជួញដូរមនុស្ស គឺជាទម្រង់ទាសករមួយប្រភេទ។ កត្តាសំខាន់ដែលប៉ះពាល់ដល់ការជួញដូរស្ត្រីនៅកម្ពុជា គឺភាពក្រីក្រ និងចំណាកស្រុក បញ្ហាទាំង២នេះគឺជាប់ទាក់ទងគ្នាទៅវិញទៅមក។ ក្រៅពីនេះការជួញដូរមនុស្សក៏កើតចេញពីរូបភាពផ្សេងគ្នាទៀតផងដែរ ទៅតាមល្បិចកលរបស់ជនល្មើសធ្វើការបោកបញ្ឆោតជនរងគ្រោះ។

គ្រួសារដែលលំបាកនៅក្នុងជីវភាពរស់នៅ និងភាពក្រីក្រអាចទទួលអារម្មណ៍គាបសង្កត់ឲ្យលក់ដូរកូនស្រីរបស់ខ្លួនដើម្បីសងបំណុលគេដែលគ្រួសារបានជំពាក់។ ក្រោយពេលជួញដូរ ជនរងគ្រោះត្រូវបានគេបង្ខំឲ្យធ្វើការជាទម្ងន់ដើម្បីសងបំណុលរបស់គ្រួសារ។ ជាពិសេសស្ត្រីដែលរស់នៅតំបន់ជិតព្រំដែន ច្រើនតែងាយរងគ្រោះ

[27] កាន់ វិច្ចិកា, *Hello VOA៖ កំណើននៃការជួញដូរមនុស្ស បង្ហាញពីកម្សោយរបស់អាជ្ញាធរ*, https://khmer.voanews.com/a/hello-voa-rising-human-trafficking-in-cambodia-highlights-authorities-weakness/ ។

ដោយត្រូវបានគេជួញដូរក្នុងពេលធ្វើចំណាកស្រុក ដោយស្ត្រីទាំងនោះបានធ្វើដំណើរទៅកាន់តំបន់ផ្សេងៗជាច្រើនដើម្បីស្វែងរកការងារធ្វើ។ ក្នុងពេលធ្វើចំណាកស្រុកនេះ ស្ត្រីច្រើនតែត្រូវគេបោកប្រាស់អំពីការរកការងារធ្វើតាមរយៈមេខ្យល់ដោយសន្យាជួយជូនទៅ ជាថ្នូរនឹងប្រាក់ឈ្នួលនៃការជូនផ្លូវនោះ។ បញ្ហាបែបនេះគេហៅថា "ការជ្រើសរើស"។ ក្នុងករណីដូច្នេះស្ត្រីពុំបានដឹងព័ត៌មានអ្វីទាល់តែសោះ ហើយត្រូវពឹងផ្អែកមេខ្យល់ទាំងស្រុងចំពោះមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ចំណីអាហារ ការងារ និងភាសា។ ត្រង់ចំណុចនេះហើយដែលស្ត្រីតែងតែត្រូវគេជួយញដូរ និងលក់ឲ្យទៅធ្វើការងារដោយបង្ខំ។ ទន្ទឹមនឹងនោះចំណងនៃបំណុលក៏ត្រូវបានកើតឡើងដែរ ដោយគេប្រាប់ជនរងគ្រោះថាខ្លួនបានជំពាក់ប្រាក់មនុស្សដែលជូននាងមកនូវថ្លៃធ្វើដំណើរ និងការចំណាយផ្សេងៗ ហើយដើម្បីដោះបំណុលទាំងអស់នោះនាងត្រូវធ្វើជាស្ត្រីពេស្យា ឬការងារដោយបង្ខំណាមួយ។

ក្រុមជួញដូរមនុស្សច្រើនបោកបញ្ឆោតស្ត្រីដែលងាយរងគ្រោះបំផុតដូចជា ស្ត្រីក្រីក្រ ខ្វះការអប់រំ និងពុំបានដឹងពីសិទ្ធិរបស់អ្នកទាំងអស់នោះជាដើម។ ជាធម្មតាស្ត្រីដែលត្រូវបានជួញដូរច្រើនតែរងគ្រោះពីសំណាក់ការរំលោភលើសិទ្ធិជាច្រើនករណី។ ឧទាហរណ៍ ស្ត្រីរងគ្រោះដែលត្រូវបានលក់ក្នុងអាជីវកម្មផ្លូវភេទច្រើនតែទទួលរងអំពើរំលោភសេពសន្ថវៈជាប្រចាំ។ ទន្ទឹមនឹងនោះនាងក៏ត្រូវរងការវាយដំ ឬមេបនបង្ខំឲ្យប្រើប្រាស់គ្រឿងញៀនដើម្បីធ្វើឲ្យនាងចុះចូលជាមួយគេជានិច្ចហើយមិនរត់គេចទៅណា។ ស្រដៀងគ្នានេះដែរ ស្ត្រីណាដែលគេបង្ខំឲ្យធ្វើការនៅក្នុងផ្ទះក៏អាចងាយរងគ្រោះពីការរំលោភបំពានលើរាងកាយ និងផ្លូវភេទផងដែរពីសំណាក់ថៅកែ និងមនុស្សផ្សេងៗទៀតនៅក្នុងផ្ទះនោះ។ យោងទៅតាមសៀវភៅការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា ឆ្នាំ២០១០ ដែលត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ(NGO-CEDAW) និងគណៈកម្មាធិការស្ត្រីកម្ពុជា(CAMBOW) បានធ្វើការបែងចែករូបភាពនៃការជួយដូរ និងអំពើអាជីវកម្មផ្លូវភេទជា៦រូបភាពដូចតទៅ៖

### ៣.១.១. ការជួញដូរមនុស្សបែបពាណិជ្ជកម្ម

អំពើជួញដូរមនុស្សបែបនេះ ពាក់ព័ន្ធជាការផ្តល់អំណាចគ្រប់គ្រងខុសច្បាប់លើមនុស្សណាម្នាក់ដោយមនុស្សម្នាក់ទៀត ឬជាការទទួលសិទ្ធិគ្រប់គ្រងដោយខុសច្បាប់របស់មនុស្សណាម្នាក់ជាថ្នូរនឹងប្រាក់កាក់។ ក្នុងករណីបែបនេះជនរងគ្រោះច្រើនតែជាស្ត្រី និងកុមារ។

### ៣.១.២. ការបោកតាមរយៈការរកការងារឲ្យធ្វើ

បញ្ហានេះសម្តៅទៅលើការរកការងារធ្វើដោយពួកអ្នកចំណាកស្រុកដែលពុំសូវបានដឹងព័ត៌មានច្រើន។ ជាធម្មតាអំពើជួញដូរមនុស្សបែបនេះកើតឡើងតាមរយៈមេខ្យល់ជាអ្នកដឹកនាំ។

**៣.១.៣. អាពាហ៍ពិពាហ៍ក្លែងក្លាយ**

បញ្ហានេះសម្តៅចំពោះអាពាហ៍ពិពាហ៍របស់នារីខ្មែរ និងបុរសបរទេស ដែលភាគច្រើនឪពុកម្តាយជាអ្នកជម្រុញ ឬមានការយល់ព្រមដោយស្ត្រីផ្ទាល់ក៏មាន ប៉ុន្តែស្ត្រីដែលរៀបការនោះពុំសូវបានដឹងព័ត៌មានច្បាស់លាស់អំពីបញ្ហាដែលកើតឡើងចំពោះខ្លួនឯងក្រោយអាពាហ៍ពិពាហ៍នោះឡើយ។ ជាធម្មតាបញ្ហានេះកើតឡើងតាមរយៈមេខ្យល់ដូចគ្នា។

**៣.១.៤. សុំកូន**

សម្តៅលើបញ្ហាដែលកុមារតូចៗ ជាពិសេសកុមារី ដែលត្រូវបានគេសុំយកទៅធ្វើជាកូនចិញ្ចឹមហើយក្រោយមកត្រូវបានគេយកទៅរំលោភ ឬយកទៅលក់ឲ្យធ្វើជាស្ត្រីបំរើការកំសាន្ត ឲ្យធ្វើការងារ ឬអាចយកទៅវះកាត់យកសរីរាង្គណាមួយក៏មាន។

**៣.១.៥. អាជីវកម្មលើពលកម្មកុមារ**

សម្តៅទៅលើការបង្ខិតបង្ខំកុមារឲ្យធ្វើការងារដោយគ្មានប្រាក់ឈ្នួល ឬធ្វើការដើម្បីសងបំណុលឪពុកម្តាយក្នុងករណីនេះកុមារអាចបាត់បង់ឱកាសរៀនសូត្រ និងសេចក្តីសុខ ព្រមជាមួយភាពកក់ក្តៅនៅក្នុងវ័យកុមារ។

**៣.១.៦. អំពើហិង្សាក្នុងគ្រួសារ**

សម្តៅលើស្ថានភាពដែលកុមារចាកចេញពីផ្ទះសំបែង ដោយសារអំពើហិង្សានៅក្នុងគ្រួសារ ដែលវាជាហេតុនាំឲ្យកុមារអាចរងគ្រោះដោយអំពើជួញដូរជាដើម។ ជាពិសេសកុមារីអាចត្រូវបានជួញដូរដើម្បីធ្វើអាជីវកម្មផ្លូវភេទ។ បុរសស្ត្រី និងកុមារកម្ពុជា ត្រូវបានគេលក់ដូរក្នុងអាជីវកម្មផ្លូវភេទ និងអាជីវកម្មខាងកម្លាំងពលកម្មទៅប្រទេសថៃ ម៉ាឡេស៊ី ម៉ាកាវ និងតៃវ៉ាន់ជាដើម។ ក្នុងបញ្ហាបែបនេះស្ត្រីដែលត្រូវបានគេយកទៅបម្រើតាមផ្ទះ ច្រើនតែត្រូវបង្ខំឲ្យរួមភេទជាមួយម្ចាស់ផ្ទះ។ ចំណែកឯបុរសវិញភាគច្រើនត្រូវបានគេលក់ដូរឲ្យធ្វើជាកម្មករនេសាទ សំណង់ និងវិស័យឧស្សាហកម្មផ្សេងៗដោយបង្ខំ។ កម្ពុជាគឺជាចំណុចឆ្លងកាត់សម្រាប់មនុស្សដែលត្រូវគេជួញដូរពីវៀតណាមទៅប្រទេសថៃ និងជាចំណុចគោលដៅដែលត្រូវជួញដូរពីវៀតណាមទៅចិន។

អំពើជួញដូរក្នុងប្រទេស ក៏ជាបញ្ហាមួយដ៏គួរឲ្យចាប់អារម្មណ៍ផងដែរ។ មានករណីជួញដូរស្ត្រី និងកុមារជាច្រើនពីជនបទមកទីក្រុងក្នុងគោលបំណងដើម្បីអាជីវកម្មផ្លូវភេទ។ ក្នុងករណីជាច្រើនកុមារត្រូវបានគ្រួសារលក់ ឬចាញ់បោកគេថាយកទៅធ្វើការជាអ្នកបម្រើក្នុងផ្ទះ ប៉ុន្តែក្រោយមកត្រូវបានគេបង្ខំឲ្យធ្វើជាទាសករផ្លូវភេទទៅវិញ។

ទាក់ទងទៅនឹងទណ្ឌកម្មទៅលើជនល្មើសដែលបានប្រព្រឹត្តការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទគឺត្រូវទទួលទោសតាមការអនុលោមនៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួយដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលត្រូវ

បានអនុម័តដោយសភាកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំសភាលើកទី៧ នីតិកាលទី៣ ហើយព្រឹទ្ធសភាយល់ស្របទាំងស្រុងដោយគ្មានការកែប្រែទាំងស្រុង[28]។

## ៣.២. អំពើហិង្សាប្រឆាំងនឹងស្ត្រី

### ៣.២.១. អំពើហិង្សាផ្លូវកាយ

អំពើហិង្សាក្នុងគ្រួសារ គឺជាគម្រូនៃឥរិយាបទដែលជាប់ពាក់ព័ន្ធនឹងអំពើហិង្សាឬការរំលោភបំពានផ្សេងទៀតដោយមនុស្សម្នាក់ប្រឆាំងនឹងការផ្សេងទៀតនៅក្នុងការកំណត់ក្នុងគ្រួសារ ដូចជានៅក្នុងអាពាហ៍ពិពាហ៍ ឬដែលមានចរិកលក្ខណៈជាការប្រមាថមាក់ងាយ ការរំលោភការបំពាន ការគំរាមគំហែងលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និង ផ្លូវសេដ្ឋកិច្ច ដល់មនុស្សណាម្នាក់ក្រុមណាមួយ ហើយដែលបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ដើម្បីត្រួតត្រាទៅលើមនុស្សផ្សេងៗទៀតដែលកំពុងរស់នៅក្នុងគ្រួសារនោះ។ ក្រុមគ្រួសារ ឬបុគ្គលដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារមានរបួសពីររបួសរាងកាយនិងផ្លូវចិត្ត ដែលអាចមានផលប៉ះពាល់ជាច្រើននៅលើចិត្ត រាងកាយ និងស្មារតី។ វាគឺជាធម្មជាតិដើម្បីទទួលយកបទពិសោធន៍ទាំងនេះ និងការទទួលស្គាល់ផលប៉ះពាល់អាចជាជំហានដំបូងសំខាន់ក្នុងការផ្តោតលើដំណើរការឆ្ពោះទៅរកការស្តារ និងការព្យាបាលមួយ។

### ៣.២.២. អំពើហិង្សាផ្លូវចិត្ត

ជាសកម្មភាពទាំងឡាយណា ដែលធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់គេ ហើយមិនអាចទទួលយកបានដូចជា ការប្រើពាក្យសម្តីជេរប្រមាថ គម្រាមកំហែង បំបិទសិទ្ធិសេរីភាព ។ល។

ស្ថានភាពប្រទេសកម្ពុជាដូចនឹងប្រទេសជាច្រើនទៀតផងដែរ អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាផ្ទៃក្នុងមួយដែលជះឥទ្ធិពលជាអវិជ្ជមានទៅលើការរស់នៅរបស់ជនរងគ្រោះ ក៏ប៉ុន្តែករណីនេះវាមិនដូចគ្នានឹងប្រទេសដទៃទៀតទេ ពីព្រោះប្រទេសកម្ពុជាបង្កើតក្រមសីលធម៌មួយតាំងពីបុរាណមួយដែលហៅថា "ច្បាប់" ដែលច្បាប់នេះស្ត្រីត្រូវតម្រូវឲ្យគោរពគោរពប្រណិបត្តិប្តីរបស់ខ្លួន មិនថាពេលណានោះទេ។ ច្បាប់នេះនៅមានបង្រៀនក្នុងកម្មវិធីសិក្សាដល់នារីនៅឡើយ ហើយជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថចំពោះសិទ្ធិស្ត្រី។ ច្បាប់នេះផ្តល់ដំបូន្មានដូចជា "*មិនត្រូវទូលពិតដល់ឪពុកម្តាយរបស់អ្នកអំពីប្តីរបស់អ្នកឡើយ បើមិនដូច្នេះទេរឿងនេះនឹងដឹងឮខ្ចរខ្ចាយពេញភូមិមិនខាន* " និង "*មិនត្រូវគេងបែរខ្នងដាក់ប្តីរបស់អ្នកឡើយនៅពេលដែលប្តីរបស់អ្នកកំពុងសំរាន្ត និងមិនត្រូវប៉ះក្បាលរបស់ប្តីដោយមិនឱនលំទោនជាមុនឡើយ។ ត្រូវមានការអត់ធ្មត់បង្ហាញនូវការអត់ធ្មត់របស់អ្នក និងមិនត្រូវតមាត់ករជាមួយប្តីឡើយនៅពេលប្តីរបស់អ្នកខឹងសម្បា* "។ ផ្អែកតាមវប្បធម៌ និងប្រពៃណី បើស្ត្រីណា

[28] អ៊ុំ ច័ន្ទលក្ខិណា, *តើការជួញដូរ និងអាជីវកម្មផ្លូវភេទកើតមានក្នុងរូបភាពដូចម្តេចខ្លះ?* , https://wmc.org.kh/article ។

ព្យាយាមអនុវត្តតាមច្បាប់នេះឲ្យបានខ្ជាប់ខ្ជួននោះ នាងនឹងទទួលបាននូវការសរសើរជាមិនខាន។ ផលវិបាកនៃក្រមសីលធម៌នេះ គឺថាស្ត្រីកម្ពុជាដែលទទួលរងនឹងអំពើហិង្សាក្នុងគ្រួសារនឹងមិនពិភាក្សាអំពីបញ្ហារបស់ខ្លួនជាមួយអ្នកដទៃឡើយ ពីព្រោះពួកគេគិតថាបញ្ហាក្នុងគ្រួសារនេះ គួររក្សាជារឿងឯកជន។

ដោយសារតែការរក្សាប្រពៃណីនេះ របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ជូនទៅគណៈកម្មាធិការ មិនបានរៀបរាប់ច្រើនអំពីអំពើហិង្សាក្នុងគ្រួសារ។ យ៉ាងណាមិញអំពើហិង្សាក្នុងគ្រួសារ គឺជាកត្តាចម្បងមួយដែលរួមចំណែកធ្វើឲ្យមានវិសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ បើទោះជាគ្មានតួលេខច្បាស់លាស់អំពីចំនួនជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏របាយការណ៍មួយស្តីពីអំពើហិង្សាដែលគ្រោងនឹងបោះពុម្ពផ្សាយ ដែលបានរៀបចំឡើងដោយក្រសួងកិច្ចការនារី បានធ្វើការអង្កេតទៅលើប្រជាជនចំនួន ៣០០០នាក់ នៅក្នុងខេត្តចំនួន១៣ ដែលទាក់ទងទៅនឹងឥរិយាបថរបស់ពួកគេចំពោះអំពើហិង្សាក្នុងគ្រួសារ។ អស់រយៈពេលជាច្រើនឆ្នាំមកនេះ មានរបាយការណ៍រាប់ពាន់ករណី ស្តីពីការរំលោភបំពាន និងការប្រើអំពើហិង្សាក្នុងគ្រួសារ។ ទោះជាយ៉ាងនេះក្តីតួលេខទាំងនេះមិនបានបង្ហាញឲ្យបានសុក្រឹត្យអំពីតថភាពនៃអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកម្ពុជា ដោយសារតែមានរបាយការណ៍មិនត្រឹមត្រូវដោយជនរងគ្រោះ។ ស្ត្រីប្រឈមមុខនឹងការអាម៉ាស់ និងការបាត់បង់កិត្តិយសនៅក្នុងការស្វែងរកជំនួយពីខាងក្រៅ ហើយជនរងគ្រោះស៊ូបៀមទុក្ខនូវការឈឺចាប់នេះ។ បញ្ហាមួយចំនួនទៀត ដូចជាការបាត់បង់ការជឿទុកចិត្តលើមន្ត្រីផ្នែកច្បាប់ និងមន្ត្រីតុលាការនៅប្រទេសកម្ពុជា អាចជាកត្តាមួយធ្វើឲ្យស្ត្រីមិនហ៊ានរាយការណ៍អំពីការរំលោភបំពាន និងការប្រើអំពើហិង្សាក្នុងគ្រួសារ និងផលវិបាកដែលកើតមានឡើង។ ដូចនេះមានតែរាជរដ្ឋាភិបាល និងសង្គមស៊ីវិលទេដែលជាអ្នកមានតួនាទីសំខាន់ ក្នុងការទទួលបន្ទុកចំពោះការអប់រំ និងការគាំទ្រមតិទៅលើអ្វីមួយ ព្រមទាំងការពារពួកគេទប់ទល់នឹងអំពើហិង្សាទាំងឡាយដែលកើតមានឡើងចំពោះខ្លួនគេ តាមរយៈការចុះតាមដាន និងអង្កេតដើម្បីស្រាវជ្រាវរកជនល្មើសមកផ្តន្ទាទោសតាមផ្លូវច្បាប់ក្នុងបំណងដើម្បីឲ្យរាងចាល។

### ៣.២.៣. អំពើហិង្សាផ្លូវភេទ

#### ៣.២.៣.១. ការរំលោភសេពសន្ថវៈជាទូទៅ

រំលោភសេពសន្ថវៈ សម្តៅលើ គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស[29]។

[29] ក្រសួងយុត្តិធម៌,ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២៣៩ វាក្យខណ្ឌទី១ (ឆ្នាំ២០០៩)។

ចន្លោះពីដើមឆ្នាំ២០១២ ដល់ចុងឆ្នាំ២០១៤ អង្គការលីកាដូ បានស៊ើបអង្កេត៧៦២ករណីនៃករណីរំលោភសេពសន្ថវៈ ឬបទប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលពាក់ព័ន្ធនឹងជនរងគ្រោះចំនួន៧៩៣នាក់។ ភាគច្រើននៃជនរងគ្រោះទាំងនេះមានអាយុក្រោម១៨ឆ្នាំ ដោយចំនួនមួយភាគធំស្ថិតក្នុងក្រុមអាយុពី១២ឆ្នាំ ទៅ ១៧ឆ្នាំ។ ជនរងគ្រោះ៥៨នាក់ ស្ថិតក្រោមអាយុ៦ឆ្នាំ(៧ភាគរយ) ១១៨នាក់មានអាយុពី៦ ទៅ ១១ឆ្នាំ(២៣ភាគរយ) ៣២៨នាក់អាយុពី១២ ទៅ ១៧ឆ្នាំ(៤១ភាគរយ) និង ២២៦នាក់មានអាយុពី១៨ឆ្នាំឡើងទៅ(២៩ភាគរយ)។

គិតត្រឹមខែសីហា ឆ្នាំ២០១៥ ក្នុងចំណោម ៧៦២ករណីដែលទទួលបាន មានចំនួន៤២៤ករណីត្រូវបានបញ្ចប់។ ត្រឹម ១/៣ប៉ុណ្ណោះនៃករណីនេះ ត្រូវបានបញ្ចប់ដោយការផ្តន្ទាទោសអំពីបទល្មើសរំលោភសេពសន្ថវៈ និងដាក់ទោសឲ្យជាប់ពន្ធនាគារ ដែលគោរពទៅតាមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។ ចំណែក ២/៣ទៀត ដែលនៅសេសសល់នៃករណីទាំងនេះ ត្រូវបានបិទមុនការជំនុំជម្រះក្តី ឬបញ្ចប់ដោយការផ្តន្ទាទោសមិនត្រឹមត្រូវ ឬការសម្រេចឲ្យដោះលែងតែម្តង។

ក្នុងចំណោមករណីជាច្រើន ដែលត្រូវបានបិទមុនពេលជំនុំជម្រះក្តីមានច្រើនជាងពាក់កណ្តាល(៧២ករណី) ត្រូវបានបិទនៅពេលដែលជនរងគ្រោះបានធ្វើការដកពាក្យបណ្តឹងព្រហ្មទណ្ឌ បន្ទាប់ពីជនសង្ស័យបានបង់ប្រាក់សំណង។ ៥២ករណី ក្នុងចំណោមករណីទាំងនោះ អង្គការលីកាដូបានទទួលព័ត៌មានទាក់ទងនឹងអ្នកដែលពាក់ព័ន្ធនៅក្នុងការចចារសំណង៖ សំណង ៤៣ករណីត្រូវបានចចារដោយនគរបាល ៦ករណីត្រូវបានចចារដោយព្រះរាជអាជ្ញា និង ៣ករណីត្រូវបានចចារដោយចៅក្រមស៊ើបសួរ។ អ្នកឃ្លាំមើលអង្គការលីកាដូ ជឿជាក់ថាស្ទើរតែ១០០ភាគរយនៃករណីត្រូវបានដោះស្រាយដោយការផ្តល់សំណង គឺមានពាក់ព័ន្ធនឹងការបង់ប្រាក់ក្រៅច្បាប់របស់ជនសង្ស័យទៅឲ្យមន្ត្រីរាជការ។

ជនរងគ្រោះជ្រើសរើសបញ្ចប់រឿងក្តីដោយសំណង ដោយសារហេតុផលមួយចំនួន។ ដោយសារភាពអាម៉ាស់ ដែលបានលើកឡើងពីការរំលោភ ស្ត្រីជាច្រើនចង់ធានាថា មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះបានដឹងអំពីករណីរបស់ពួកគាត់។ វិធីមួយដើម្បីធ្វើបែបនេះ គឺការចចាររកដំណោះស្រាយមួយយ៉ាងឆាប់រហ័សដោយមិនចាំបាច់ចូលទៅតុលាការនោះទេ។ កត្តាទីពីរ គឺការចំណាយ និងផលលំបាកជាក់ស្តែងនៃការបន្តករណីតាមរយៈតុលាការ។ ប្រជាជនកម្ពុជាភាគច្រើនបានដឹងថា អំពើពុករលួយមួយចំនួនកើតមាននៅក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌ ហើយបានដឹងថា អ្នកទាំងនោះនឹងមិនអាចមានលទ្ធភាពបង់ប្រាក់ក្រៅផ្លូវការណ៍ដែលទាមទារឲ្យពួកគាត់ធ្វើការបង់នៅក្នុងដំណើរការទាំងមូលបាននោះទេ។ ជាចុងក្រោយ ក្នុងករណីដែលជនល្មើសមានតួនាទីសំខាន់ និងអំណាច ជនរងគ្រោះអាចមានអារម្មណ៍ថាគាត់ត្រូវបានបង្ខំឲ្យបញ្ចប់រឿងក្តី ដោយ

ការគម្រាមកំហែងពីខាងក្រៅ ឬពីខាងក្នុងថាជនសង្ស័យអាចនឹងចាត់វិធានការសងសឹក ប្រសិនបើជនរងគ្រោះមិនធ្វើការបញ្ចប់រឿងក្តីនោះទេ[30]។

### ៣.២.៣.២. ការរំលោភសេពសន្ថវៈដោយសាច់ញាតិ

ការរំលោភសេពសន្ថវៈដោយសាច់ញាតិកើតមានឡើងច្រើននៅក្នុងប្រទេសកម្ពុជា ហើយប្រព័ន្ធច្បាប់នៅតែមិនទាន់ជោគជ័យក្នុងការការពារមនុស្សជាច្រើន ដែលមានបទពិសោធន៍ទទួលរងការរំលោភបំពាន។ ជិត១/៣នៃករណីរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈទាំងអស់ដែលត្រូវបានសិក្សាស្រាវជ្រាវដោយសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស(អង្គការលីកាដូ) ចាប់ពីខែមករា ឆ្នាំ២០១៧ ដល់ខែធ្នូ ឆ្នាំ២០១៩ មានជាប់ពាក់ព័ន្ធនឹងជនសង្ស័យដែលជាសាច់ញាតិរបស់ជនរងគ្រោះ ដែលបានរាយការណ៍ថាបានទទួលរងការរំលោភបំពាន[31]។

ក្នុងចំណោមបទរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈសរុបចំនួន៤៤៦ករណី ដែលត្រូវបានសិក្សាស្រាវជ្រាវក្នុងរយៈពេល៣ឆ្នាំ មាន៨៨ករណី ដែលជាប់ពាក់ព័ន្ធនឹងស្ត្រីអាយុចាបពី១៨ឆ្នាំឡើងទៅ(២០ភាគរយ) និងចំនួន៣៥៨ករណីជាប់ពាក់ព័ន្ធនឹងកុមារអាយុក្រោម១៨ឆ្នាំ(៨០ភាគរយ)។ ជនសង្ស័យ គឺជាសាច់ញាតិរបស់ជនរងគ្រោះ ដែលបានរាយការណ៍ថា ខ្លួនបានទទួលរងអំពើហិង្សាផ្លូវភេទ នៅក្នុង១៣៧ករណីនៃករណីសរុបទាំងនេះ(៣១ភាគរយ)។ ខណៈអង្គការលីកាដូធ្វើអន្តរាគមន៍ករណីដែលពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើស្ត្រី និងក្មេងស្រី និងក្មេងប្រុស ដោយមិនគិតពីភេទរបស់ជនសង្ស័យ។ ជនសង្ស័យសុទ្ធតែជាបុរស ឬក្មេងប្រុស ដែលត្រូវបានរាយការណ៍មកថា បានរំលោភបំពានលើស្ត្រី ឬក្មេងស្រីនៅក្នុងគ្រប់ករណីនៃករណីចំនួន១៣៧នេះ។ នេះអាចជាលទ្ធផលនៃឧបសគ្គចម្បងក្នុងការរាយការណ៍ ដែលស្ត្រីពេញវ័យ និងក្មេងប្រុសទាំងនេះបានជួបប្រទះ ទោះបីជាមិនទាំងស្រុងក្តី។ ប្រហែលជាពាក់កណ្តាលនៃស្ត្រី និងក្មេងស្រីនៅក្នុងករណីទាំងនេះ(៤៦ភាគរយ) បានរាយការណ៍ពីការរំលោភបំពានដោយសាច់ញាតិលោហិត និង(៥៤ភាគរយ)បានរាយការណ៍ពីការរំលោភបំពានដោយញាតិលោហិតផ្សេងទៀត ដូចជាសាច់ថ្លៃ ឬសាច់ញាតិខាងឪពុក ឬម្តាយចុង។

ឧបសគ្គដែលចាក់ឫស និងមានជាយូរណាស់មកហើយក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើងចំពោះស្ត្រី និងក្មេងស្រីដែលត្រូវបានរងអំពើរំលោភសេពសន្ថវៈដោយសាច់ញាតិរបស់ខ្លួន។ អ្នកទាំងនេះត្រូវព្យាយាមប្រឈមនឹងសម្ពាធគ្រួសារ ដែលជាឧបសគ្គបន្ថែមដោយមិនត្រូវអើពើចំពោះអំពើហិង្សាផ្លូវភេទ និងជារឿយៗមានការពឹងផ្អែក

[30] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ,ការរួចខ្លួនពីបទល្មើស៖ ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈក្នុងប្រព័ន្ធតុលាការកម្ពុជា (ឆ្នាំ២០១៥)។

[31] សាច់ញាតិ រួមមាន ញាតិលោហិត សាច់ថ្លៃ និងសាច់ញាតិខាងឪពុក ឬម្តាយចុង។

ផ្នែកហិរញ្ញវត្ថុលើជនល្មើស។ ទោះបីជារស់នៅជិតសាច់ញាតិក៏ដោយ ក៏ស្ត្រី និងក្មេងស្រីតិចតួចណាស់ ទទួលបានការការពារខ្លួនពីជនសង្ស័យដែលអាចផ្តល់ជូន និងទៅតាមភាពជាក់ស្តែងក្នុងកំឡុងពេល និងក្រោយដំណើរការតាមផ្លូវច្បាប់។ កត្តាទាំងនេះផ្តល់ការលំបាកដល់ការរាយការណ៍ពីករណីរំលោភសេពសន្ថវៈ និងជម្រុញឲ្យមនុស្សភាគច្រើនដកពាក្យបណ្តឹងរដ្ឋប្បវេណីវិញ ឬទុកសំណុំរឿងចោលឥតចាត់ការ។ ជាលទ្ធផលនៃភាពខ្វះចន្លោះរបស់ប្រព័ន្ធតុលាការដើម្បីកាត់ទោសបទល្មើសរំលោភសេពសន្ថវៈឲ្យបានត្រឹមត្រូវ ស្ត្រី និងក្មេងស្រីជាច្រើនដែលត្រូវបានរំលោភសេពសន្ថវៈដោយសាច់ញាតិរបស់ខ្លួន ត្រូវផ្លាស់ទៅរស់នៅកន្លែងផ្សេង ដែលនេះជាការខិតខំប្រឹងប្រែងមួយដើម្បីរស់នៅជៀសឲ្យផុតពីអំពើហិង្សា។

បញ្ហារំលោភសេពសន្ថវៈដោយសាច់ញាតិ ទើបតែក្លាយជាបញ្ហាធ្ងន់ធ្ងរ ដោយសារតែការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលធ្វើឲ្យមនុស្សចំណាយពេលវេលាច្រើននៅផ្ទះ ដែលជម្រុញឲ្យពួកគាត់ភាគច្រើនកាន់តែនៅជិតនឹងជនល្មើស។ ប្រទេសកម្ពុជា មិនបានឈានដល់ការបិទប្រទេសទាំងស្រុងនោះទេ ប៉ុន្តែសាលារៀននៅទូទាំងប្រទេសបានបិទចាប់ពីខែមីនា ដល់ខែធ្នូ ឆ្នាំ២០២០ ដោយទុកឲ្យកុមារជាច្រើនត្រូវនៅផ្ទះ។ អ្នកផ្សេងទៀតក៏បានចំណាយពេលវេលាច្រើននៅផ្ទះដូចគ្នាដែរ ដោយសារការវិលត្រលប់មកពីប្រទេសជិតខាង ឬដោយសារកំណើននៃភាពអត់ការងារធ្វើ។

របាយការណ៍នេះគឺផ្អែកលើតែតួលេខនៃករណីដែលបានទទួល និងសិក្សាស្រាវជ្រាវដោយបុគ្គលិករបស់អង្គការលីកាដូប៉ុណ្ណោះ ហើយមិនឆ្លុះបញ្ចាំងពីការរីកសាយកាន់តែទូលំទូលាយនៃករណីរំលោភសេពសន្ថវៈ និងអំពើបំពានផ្លូវភេទ នៅក្នុងប្រទេសកម្ពុជាទាំងមូលនោះទេ[32]។

## ៣.៣. ទំនៀមទម្លាប់ប្រពៃណី

ទំនាក់ទំនងរវាងបុរសនិងស្ត្រីនៅប្រទេសកម្ពុជា ត្រូវបានគេគិតថាស្មើភាពគ្នា ដូចគ្នានឹងបណ្តាប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍។ ក្នុងខណៈដែលបុរសទទួលបាននូវឋានៈ និងតួនាទីជាមេគ្រួសារ ស្ត្រីក៏មានភាពឯករាជ្យ និងភាពជាម្ចាស់ការនៅក្នុងការធ្វើជាកម្មសិទ្ធិករលើទ្រព្យសម្បត្តិផ្សេងៗដូចជា ដីធ្លី ការចាត់ចែងហិរញ្ញវត្ថុ និងការបញ្ចេញយោបល់ក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗនៅក្នុងគ្រួសារ។ ទាំងបុរសនិងស្ត្រី អាចទទួលបានកេរ្តិ៍មរតកដីស្រែ ដីភូមិ និង ផ្ទះ ហើយបុរសនិងស្ត្រី ធ្វើការងារដែលបំពេញឲ្យគ្នាទៅវិញទៅមក និងចូលរួមដូចគ្នាក្នុងការងាររកប្រាក់ចំណូលផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ ប្រពៃណីរបស់សង្គមកម្ពុជាបានរួមចំណែកក្នុងការបង្កើនឲ្យមានវិសមភាពរវាងបុរស និងស្ត្រី។ តាមទំនៀមទម្លាប់ប្រពៃណីស្ត្រីមានឋានៈទាប

[32] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ, ទម្លាយភាពស្ងៀមស្ងាត់៖ ការរំលោភសេពសន្ថវៈដោយសាច់ញាតិ និងឧបសគ្គក្នុងការទទួលបានយុត្តិធម៌នៅកម្ពុជា(ខែធ្នូ ២០២០) ។

ជាងបុរស ទទួលបានការអប់រំតិចជាង និងពុំសូវបានចូលរួមក្នុងសេចក្តីសម្រេចជាសាធារណៈផ្សេងៗ ក្រៅពីការងារក្នុងគ្រួសារឡើយ។

នៅក្នុងសាសនា និងប្រពៃណីវប្បធម៌កម្ពុជា ស្ត្រីទទួលបាននូវស្ថានភាពទាបជាងបុរស។ នៅក្នុងព្រះពុទ្ធសាសនា ស្ត្រីត្រូវបានគេចាត់ទុកថា ជាអ្នកដែលទទួលបានផលបុណ្យតិចតួចពីជាតិមុន មិនត្រូវអនុញ្ញាតបួសជាព្រះសង្ឃឡើយ។ ស្ត្រីមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនិងសម្ភារៈ ដោយសារស្ត្រីមានតួនាទីក្នុងការចាត់ចែងចំណូលចំណាយថវិកា និងមើលការខុសត្រូវក្នុងការចិញ្ចឹមសត្វដូចជា ជ្រូក មាន់ ទា ជាដើម។ តួនាទី និងឥរិយាបថមានចែងនៅក្នុងច្បាប់ស្រី និងច្បាប់ប្រុស(ច្បាប់ទូន្មានសម្រាប់ស្ត្រី និងបុរស)។ ច្បាប់នេះបានផ្តល់បុរសនូវឋានៈ និងតួនាទីខ្ពស់ និងអំណាចជាមេគ្រួសារ ហើយទូន្មានដល់ស្ត្រីឲ្យមានការស្មោះត្រង់ដល់ខ្លួនស្តាប់បង្គាប់ និងទ្រាំទ្រនូវរាល់ការប្រព្រឹត្តរបស់ស្វាមីខ្លួន។ ស្ត្រីវ័យក្មេងដែលពុំទាន់រៀបការ ត្រូវការពារកិត្តិយសរបស់ខ្លួន និងគ្រួសារ គឺត្រូវនៅផ្ទះស្តាប់ការទូន្មានប្រៀនប្រដៅពីសមាជិកគ្រួសារ និងមិនត្រូវមានទំនាក់ទំនងជាមួយបុរសនៅក្រៅគ្រួសារឡើយ។ ចំណែកស្ត្រីដែលរៀបការរួចត្រូវគេរំពឹងថា មានគំនិតចាស់ទុំ មានភាពប៉ិនប្រសប់ក្នុងការប្រកបរបរចិញ្ចឹមជីវិត និងគ្រប់គ្រងការពារផលប្រយោជន៍គ្រួសារ។

តាមទំនៀមទម្លាប់នេះ ការប្រព្រឹត្តរបស់ស្ត្រីមានភាពខុសគ្នានៅតាមដំណាក់កាលនៃជីវិត ឧទាហរណ៍ស្ត្រីក្មេងនៅលីវត្រូវមានភាពម្យទម និងមានភាពអៀនខ្មាស់ច្រើន ហើយក្រោយមកនៅពេលក្លាយជាភរិយា ឬមាតាគេ ស្ត្រីនោះត្រូវបានគេរំពឹងទុកជាអ្នកមានវោហារក្នុងការចរចារ ការប្រកបរបរ និងផ្តល់ទីប្រឹក្សាដល់ស្វាមីរបស់ខ្លួនប៉ុណ្ណោះ មិនត្រូវជជីកសួរ ឬប្រឆាំងស្វាមីនៅទីសាធារណៈឡើយ។

ការផ្លាស់ប្តូរលក្ខខណ្ឌសង្គម និងសេដ្ឋកិច្ច ធ្វើឲ្យស្ត្រីមានការលំបាកក្នុងការគោរពប្រពៃណីនេះ។ ស្ត្រីកាន់តែច្រើនរកការងារធ្វើនៅក្រៅផ្ទះ និងធ្វើដំណើរទៅឆ្ងាយដើម្បីប្រកបរបរចិញ្ចឹមជីវិត ហើយក្មេងស្រី និងក្មេងប្រុសរៀនថ្នាក់ជាមួយគ្នាសាលា។ ការផ្លាស់ទាំងនេះក៏បានបង្កើតឡើងនូវភាពជាស្ត្រីទាន់សម័យ ដែលគេសង្កេតឃើញកើតមានឡើងនៅសង្គមកម្ពុជា ជាពិសេសក្នុងតំបន់ទីប្រជុំជន។ ទោះជាយ៉ាងណាក៏ដោយ ក៏ទំនៀមទម្លាប់ប្រពៃណីនៅតែមានឥទ្ធិពលលើស្ត្រី ដោយរំពឹងថាស្ត្រីថែរក្សាភាពក្រមុំរបស់ខ្លួនដល់ថ្ងៃរៀបការ និងភាពស្មោះត្រង់ចំពោះស្វាមីដើម្បីការពារកិត្តិយសគ្រួសារ។ ស្ត្រីជាច្រើន ជាពិសេសស្ត្រីវ័យក្មេងនៅទីប្រជុំជន និងស្ត្រីដែលទើបរស់នៅទីក្រុងដើម្បីធ្វើការងារ គេតែងព្យាយាមធ្វើឲ្យតុល្យភាពជាមួយតម្លៃវប្បធម៌ប្រពៃណី ដោយធ្វើយ៉ាងណាកុំឲ្យក្លាយខ្លួនជាស្ត្រីសម័យថ្មី(គឺជាស្ត្រីដែលមានការងារធ្វើដោយខ្លួនឯង ស្លៀកពាក់ម៉ូដរបស់ប្រទេសលោកខាងលិច និងដើរលេងជាមួយមិត្តភក្តិជាដើម) ដោយមិនធ្វើដំណើរទៅឆ្ងាយពេក ឬមិនចង់ក្លាយខ្លួនជាស្ត្រីដែលទាន់សម័យហួសពេក។ ស្ត្រីដែលពុំអាចគោរពតាមទំនៀមទម្លាប់ប្រពៃណីបានខ្ជាប់ខ្ជួនឡើយពីព្រោះកាលៈទេសៈ និងស្ថានភាពរបស់សង្គមមានការផ្លាស់ប្តូរ មនុស្សកាន់តែច្រើនទទួលបាននូវការអប់រំ និង

ទទួលបានការងារដែលមានប្រាក់ឈ្នួល ប៉ុន្តែទំនៀមទម្លាប់ប្រពៃណីដែលមានចែងនៅក្នុងច្បាប់ស្រី នៅតែមាននៅក្នុងផ្នត់គំនិតរបស់ស្ត្រី ជាពិសេសស្ត្រីក្នុងចំណោមវ័យចំណាស់នៅតាមជនបទក្នុងការឲ្យតម្លៃទៅលើអ្វីដែលគេហៅថា កូនស្រីល្អ ភរិយាល្អ និង មាតាល្អ។

មិនខុសគ្នាពីនេះដែរ ទំនៀមទម្លាប់ និងការរើសអើងរបស់សង្គមពាក់ព័ន្ធនឹងការរួមភេទរបស់ស្ត្រីមុនពេលរៀបការ បានធ្វើឲ្យស្ត្រីភាគច្រើនពុំហ៊ានសារភាពថាខ្លួនមានដៃគូរួមភេទច្រើនលើសពីមួយនាក់ឡើយ។ ស្ត្រីដែលមានអាយុចន្លោះពី១៥-៤៩ឆ្នាំ ចំនួនតែ០.៣ភាគរយ បាននិយាយថា ពួកគេបានរួមភេទជាមួយដៃគូពីរនាក់ ឬលើសពីពីរនាក់ក្នុងឆ្នាំកន្លងមក។ ១/៣ នៃយុវវ័យក្មេងដែលពុំទាន់រៀបការចំនួន១១.៥ភាគរយ បាននិយាយថាកន្លងមកពួកគេបានរួមភេទជាមួយមិត្តស្រីរបស់ពួកគេ។ នេះបង្ហាញឲ្យឃើញថាអត្រារួមភេទមុនរៀបអាពាហ៍ពិពាហ៍ក្នុងចំណោមយុវជនក្មេងៗមិនទាន់រៀបការទំនងជាមានកម្រិតខ្ពស់ជាងតួលេខដែលបានបង្ហាញខាងលើ នេះដូចគ្នាទៅនឹងរបាយការណ៍របស់អង្គការមួយចំនួនដែលធ្វើការក្នុងផ្នែកសុខភាពរបស់យុវវ័យ។ ចំពោះស្ត្រីដែលជ្រុលជ្រួសធ្វើខុសទំនៀមទម្លាប់ នឹងត្រូវទទួលការរិះគន់បាត់បង់កិត្តិយស បាត់បង់ការគោរពពីអ្នកដទៃ ឬទទួលរងការបណ្តេញចេញពីគ្រួសារ[33]។

ផ្នត់គំនិតខុសឆ្គងអំពីយេនឌ័រទៅលើស្ត្រី នៅតែកើតមានបន្តនៅក្នុងសង្គម និងដើរតួនាទីក្នុងការរារាំងមិនឲ្យស្ត្រីទទួលបានតួនាទីក្នុងការសម្រេចចិត្តឲ្យបានច្រើន ការទទួលបានការថែទាំសុខភាពបន្តពូជ និងគេចផុតពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាលើរាងកាយ។

ការរំលោភសេពសន្ថវៈនៅតែមានអត្រាខ្ពស់ ជាពិសេសនៅក្នុងប្រទេសកម្ពុជាមួយផ្នែកដោយសារតែឥរិយាបថដែលគិតថាជនរងគ្រោះ គឺជាអ្នកទទួលខុសត្រូវសម្រាប់អំពើហិង្សាផ្លូវភេទ និងមួយផ្នែកដោយសារតែកង្វះវិធានការសង្គម និងផ្លូវច្បាប់សម្រាប់ជនល្មើស។

អំពើហិង្សាពីដៃគូស្និទ្ធស្នាល នៅតែមានការរីករាលដាលពាសពេញប្រទេសកម្ពុជា។ ទោះបីជាកិច្ចប្រឹងប្រែងមានការកើនឡើងពីរាជរដ្ឋាភិបាលជាតិ ក្នុងការលើកកម្ពស់ការយល់ដឹងថាអំពើហិង្សាក្នុងគ្រួសារជាទង្វើខុសក៏ដោយ ក៏គោលនយោបាយរាជរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋានបន្តប្រើប្រាស់ការសម្រុះសម្រួលជាដំណោះស្រាយដែលគេចង់បានសម្រាប់បញ្ហាអំពើហិង្សាក្នុងគ្រួសារដដែល។ ខណៈដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ មានវិធានការការពារពីរប្រភេទផ្សេងគ្នា(សេចក្តីសម្រេចរដ្ឋបាលដោយក្រុមប្រឹក្សាឃុំនៅមូលដ្ឋាន និងដីកាការពាររបស់តុលាការ)ក៏ដោយ ក៏វិធីសាស្ត្រក្នុងការទប់ស្កាត់អំពើហិង្សាដោយដៃគូស្និទ្ធស្នាលមិនដែលមានភាពដាច់ខាតដោយច្បាប់ទេ ហេតុដូច្នេះហើយគេសឹងតែមិនដែលបាន

[33] ចំណែកស្មើភាពសំរាប់នារី ការប៉ាន់ប្រមាណពីយេនឌ័រ នៅកម្ពុជា ឆ្នាំ២០០៨ ។

ប្រើវិធីសាស្ត្រទាំងនោះ សូម្បីតែជាមួយនឹងវិធីសាស្ត្រសម្រុះសម្រួលក៏ដោយ។ មិនមានកិច្ចការពារណាមួយចែងក្នុងច្បាប់ សម្រាប់ស្ត្រីដែលមិនរស់នៅជាមួយដៃគូរបស់ខ្លួនឡើយដោយរាប់ទាំងអ្នកដែលត្រូវបានដៃគូឈ្លបតាមធ្វើបាបបន្ទាប់ពីពួកគេប៉ុនប៉ងរស់នៅកន្លែងផ្សេងទៀតក៏ដោយ។

រាជរដ្ឋាភិបាល គឺត្រូវបានស្នើឲ្យបញ្ចូលនៅក្នុងផែនការសកម្មភាពថ្មី ស្តីពីការការពារ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ធ្វើវិសោធនកម្មខ្លះលើច្បាប់ទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងបន្ថែមនូវបទបញ្ញានានា ដើម្បីបញ្ជាក់អំពីការប្រើប្រាស់សេចក្តីសម្រេចរដ្ឋបាលនេះ។

បុព្វហេតុដែលពិបាកជាងគេមួយ ដែលការបន្តកើតមានអំពើហិង្សាក្នុងគ្រួសារមិនដាច់នេះ គឺឥរិយាបថដែលថាអំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាគ្រួសារជាជាងឧក្រិដ្ឋកម្មដែលធ្វើឲ្យឈឺចាប់ដល់មនុស្សទាំងអស់នៅក្នុងសង្គម ហើយនៅក្នុងកាលៈទេសៈខ្លះអំពើហិង្សាត្រូវបានបង្ហាញថាអាចទទួលយកបាន។ ផ្នត់គំនិតរបស់បុរសអំពីមនុស្សស្រីរួមចំណែកបង្កឲ្យមានអំពើហិង្សាដោយសារតែបុរសជាច្រើនជឿថា ប្រពន្ធ និងកូនរបស់ខ្លួនជាកម្មសិទ្ធិរបស់ពួកគេ។ ខ្សែភាពយន្ត និងកម្មវិធីកម្សាន្តតាមទូរទស្សន៍ជាច្រើនហាក់ដូចជាពង្រឹងឥរិយាបថទាំងនេះ តាមរយៈការបង្ហាញជារូបភាពនៃអំពើហិង្សាក្នុងសភាពមួយដែលជាការស្នើឡើងថា អាកប្បកិរិយាបែបនេះជាការអាចទទួលយកបាន។ កិច្ចខិតខំប្រឹងប្រែងជាច្រើនរបស់រាជរដ្ឋាភិបាល ទាក់ទងនឹងរូបភាពរបស់ស្ត្រីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានដឹកនាំដោយគណៈកម្មាធិការជាតិសម្រាប់លើកកម្ពស់សីលធម៌សង្គមកម្ពុជាតម្លៃស្ត្រី និងគ្រួសារខ្មែរ និងបានស្តីបន្ទោសតារាសម្តែងស្ត្រីដែលបង្ហាញពីភាពមិនសមរម្យក្នុងការស្លៀកពាក់។ ការផ្សព្វផ្សាយពត៌មានទាក់ទងនឹងអំពើហិង្សាលើស្ត្រី ក៏បានបញ្ចូលការប្រើប្រាស់សម្តីពាក្យពេជន៍ដែលមានការបន្ទាបតម្លៃរបស់ជនរងគ្រោះ និងរូបភាពនៃអំពើហិង្សាដែរ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានអនុម័តប្រកាសរួមមួយស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយក្នុងការរាយការណ៍ពត៌មានអំពើហិង្សាលើស្ត្រី[34]។

## ៣.៤. បញ្ហាសុខភាព

ជាការពិតណាស់ គេបានទទួលស្គាល់ថាស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ជាមួយនឹងបុរស តែក្នុងច្បាប់នេះពុំទាន់ចូលជ្រៅដល់សុខទុក្ខស្ត្រីឡើយ។ យ៉ាងណាមិញស្ត្រី ធម្មជាតិបង្កើតឲ្យមានពពោះសម្រាលកូន និងរោគមួយចំនួនដែលពាក់ព័ន្ធនឹងស្ត្រី ដែលបុរសពុំត្រូវបានកើតឡើយ។ នៅក្នុងដំណាក់កាលទាំងនេះ ស្ត្រីត្រូវតែរក្សាខ្លួនឲ្យបានល្អ ត្រូវថ្នមខ្លួន ប្រយ័ត្នប្រយែង បើគេហ៊ានធ្វេសប្រហែសនឹងត្រូវបាត់បង់សម្ផស្ស ឬក៏អាចស្លាប់បាត់បង់ជីវិតក៏សឹងមាន។ ចុះបើស្ត្រីមានកូនជាបន្តបន្ទាប់ទៅ តើស្ត្រីអាចមានកម្លាំងឯណានឹងប្រកបការងារដូចបុរសបាន? ចុះបើឥតធ្វើការបាន តើគេអាចរស់នៅដោយខ្លួនឯងបានដែរឬទេ? ចុះបើរស់នៅខ្លួនឯងមិនបានត្រូវ

[34] NGO-CEDAW, របាយការណ៍តាមដានការអនុវត្តអនុសញ្ញា ស៊ីដ ឆ្នាំ២០១៧ (ឆ្នាំ២០១៧)។

រស់នៅដោយពឹងផ្អែកគេបែបនេះ តើគេត្រូវប្រើសិទ្ធិរបស់គេដូចម្តេចទៅ? ត្រង់នេះហើយដែលជាទុក្ខរបស់ស្ត្រី ដែលទាមទារឲ្យបុរសជាដៃគូរបស់ខ្លួនមានមេត្តាធម៌ដល់ខ្លួន ដោយចេះអំណត់នូវចំណង់របស់ខ្លួនឲ្យស្របនឹងចំណង់របស់គេ ឬដៃគូរបស់ខ្លួនវិញ ពិតមែនតែម្នាក់ៗមានពេលខ្លះត្រូវពលីកម្មឲ្យគ្នាដោយជៀសមិនផុត តែត្រូវមានព្រំដែន។ ធ្វើដូចនេះបានទាល់តែមានការយោគយល់គ្នាទៅវិញទៅមក។ ដើម្បីយោគយល់គ្នាបាន ទាល់តែមានការទុកចិត្តគ្នា។ ដើម្បីទុកចិត្តគ្នាបាន ទាល់តែត្រូវហ៊ាននិយាយការពិតប្រាប់គ្នា។ ដើម្បីនិយាយការពិតប្រាប់គ្នាបាន ទាល់តែស្គាល់និងចេះគោរពសិទ្ធិមនុស្សប្រជាធិបតេយ្យក្នុងគ្រួសារ។ បុរសមិនត្រូវសម្តាងលើកម្លាំងបាយ ឬអំណាចសេដ្ឋកិច្ចដើម្បីគាបសង្កត់លើស្ត្រីឡើយ[35]។

ក្រៅពីនេះ ស្ត្រីមានទណ្ឌកម្មពីសង្គមថែមទៀតដែលទាមទារឲ្យស្ត្រីខំមាត់សង្កត់ចិត្ត ដើម្បីរស់នៅស្របតាមផ្នត់គំនិតរបស់សង្គម។ ដូច្នេះដើម្បីលើកកម្ពស់សុខភាពរបស់ស្ត្រីជាមាតា និងទារកពិសេសបំផុតត្រូវកំណត់ផែនការគ្រួសារ ដើម្បីទប់ស្កាត់កុំឲ្យមានទារកញឹកញាប់ពេក ហើយត្រូវយល់នូវចំណុចមួយចំនួនដូចតទៅនេះ ដើម្បីកាត់បន្ថយអត្រាមរណភាពនៃទារក ឬកុមាររាប់លាននាក់ និងមរណភាពនៃមាតាដែលជាស្ត្រី ក្នុងមួយឆ្នាំៗរាប់សែននាក់ គឺការមានផ្ទៃពោះមុនអាយុ១៨ឆ្នាំ និងក្រោយអាយុ៣៥ឆ្នាំ បង្កើតគ្រោះថ្នាក់ដល់ជីវិតទាំងម្តាយ និងកូន អាចបង្កើតគ្រោះថ្នាក់ដល់សុខភាពមាតានៅពេលមានផ្ទៃពោះ និងនៅពេលសម្រាលកូនកាលបើម្តាយមានកូនលើសពី៤នាក់ឡើងទៅ ត្រូវជៀសវាងកុំឲ្យមានផ្ទៃពោះញឹកពេកដែលអាចបង្កនូវគ្រោះថ្នាក់ដល់មាតានៅពេលមានទារក។

បច្ចុប្បន្ននៅប្រទេសកម្ពុជាយើង ថ្វីបើស្ថានភាពសុខភាព និងអាយុកាលរំពឹងទុករបស់ប្រជាជនកំពុងតែមានភាពល្អប្រសើរក៏ដោយ ក៏ប្រទេសកម្ពុជាសូចនាករផ្នែកសុខភាពមួយចំនួននៅតែមានកម្រិតទាបជាងគេនៅក្នុងតំបន់ ទោះបីជាស្ថានភាព និងអាយុកាលរំពឹងរស់នៅរបស់ប្រជាជនមួយចំនួននៅតែមានភាពល្អប្រសើរក៏ដោយ។ បើតាមការប៉ាន់ប្រមាណនាពេលបច្ចុប្បន្នបានបង្ហាញថាជាមធ្យមស្ត្រីមានអាយុវែងជាងបុរស ៦.៣ឆ្នាំ(អាយុការរំពឹងរស់របស់ស្ត្រី ៦៤ឆ្នាំ ហើយអាយុរំពឹងរស់របស់បុរស ៥៨ឆ្នាំ)។ បុរសអាចរងរបួស គ្រោះថ្នាក់ចរាចរណ៍ ឬ ពិការភាពរាងកាយរហូតដល់ទៅពីរដងច្រើនជាងស្ត្រី ប៉ុន្តែស្ត្រីមានការប្រឈមមុខខ្ពស់នឹងហានិភ័យនៃការឈឺថ្កាត់ ឬមរណភាពដោយសារតែការមានផ្ទៃពោះ និងការសម្រាលកូន។ ស្ថានភាពកង្វះអាហារូបត្ថម្ភរបស់ស្ត្រី នៅតែជាបញ្ហាព្រួយបារម្ភយ៉ាងខ្លាំង។ នេះជាបញ្ហាដែលទាមទារឲ្យយកចិត្តទុកដាក់ជាបន្តបន្ទាប់ ដោយសារស្ថានភាពជំងឺរបស់ស្ត្រីបានកើនឡើងយ៉ាងខ្លាំងក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយនេះ ហើយស្ថានភាពកង្វះអាហារូបត្ថម្ភ និងជំងឺនេះអាចមានផលិតភាពទាបប្រឈមមុខនឹងការកើនឡើងនូវជំងឺ និងមរណ

[35] ក្រសួងកិច្ចការនារី, ចំណែកស្មើភាពសំរាប់ស្ត្រី ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា (ឆ្នាំ២០០៨)។

ភាពមាតាខ្ពស់ និងប្រឈមមុខដល់ការកើនឡើងនៃបញ្ហាបន្តពូជរបស់ស្ត្រី។ ស្ត្រីដែលខ្វះអាហាររូបត្ថម្ភនឹងមានកម្ពស់ទាប អាចសម្រាលកូនដែលខ្វះទម្ងន់ ហើយទារកបែបនេះងាយនឹងកើតជំងឺផ្សេងៗ និងស្លាប់ណាស់។

ជំងឺមិនឆ្លងមួយចំនួនដែលប៉ះពាល់ដល់ស្ត្រី មានដូចជាជំងឺមហារីកមាត់ស្បូន និងមហារីកដោះ។ ជំងឺមហារីកមាត់ស្បូន ជាជំងឺដែលលេចធ្លោរជាងគេបំផុតក្នុងចំណោមស្ត្រីក្នុងប្រទេសកម្ពុជា។ យ៉ាងហោចណាស់ជាងពាក់កណ្តាលនៃស្ត្រីបានធ្វើរោគវិនិច្ឆ័យថាមានជំងឺមហារីកមាត់ស្បូនគឺហួសពេលព្យាបាលទោះជាយ៉ាងណាក៏ដោយ ការស្លាប់របស់ពួកគេអាចទប់ស្កាត់បានតាមរយៈការបង្ការ និងព្យាបាលទាន់ពេលវេលា។

បច្ចុប្បន្ននេះ មិនទាន់មានសេវាវិភាគរកមហារីកសុដន់ទេ ហើយស្ត្រីជាច្រើនបានស្លាប់ដោយសារជំងឺនេះគឺបានទទួលការថែទាំ និងព្យាបាលសម្រន់ដែលមានតម្លៃថ្លៃ និងពេលខ្លះទទួលបានការធ្វើរោគវិនិច្ឆ័យយឺតពេលក្នុងការព្យាបាល។ ខណៈពេលដែលឆ្មបបានទទួលការបណ្តុះបណ្តាលពីសារៈសំខាន់នៃការពិនិត្យសុដន់ដោយខ្លួនឯង គ្មានទិន្នន័យណាមួយដែលបង្ហាញពីលទ្ធផលដែលពួកគាត់បានទទួលយកចំណេះដឹងទាំងនោះទៅអនុវត្ត និងធ្វើការបញ្ជូននៅឡើយទេ។

បញ្ហាដ៏គួរឲ្យព្រួយបារម្ភមួយទៀត គឺយេនឌ័រ និងសុខភាពភ្នែកនៅក្នុងប្រទេសកម្ពុជា ដែលបានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការបង្ការ និងការពារភាពពិការភ្នែករបស់ក្រសួងសុខាភិបាលឆ្នាំ ២០០៨-២០១៥។ តាមការប៉ាន់ប្រមាណនៅប្រទេសកម្ពុជា ប្រជាជនចំនួន៤៣៨០០នាក់ ពិការភ្នែកទាំងសងខាង។ ក្រៅពីនេះ ប្រជាជនចំនួន៣៣៣,៥៩១នាក់ បានរកឃើញថាមានបញ្ហាចុះខ្សោយ ហើយក្នុងនោះ ៥៧,៨៥៧នាក់ រកឃើញថាមានបញ្ហាចុះខ្សោយធ្ងន់ធ្ងរ។ មានសារៈសំខាន់ណាស់ក្នុងការកាត់សម្គាល់ថា អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក គឺមានកម្រិតខ្ពស់ក្នុងចំណោមស្ត្រីអាយុលើសពី៥០ឆ្នាំ គឺ ៣,៤ភាគរយ ធៀបទៅនឹង ២ភាគរយ ក្នុងចំណោមក្រុមបុរសនៅក្នុងក្រុមអាយុដូចគ្នា។

បញ្ហាសុខភាពចម្បងមួយទៀតដែលកើតឡើងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺទាក់ទងនឹងសិទ្ធិផ្លូវភេទរបស់យុវវ័យ និងលទ្ធភាពទទួលបាននូវសេវាសុខភាពរបស់ពួកគេ[36]។

[36] ក្រសួងកិច្ចការនារី, យេនឌ័រ និងសុខភាព ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា (ឆ្នាំ២០១៤)។

# ជំពូកទី៤
# ក្របខណ្ឌយុទ្ធសាស្ត្ររបស់
# រាជរដ្ឋាភិបាល

# ជំពូកទី៤
# ក្របខណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

## ៤.១. គោលនយោបាយ និង ក្របខណ្ឌច្បាប់នៅក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យនយោបាយ និងការធ្វើសេចក្តីសម្រេច

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥ ទទួលស្គាល់ថាស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងសង្គម សេដ្ឋកិច្ច ជីវិត នយោបាយ និងវប្បធម៌។ រដ្ឋធម្មនុញ្ញមាត្រា៣៦ និង៤៥ ក៏បានបញ្ជាក់អំពីការងារដូចគ្នាទទួលបានកម្រៃស្មើគ្នាទាំងបុរស និងស្ត្រី ការរើសអើងគ្រប់ប្រភេទលើស្ត្រីត្រូវលុបបំបាត់ចោល។
- ដូចមានចែងនៅគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាគោលដៅទី៥ ការជម្រុញឲ្យមានស្ត្រីកាន់តែច្រើននៅក្នុងតួនាទីដឹកនាំ និងតួនាទីនយោបាយ គឺជាធាតុផ្សំចាំបាច់ ដើម្បីសម្រេចបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។ ទន្ទឹមនឹងនោះ ការបញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ការលើកកម្ពស់ស្ត្រីក្នុងវិស័យអប់រំ និងការធានាឲ្យស្ត្រីទទួលបានសិទ្ធិសុខភាពបន្តពូជក៏ជាកត្តាសំខាន់ផងដែរ ក្នុងការធ្វើឲ្យប្រសើរឡើងនូវឋានៈរបស់ស្ត្រីចូលរួមក្នុងភាពជាអ្នកដឹកនាំ។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ត្រូវបានធ្វើមូលដ្ឋាននីយកម្ម ADG5 ទៅក្នុង**យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ នារីរតនៈ និងផែនការសកម្មភាពជាតិក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី**។
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ ការអភិវឌ្ឍន៍ធនធានមនុស្ស មុំទី៤ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គម ផ្តោតលើអាទិភាពមួយចំនួនដូចជា៖
  - បន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ ក្រសួង,ស្ថាប័ន ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ។
  - ធ្វើបច្ចុប្បន្នភាព និងអនុវត្ត “ផែនការយុទ្ធសាស្ត្រនារីរតនៈ” ដោយបន្តជម្រុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍គ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត។
  - បន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រីតាមរយៈការពង្រីកកម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរតាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធ សម្តៅទប់ស្កាត់ការជួញដូរ និងអំពើហិង្សាលើស្ត្រី និងកុមារ។
- ក្រសួងកិច្ចការនារី បានសហការយ៉ាងសកម្មជាមួយក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ដៃគូ

អភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចនៃក្រុមការងារបច្ចេកទេសយេនឌ័រ(TWGG-WLG) ដែលទទួលខុសត្រូវក្នុងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច។ ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ បានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (GMAPs) និងគ.ជ.អ.ប. បានបង្កើតផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ សម្រាប់ការអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងមុខងារសាធារណៈ និងក្នុងការគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ។

- រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំឯកសារគន្លឹះចំនួន៣ ក្នុងការជម្រុញសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី៖

១) ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ២០១៩-២០២៣

២) គោលនយោបាយជាតិស្តីពី សមភាពយេនឌ័រ និង

៣) ផែនការសកម្មភាពជាតិលើកទី៣ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAWIII)[37]

## ៤.២. ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥(២០១៩-២០២៣)

នារីរតនៈទី៥ ផ្តោតលើការជម្រុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មអភិវឌ្ឍន៍គ្រប់វិស័យ និងគ្រប់កម្រិត និងមានយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនឹងសេដ្ឋកិច្ច ការអប់រំ សុខភាព កិច្ចការពារផ្លូវច្បាប់ អភិបាលកិច្ច និងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះ ទ្រទ្រង់ដោយកម្មវិធីពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន ដែលជាកត្តាចាំបាច់បំផុតនៃភាពជោគជ័យក្នុងការអនុវត្ត **នារីរតនៈ**។ ក្នុងបរិការណ៍នេះ កម្មវិធីអភិវឌ្ឍន៍ស្ថាប័នត្រូវធ្វើឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃការវិវត្តន៍ និងបរិបទថ្មីៗរបស់ពិភពលោក និងនៅក្នុងប្រទេស ក៏ដូចជាការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងការធ្វើឌីជីថលភាវូបនីយកម្ម[38]។

### ៤.២.១. យុទ្ធសាស្ត្រទី១ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ជាយុទ្ធសាស្ត្រអាទិភាព និងអភិក្រមមូលដ្ឋានដ៏សំខាន់សម្រាប់ឆ្នាំ២០១៩-២០២៣។ យុទ្ធសសាស្ត្រចតុកោណដំណាក់កាលទី៤ របស់របស់រដ្ឋាភិបាលកម្ពុជា បានណែនាំឲ្យបន្តលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី តាមរយៈការពង្រីកកម្ម

[37] អគ្គលេខាធិការដ្ឋានរដ្ឋសភា, បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ: លទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ។
[38] ក្រសួងកិច្ចការនារី, នារីរតនៈទី៥ ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ឆ្នាំ ២០១៩-២០២៣(ឆ្នាំ២០២០)។

វិធីអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ព្រមទាំងការជម្រុញការអនុវត្តន៍មូលនិធិជាតិសម្រាប់ការអភិវឌ្ឍន៍ជំនាញ និងការបង្កើនគំនិតសហគ្រិនភាពក្នុងកម្មវិធីអប់រំ។

ម៉្យាងវិញទៀត ក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបបដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាល នឹងជម្រុញការអភិវឌ្ឍន៍សហគ្រិនភាព និងរៀបចំប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិយាកាសអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ ការជម្រុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តការប្រតិបត្តិការសហគ្រិនភាពក្នុងក្របខណ្ឌរាជរដ្ឋាភិបាល និងជាមួយវិស័យឯកជន។ រាជរដ្ឋាភិបាលបានដាក់ចេញការអនុវត្តគោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម បង្កើតមូលនិធិសហគ្រិនភាព និងសក្ដានុពលរបស់ស្ត្រី នៅក្នុងវិស័យសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងស្របតាមស្ថានភាពសង្គម។

ក្នុងបរិការណ៍នេះ នារីរតនៈទី៥ ផ្ដោតលើអាទិភាពដូចខាងក្រោម៖

១. ពង្រឹង និងពង្រីកបរិយាកាសការគាំទ្រផ្នែកគោលនយោបាយ និងការវិនិយោគប្រកបដោយបរិយាបន្នក្នុងការគាំទ្រការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

២. ពង្រីកកាលានុវត្តភាព និងបរិយាកាសសម្រាប់ការអភិវឌ្ឍន៍សហគ្រិនភាព និងធុរកិច្ចរបស់ស្ត្រីប្រកបដោយកាលានុត្តភាព និងបរិយាបន្ន។

៣. ពង្រីកបរិយាកាសសម្រាប់ស្ត្រី ក្នុងការទទួលបានវិជ្ជាជីវៈជាពិសេស ស្របតាមតម្រូវការសេដ្ឋកិច្ចឌីជីថល និងប្រកបដោយបរិយាបន្ន។

៤. លើកកម្ពស់ការយកចិត្តទុកដាក់ និងគាំទ្រដល់ស្ត្រី ដែលកំពុងមានសកម្មភាពក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

៥. លើកកម្ពស់កម្មវិធីតុល្យភាពជីវិត គ្រួសារ និងការងារ បរិយាកាសមេត្រីភាព និងសុវត្ថិភាពសម្រាប់ស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ច។

៦. ពង្រីកកាលានុវត្តភាពសេដ្ឋកិច្ចនៅតាមសហគមន៍ រួមទាំងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្នសម្រាប់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ ស្ត្រីជនជាតិភាគតិច ស្ត្រីជនជាតិដើមភាគតិច ស្ត្រីជាមេគ្រួសារ[39]។

### ៤.២.២. យុទ្ធសាស្ត្រទី២ ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី

ការទទួលបានការអប់រំពេញលេញរបស់ស្ត្រី និងក្មេងស្រី ជាលក្ខខណ្ឌដ៏ចាំបាច់ក្នុងការជម្រុញឲ្យសម្រេចបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីនៅគ្រប់វិស័យ។ ស្របតាមចក្ខុវិស័យ

[39] ក្រសួងកិច្ចការនារី, នារីរតនៈទី៥ ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ឆ្នាំ ២០១៩-២០២៣(ឆ្នាំ២០២០)។

របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៥០ តម្រូវឲ្យមានការពង្រីកលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់ស្ត្រី និងក្មេងស្រី និងស្របតាមតម្រូវការរបស់សង្គម។ ទន្ទឹមនឹងនេះ គម្លាតយេនឌ័រក្នុងវិស័យអប់រំ ជាពិសេសនៅកម្រិតឧត្តមសិក្សា និងការចាប់យកជំនាញតាមតួនាទីយេនឌ័រនៅបន្តកើតមាន ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត។ ជាមួយគ្នានេះ ការចូលរួមរបស់មនុស្សវ័យក្មេង ជាកាលានុវត្តភាពចាំបាច់ក្នុងការផ្លាស់ប្តូរ និងបណ្តុះនូវផ្នត់គំនិតជាវិជ្ជមានសម្រាប់ដំណើរឆ្ពោះទៅដើម្បីសមភាពយេនឌ័រ។

នៅក្នុងបរិការណ៍នេះ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ នឹងផ្តោតលើការពង្រឹង និងពង្រីកការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធវិស័យអប់រំ និងយុវជន ជាពិសេសការអប់រំរបស់ស្ត្រី និងក្មេងស្រីនៅក្នុងកម្រិតខ្ពស់ និងការអប់រំដែលស្របតាមតម្រូវការសង្គម ព្រមទាំងកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនតាមបែបវិជ្ជមានដែលឆ្លើយតបយេនឌ័រ។

នារីរតនៈ ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ពង្រឹងភាពជាដៃគូជាមួយក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំយុវជន និងកីឡា ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធវិស័យអប់រំ យុវជន និងជម្រុញការទទួលបានការអប់រំរបស់ស្ត្រី និងក្មេងស្រីនៅកម្រិតខ្ពស់ និងការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា។

២. ពង្រឹងភាពជាដៃគូជាមួយគ្រឹះស្ថានសិក្សា និងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងចំណោមក្រុមមនុស្សវ័យក្មេង។

៣. លើកកម្ពស់កម្មវិធីទារកដ្ឋាននៅតាមគ្រឹះស្ថានសាធារណៈ និងកន្លែងធ្វើការ និងពង្រឹងកម្មវិធីមត្តេយ្យសិក្សាសហគមន៍នៅតាមមូលដ្ឋាន ព្រមទាំងលើកកម្ពស់កម្មវិធីអប់រំមាតា ការយល់ដឹងពីសារៈសំខាន់នៃការថែទាំ និងការសិក្សាសម្រាប់កុមារតូច និងការចិញ្ចឹមកូនតាមបែបវិជ្ជមាន។

៤. ពង្រឹង និងពង្រីកការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានដែលឆ្លើយតបនឹងយេនឌ័រ។

៥. រៀបចំ និងអនុវត្តកម្មវិធីអបរំសុខមាលភាពសង្គម ជាពិសេសសម្រាប់ស្ត្រី និងគ្រួសារ សម្តៅលើកកម្ពស់ការអនុវត្តសិទ្ធិរបស់ស្ត្រី និងក្មេងស្រីដោយពេញលេញ។

៦. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីស្ថានភាពនិងបញ្ហាថ្មីៗពាក់ព័ន្ធនឹងស្ថានភាពស្ត្រី និងយេនឌ័រនៅក្នុងវិស័យអប់រំយុវជន និងកីឡា។

### ៤.២.៣. យុទ្ធសាស្ត្រទី៣ ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី

រាជរដ្ឋាភិបាលបន្តអនុវត្ត និងធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសមធម៌នៃសេវាសុខភាព តាមរយៈប្រព័ន្ធសុខាភិបាល និងបង្កើនការបង្កាហានិភ័យហិរញ្ញវត្ថុ។ ការសម្រេចឲ្យបានលទ្ធផលសុខភាពដោយសមធម៌ នៅក្នុងចំណោមប្រជាពលរដ្ឋដែលមានស្ថានភាពសេដ្ឋកិច្ច និងសង្គមខុសៗគ្នារវាងប្រជាពលរដ្ឋរស់នៅទីប្រជុំជន និងតំបន់ជនបទ នៅតែជាសម្ពាធមកលើប្រព័ន្ធសុខាភិបាល ក្នុងការឈានទៅសម្រេចបានចក្ខុវិស័យរយៈពេលវែង *"ប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសុខភាព និងសុខមាលភាពកាន់តែល្អប្រសើរ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព"* ។ ក្នុងខ្លឹមសារនេះ បញ្ហាវិសមភាពយេនឌ័រនៅក្នុងវិស័យសុខាភិបាលនៅតែជាឧបសគ្គសម្រាប់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបានសេវាសុខភាពដែលមានគុណភាព និងសមធម៌ ដែលចំណុចនេះបណ្តាលមកពីកត្តាមួយចំនួន ដូចជាកម្រិតនៃការអប់រំ ខ្វះការទទួលបានព័ត៌មាន ខ្វះខាតផ្នែកសេដ្ឋកិច្ច បន្ទុកការងារផ្ទះសម្បែង និងការថែទាំកូន និងចាស់ជរាជាដើម។

ក្រសួងកិច្ចការនារី នឹងសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ ពង្រីកកម្មវិធីវិភាគគម្លាតយេនឌ័រ និងការជម្រុញការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំ និងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធសុខភាព ជាពិសេសអាហារូបត្ថម្ភ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់ស្ត្រី និងក្មេងស្រី និងបន្តតួនាទីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបាន និងការប្រើប្រាស់មូលនិធិសមធម៌ រួមជាមួយគម្រោងគាំពារសុខភាពសង្គមផ្សេងៗ ដូចជាបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) ការទទួលបានសេវាធានារ៉ាប់រងសុខភាពដល់ស្ត្រី និងក្មេងស្រី ព្រមទាំងជម្រុញឲ្យស្ត្រី និងក្មេងស្រីទទួលបានសេវាប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

កិច្ចការនេះ មានគោលដៅចូលរួមចំណែកកាត់បន្ថយអត្រាការស្លាប់របស់មាតា និងទារក អត្រាស្លាប់នៃជំងឺឆ្លង ជំងឺមិនឆ្លង និងស្លាប់ដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រព្រឹត្តនានា ដូចជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការប្រើប្រាស់គ្រឿងញៀន សារធាតុញៀន គ្រឿងស្រវឹង និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

ក្នុងមូលដ្ឋាននេះ នារីរតនៈទី៥ ផ្តោតលើអាទិភាពខាងក្រោម៖

១. ពង្រឹង និងពង្រីកការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពវិស័យសុខាភិបាល និងកម្មវិធីនានា រួមមានកម្មវិធីសុខភាពបន្តពូជ សុខភាពមាតាទារក សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត សុខភាពភ្នែក អាហារូបត្ថម្ភ សន្តិសុខស្បៀង កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង។

២. បង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបានសេវាសុខភាពប្រកបដោយបរិយាបន្ន មានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ស្របតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

៣. បន្តអភិវឌ្ឍសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យបានទូលំទូលាយអំពីការវិភាគយេនឌ័រនៅក្នុងផ្នែកសុខភាព អាហារូបត្ថម្ភ និងសន្តិសុខស្បៀង។

៤. លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការអនុវត្តក្របខណ្ឌកិច្ចគាំពារសង្គម។

៥. ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលការងារបានអនុវត្តន៍ ផ្អែកលើផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់ក្រសួង និងរៀបចំមូលទិន្នន័យថ្មីៗស្តីពីយេនឌ័រ និងសុខភាព(ការបន្តពូជ សុខភាពផ្លូវភេទ ជំងឺឆ្លង និងជំងឺមិនឆ្លង) អាហារូបត្ថម្ភ សន្តិសុខស្បៀង។

### ៤.២.៤. យុទ្ធសាស្ត្រទី៤ កិច្ចគាំពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី មានគោលបំណងលើកកម្ពស់ការពារសិទ្ធិ និងលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រី និងក្មេងស្រីដែលស្ថិតនៅក្នុងក្រុមងាយរងគ្រោះ[40] ព្រមទាំងបង្កើនការផ្តល់សេវាដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងទៅនឹងយេនឌ័រ ឲ្យកាន់តែមានប្រសិទ្ធភាព គុណភាព បរិយាបន្ន និងទាន់ពេលវេលា។ ក្រសួងកិច្ចការនារីបន្តដឹកនាំ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងផ្នែកឯកជន ក្នុងការតាក់តែង និងអនុវត្តផែនការសកម្មភាពស្តីពីអំពើហិង្សាលើស្ត្រីលើកទី៣ ២០១៩-២០២៣។

ការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការបំពារបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ ជាកិច្ចការដ៏សំខាន់សម្តៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងក្មេងស្រី ដើម្បីធានាការលើកកម្ពស់ និងការពារសិទ្ធិរបស់ពួកគេ។

ក្នុងបរិការណ៍នេះ នារីរតនៈទី៥ ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ជម្រុញការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

២. សម្របសម្រួល និងជម្រុញការអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣ តាមរយៈការបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំ និងការពង្រឹងប្រសិទ្ធក្នុងការអនុវត្តន៍

[40] **ស្ត្រី និងក្មេងស្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ** រួមមានស្ត្រីដែលមានពិការភាព ផ្ទុកមេរោគអេដស៍ ពលករទេសន្តោប្រវេសន៍ អ្នកធ្វើការតាមផ្ទះ អ្នកដែលបម្រើការងារនៅកន្លែងកំសាន ក្រុមស្រលាញ់ភេទដូចគ្នា ស្ត្រីស្ថិតនៅក្នុងក្រុមសាសនាដែលមានអ្នកគោរពប្រតិបត្តិភាគតិច ស្ត្រីនៅក្នុងពន្ធនាគារ ស្ត្រីដែលប្រើប្រាស់គ្រឿងញៀន ឬដៃគូរបស់ពួកគេប្រើប្រាស់គ្រឿងញៀន និងអាចមានក្រុមងាយរងគ្រោះដទៃផ្សេងទៀត។

មុខងារបច្ចេកទេសយេនឌ័រ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។

៣. អនុវត្តកម្មវិធី និងយុទ្ធនាការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។

៤. រៀបចំ និងអនុវត្តកិច្ចការពារផ្លូវច្បាប់ និងសេវាពហុវិស័យជូនជនរងគ្រោះដោយសារតែអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

៥. ពិនិត្យ និងជម្រុញការអនុវត្តន៍ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទប់ស្កាត់រាល់ទម្រង់អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងក្មេងស្រី។

៦. ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣។

៧. សម្របសម្រួល និងគាំទ្រការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិ តំបន់ និងអនុតំបន់ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងកុមារ អំពើធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចនានា។

៨. ចូលរួមគាំទ្រការអនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។

៩. សិក្សាស្រាវជ្រាវអំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធអំពើហិង្សាគ្រប់រូបភាពពាក់ព័ន្ធនឹងយេនឌ័រស្របតាមការអនុវត្តន៍ និងស្ថានភាពថ្មីៗរបស់សង្គម។

### ៤.២.៥. យុទ្ធសាស្ត្រទី៥ ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានកំណត់ថារាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និងពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅក្នុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងកម្រិតនយោបាយ និងកម្រិតជំនាញ។ អាទិភាពនេះ អាចសម្រេចបានតាមរយៈការដាក់ចេញជាយុទ្ធសាស្ត្រ និងចូលរួមដោយសកម្ម រួមទាំងឆន្ទៈ និងការប្តេជ្ញានៅក្នុងដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាលរួមមាន កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណបក្សនយោបាយ។

ក្រសួងកិច្ចការនារី សម្របសម្រួលក្នុងការរៀបចំ និងអនុវត្តក្របខណ្ឌកម្មវិធីស្តីពីការលើកកម្ពស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ តាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច។

ក្នុងបរិការណ៍នេះ នារីរតនៈទី៥ ផ្តោតលើអាទិភាពដូចខាងក្រោម៖

១. ពង្រីកបរិយាកាសគាំទ្រផ្នែកគោលនយោបាយ ព្រមទាំងបរិយាកាសមេត្រីភាពសម្រាប់ស្ត្រីនៅកន្លែងធ្វើការ និងការគាំទ្រពីដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំ និងតួនាទីបច្ចេកទេសនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងវិស័យនយោបាយ វិស័យសាធារណៈ និងនៅតាមសហគមន៍។

២. ពង្រឹងបណ្ដាញ និងអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៣. លើកកម្ពស់ការយល់ដឹង ការផ្លាស់ប្ដូរឥរិយាបថរបស់សាធារណជន ទាំងបុរស និងស្ត្រីជាថ្នាក់ដឹកនាំរួមទាំងយុវវ័យ ដៃគូពាក់ព័ន្ធ អំពីការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ អភិបាលកិច្ច និងអភិវឌ្ឍសហគមន៍។

៤. លើកកម្ពស់ការចូលរួមរបស់យុវជន និងស្ត្រីវ័យក្មេង ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចដែលឆ្លើយតបយេនឌ័រ។

### ៤.២.៦. យុទ្ធសាស្ត្រទី៦ ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងរបៀបវារៈឆ្លើយតបការប្រែប្រួលអាកាសធាតុ ជាពិសេសតាមរយៈការដាក់បញ្ចូលជាយុទ្ធសាស្ត្រអាទិភាពនៃផែនការនារីរតនៈ និងដាក់ចេញនូវវិធានការពង្រឹងភាពអង់អាចដល់ស្ត្រី ក្នុងការបន្សាំ និងសាងភាពអត់ធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

ក្រសួងកិច្ចការនារី នឹងពង្រឹងសមត្ថភាពបច្ចេកទេសនិងប្រសិទ្ធភាព ក្នុងការចូលរួមនៅក្នុងរបៀបវារៈរបស់កម្មវិធីអភិវឌ្ឍន៍ដោយចីរភាព និងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈបន្តអនុវត្តផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣ ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០ និងផែនការសកម្មភាពយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣។

ក្នុងមូលដ្ឋាននេះ នារីរតនៈទី៥ ផ្ដោតអាទិភាពដូចខាងក្រោម៖

១. ពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

២. ការបញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការ យុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញទន្លេសាប និងទន្លេមេគង្គមានភាពប្រសើរឡើង។

៣. គាំទ្រ និងបង្កើតគំនិតផ្តួចផ្តើមនានា ក្នុងការឆ្លើយតបតម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមស្ត្រីក្មេងស្រី ដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

៤. រៀបចំប្រព័ន្ធគ្រប់គ្រងនិងចែករំលែកពត៌មាន និងការសិក្សាស្រាវជ្រាវថ្មីៗ ស្តីពីផលប៉ះពាល់យេនឌ័រ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ប្រកបដោយបរិយាបន្ន[41]។

## រូបចំព្រួញផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣

ដើម្បីសម្រេចសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីគ្រប់រូបនៅកម្ពុជា

| **ការបញ្ជ្រាបយេនឌ័រ**<br>ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី១** | **យុទ្ធសាស្ត្រទី២** | **យុទ្ធសាស្ត្រទី៣** | **យុទ្ធសាស្ត្រទី៤** | **យុទ្ធសាស្ត្រទី៥** | **យុទ្ធសាស្ត្រទី៦** |
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី | ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី | ភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាសធារណៈ និងនយោបាយ | ការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ |

[41] ក្រសួងកិច្ចការនារី, នារីរតនៈទី៥ ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ឆ្នាំ ២០១៩-២០២៣(ឆ្នាំ២០២០)។

# សេចក្ដីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយប្រធានបទស្តីពី **«សិទ្ធិនារីនៅកម្ពុជា»** រួចមក យើងបានយល់ដឹងអំពីសិទ្ធិនារី ទំនៀមទម្លាប់ប្រពៃណី និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទាំងច្បាប់ជាតិ និងអន្តរជាតិ។ ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរតាំងពីសម័យបុរាណមក ប៉ុន្តែតួនាទីរបស់ស្ត្រីស្ថិតក្នុងសភាពមួយមានកម្រិតនៅឡើយ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សិទ្ធិមនុស្សនៅកម្ពុជាត្រូវបានរំលោភបំពានទាំងស្រុងយ៉ាងធ្ងន់ធ្ងរដែលពិភពលោកមិនចង់ដឹង មិនចង់ឮ ហើយដែលឧក្រិដ្ឋជននៃរបបនេះត្រូវតែទទួលទោសដែលមិនអាចលើកលែងឲ្យបាន។

ក្រោយវត្តមានរបស់ អ៊ុន តាក់ កម្ពុជាបានប្រកាសរដ្ឋធម្មនុញ្ញថ្មី ដែលក្នុងនោះមានចែងពីសិទ្ធិរបស់នារីផងដែរ។ ចាប់ពីពេលនោះ ស្ថាប័នសិទ្ធិមនុស្សជាតិ និងអន្តរជាតិបានកើតឡើងព្រោងព្រាត។ មកទល់នឹងបច្ចុប្បន្ននេះ យើងឃើញថាស្ថានភាពសិទ្ធិនារីមានភាពប្រសើរឡើងជាលំដាប់ ទោះបីជាយឺតក៏ដោយ។ នៅក្នុងជួររាជរដ្ឋាភិបាល ចំនួនសមាសភាពជាស្ត្រីនៅតែតិចតួច។ សមាសភាពស្ត្រីបម្រើការនៅថ្នាក់ឃុំ-សង្កាត់មានការកើនឡើង។ ចំណែកស្ត្រីបម្រើការនៅក្នុងវិស័យអប់រំកម្រិតដំបូង ចំនួនកំណើនច្រើនបើប្រៀបនឹងឆ្នាំមុនៗ។ ដោយឡែក បញ្ហាប្រឈមរបស់ស្ត្រីនៅតែបន្តកើតមានជារឿយៗដូចជា ករណីរំលោភសេពសន្ថវៈ ការជួញដូរស្ត្រីនិងក្មេងស្រី អំពើហិង្សា និងការរើសអើងលើស្ត្រីនៅតែជាប្រធានបទក្តៅ ដែលទាមទារឲ្យរដ្ឋាភិបាលយកចិត្តទុកដាក់ឲ្យបានដឹតដល់។

ទាក់ទងនឹងចំនួនស្ត្រីតិចតួចបម្រើការនៅក្នុងស្ថាប័នរដ្ឋ ហើយច្រើនបម្រើការនៅក្នុងស្ថាប័នឯកជន នោះអាចមកពីវប្បធម៌ពុករលួយ វិសមភាពយេនឌ័រ និងមកពីសមត្ថភាពប្រកួតប្រជែងរបស់ពួកគេនៅមានកម្រិត។ អំពើហិង្សា និងការរំលោភសេពសន្ថវៈ អាចកើតមកពីកង្វះការអប់រំ និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល។

ជារួម ផែនការសមភាពសម្រាប់នារីនៅព្រះរាជាណាចក្រកម្ពុជា ជាវិថីមួយដ៏វែងឆ្ងាយ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ និងកែលម្អជាបន្តបន្ទាប់ពីសំណាក់រាជរដ្ឋាភិបាល និងត្រូវចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋខ្លួនឯង។

# អនុសាសន៍

ក្រោយកិច្ចស្រាវជ្រាវលើប្រធានបទស្តីពី «**សិទ្ធិនារីនៅកម្ពុជា**» ខ្ញុំមានក្តីសោមនស្សរីករាយជាពន្លឹក ដោយបានទទួលនូវចំណេះដឹងលើប្រធានបទនេះដូចជា សមត្ថភាពរបស់នារី ស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងផែនការរបស់រាជរដ្ឋាភិបាលជាដើម។ ជាការពិត រាល់ការអនុវត្តន៍ផែនការមួយមិនអាចរកឃើញភាពល្អគ្រប់ជ្រុងជ្រោយបានឡើយ មានចន្លោះប្រហោងមួយចំនួនដែលរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ និងកែលម្អចំណុចទាំងនោះ។ ក្នុងនាមជាអ្នកស្រាវជ្រាវ ខ្ញុំសូមចូលរួមចំណែកជាអនុសាសន៍មួយចំនួនដើម្បីលើកស្ទួយសិទ្ធិនារីនៅកម្ពុជាឲ្យមានតម្លាភាព វឌ្ឍនភាព សមភាព និងនិរន្តរភាព ដូចខាងក្រោមៈ

- ពង្រីកឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលបន្ថែមទៀតដល់ក្មេងស្រី ដើម្បីធ្វើឲ្យប្រសើរឡើងនូវភាពអង់អាចផ្នែកសេដ្ឋកិច្ច
- កែលម្អ និងកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដើម្បីឲ្យក្មេងស្រីពិការ និងគ្រូបង្រៀនពិការមានលទ្ធភាពទទួលបាន និងផ្តល់ការសិក្សាសមស្រប
- បង្កើនការផ្តល់សេវាថែទាំសុខភាពដល់ស្ត្រីក្រីក្រ និងស្ត្រីងាយរងគ្រោះ
- ពង្រឹង និងពង្រីកកម្មវិធីធ្វើការកែប្រែផ្នត់គំនិត និងអាកប្បកិរិយារបស់សង្គម ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ គួរពង្រីកប្រសិទ្ធភាពក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យរបស់ខ្លួន
- លើកកម្ពស់សីលធម៌នៃប្រព័ន្ធផ្សព្វផ្សាយ សម្រាប់រាយការណ៍អំពីអំពើហិង្សាលើស្ត្រី និងគោលការណ៍ណែនាំជាស្តង់ដារ គ្រប់គ្រងដោយក្រុមប្រឹក្សាប្រព័ន្ធផ្សព្វផ្សាយ
- ពង្រឹងយុទ្ធសាស្ត្រដែលជម្រុញឲ្យស្ត្រីចេះប្រើនូវសិទ្ធិ និងអំណាចរបស់ខ្លួនតាមការបង្កើតនូវលទ្ធភាពទទួលបានព័ត៌មាន និងសេវាតាមតម្រូវការ
- បង្កើតបរិយាកាស ដែលលើកទឹកចិត្តប្រជាពលរដ្ឋរាយការណ៍ពីករណីរំលោភសេពសន្ថវៈ និងលុបបំបាត់សម្ពាធដែលបង្ខំឲ្យអ្នកទាំងនោះដកពាក្យបណ្តឹងវិញ
- ធានាថាជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងក្មេងស្រី ទទួលបានសេវាពីតុលាការប្រកបដោយប្រសិទ្ធភាព។

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងពិធីសារបន្ថែម
- សេចក្តីថ្លែងការណ៍ភ្នំពេញ អំពីការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

## សៀវភៅនិពន្ធ

- នារីរតនៈទី៥ ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ឆ្នាំ ២០១៩-២០២៣
- បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំៈ លទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ
- យេនឌ័រ និងសុខភាព ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

## របាយការណ៍

- ការរួចខ្លួនពីបទល្មើសៈ ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈក្នុងប្រព័ន្ធតុលាការកម្ពុជា
- ទម្លាយភាពស្ងៀមស្ងាត់ៈ ការរំលោភសេពសន្ថវៈដោយសាច់ញាតិ និងឧបសគ្គក្នុងការទទួលបានយុត្តិធម៌នៅកម្ពុជា
- ធ្វើការងាររហូតជំពាក់បំណុលវ័ណ្ឌកៈ ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា
- របាយការណ៍តាមដានការអនុវត្តអនុសញ្ញា ស៊ីដ ឆ្នាំ២០១៧

## គេហទំព័រ

- កាន់ វិច្ឆិកា, *Hello VOAៈ កំណើននៃការជួញដូរមនុស្ស បង្ហាញពីកម្សោយរបស់អាជ្ញាធរ* (២៧ មករា ២០២២), https://khmer.voanews.com/a/hello-voa-rising-human-trafficking-in-cambodia-highlights-authorities-weakness/
- ក្រសួងពត៌មាន, *រដ្ឋមន្ត្រីក្រសួងអប់រំៈ បច្ចុប្បន្នកម្ពុជាមានសាលារៀនចំណេះដឹងទូទៅសរុបជិត ១៥.០០០កន្លែងនៅទូទាំងប្រទេស* (ថ្ងៃទី២៦ មីនា ២០១៩), https://www.information.gov.kh/articles/24614

- ខុមហ្វ្រែល, *ស្ត្រីចូលរួមនយោបាយក្នុងការបោះឆ្នោត* (៣១ សីហា ២០១២), https://comfrel.org/wp-content/uploads/2018/03/412_905455Women_in_Election_2012_KH.pdf
- ចំណែកស្មើភាពសំរាប់នារី ការប៉ាន់ប្រមាណពីយេនឌ័រ នៅកម្ពុជា ឆ្នាំ២០០៨
- បែន សុខហ៊ាន និង Erin Handley, *ស្ត្រីកម្ពុជា មានតិចជាង៣ភាគរយក្នុងចំណោមថ្នាក់ដឹកនាំយោធា* (០៥ មីនា ២០១៨) http://bit.ly/2FesVh7
- ម៉ម ពិសី, *តើទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា មានប្រភពមកពីណា?* (ថ្ងៃទី៨ មីនា ២០២១), https://www.rfi.fr/km
- តើអ្វីទៅដែលហៅថាឧត្តមសិក្សា(ការអប់រំជាន់ខ្ពស់?)(ថ្ងៃទី២៥ ឧសភា ២០១៧), https://www.palmhub.com
- លាស់ លីបលីប, *សង្គមស៊ីវិលបារម្ភអំពីការកើនឡើងតិចតួចនៃចំនួនស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់* (០១ កក្កដា ២០២២), https://khmer.voanews.com/a/civil-society-organizations-worry-about-fewer-increase-of-women-representatives-in-local-election/6640181.html
- អង្គការទិន្នន័យអំពីការអភិវឌ្ឍ, *ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា* (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១),https://opendevelopmentcambodia.net/km/topics/primary-and-secondary-education/
- អង្គការទិន្នន័យអំពីការអភិវឌ្ឍ, *ការអប់រំកម្រិតឧត្តមសិក្សា* (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២), https://opendevelopmentcambodia.net/km/topics/higher-education/
- អ៊ុំ ច័ន្ទលក្ខិណា, *តើការជួញដូរ និងអាជីវកម្មផ្លូវភេទកើតមានក្នុងរូបភាពដូចម្តេចខ្លះ?* (ថ្ងៃសុក្រ ទី១៧ ខែមេសា ឆ្នាំ២០២០), https://wmc.org.kh/article
- Natalie Hacks, ស្ថានភាពស្ត្រីនៅកម្ពុជា ចេញផ្សាយខែកក្កដា (ខែកក្កដា ២០០៤),ទំព័រទី៧០។ អាចរកបាននៅ,https://www.licadho-cambodia.org/reports/files/56kWReport2004Khmer.pdf

# បញ្ជីឧបសម្ព័ន្ធ

## លិខិតបទដ្ឋានគតិយុត្ត

- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងពិធីសារបន្ថែម

## សៀវភៅនិពន្ធ

- នារីរតនៈទី៥(២០១៩-២០២៣)

# ឧបសម្ព័ន្ធទី១

# អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់
# នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
## និងពិធីសារបន្ថែម



អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស

United Nations
Development Fund for Women
UNIFEM

# អនុសញ្ញា ស្តីពី
# ការលុបបំបាត់
# រាល់ទម្រង់នៃការរើសអើង
# ប្រឆាំងនឹងស្ត្រីភេទ
## និងពិធីសារបន្ថែម

ខែមករា ឆ្នាំ២០១០

កូនសៀវភៅនេះ  គឺជាការបោះពុម្ពផ្សាយរួមគ្នាដោយ
មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិដើម្បីស្ត្រី  និង
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល
បន្ទុកសិទ្ធិមនុស្ស - ការិយាល័យប្រចាំនៅកម្ពុជា

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស

United Nations
Development Fund for Women
UNIFEM

# អនុសញ្ញាស្តីការលុបបំបាត់រាល់ទំរង់នៃ ការរើសអើងប្រឆាំងនឹងស្ត្រីភេទ

## និងពិធីសារបន្ថែម

## សេចក្តីផ្តើម

ចាប់តាំងពីការអនុម័ត*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*មក សមភាពរវាងបុរស និងស្ត្រី និងការមិនរើសអើងក្នុងការទទួលបានសិទ្ធិនានា គឺជាគោលការណ៍ជាសារវ័ន្ត នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ មានចែងពីបទបញ្ញត្តិនានា ដែលបញ្ជាក់ច្បាស់ថា ស្ត្រីពិតជា ត្រូវទទួលបានសិទ្ធិមនុស្សដូចគ្នា ដូចបុរសដែរ ដោយផ្អែកលើមូលដ្ឋានសមភាព និងដោយមិនមានការរើសអើងណាមួយឡើយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីពាសពេញពិភពលោក បន្តប្រឈមនឹងឧបសគ្គនានា ក្នុងការទទួលបានសិទ្ធិមនុស្សរបស់គេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នានឹងបុរស រួមទាំងការរើសអើងក្នុងទំរង់ជាច្រើន។

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ អង្គការសហប្រជាជាតិបានអនុម័តសន្ធិសញ្ញាមួយ សំដៅដោះស្រាយនូវឧបសគ្គមួយចំនួន ដែលរាំងស្ត្រី មិនឲ្យទទួលបានសិទ្ធិស្មើគ្នានេះ គឺ៖ អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(CEDAW)។ មិនដូចកតិកាសញ្ញាអន្តរជាតិពីរ មួយស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមួយទៀត ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ CEDAWមិនបានចែងពីសិទ្ធិមនុស្សសំខាន់ថ្មីៗនោះទេ ៖ សិទ្ធិមនុស្សទាំងអស់ បានចែងនៅក្នុង កតិកាសញ្ញាទាំងនេះហើយ ដូចជា សិទ្ធិរស់រានមានជីវិត

សិទ្ធិសុខភាព ឬសេរីភាពនៃការបញ្ចេញមតិ បានអនុវត្តរួចហើយចំពោះស្ត្រី ក៏ដូចជាចំពោះបុរសទាំងអស់ដែរ។ ផ្ទុយទៅវិញ CEDAW គ្រាន់តែស្វែងរកដំណោះស្រាយចំពោះឧបសគ្គនានាដ៏ជាក់លាក់ដែលក្នុងការអនុវត្តន៍ជាក់ស្តែង ឧបសគ្គទាំងនេះ នៅតែបន្តរាំងស្ត្រីជាច្រើន ពីការទទួលបាននូវសិទ្ធិរបស់គេ តាមមសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗទៀត។

CEDAW ជារឿយៗ ត្រូវបានហៅថា "សន្ធិសញ្ញាសិទ្ធិនារី"។ បញ្ហានេះ គួរតែយកមកពិចារណាឲ្យបានដិតដល់ ព្រោះថាទោះជាសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ បរិយាយយ៉ាងពិស្តារពីសិទ្ធិមនុស្សជាមូលដ្ឋាន ដែលមនុស្សជាតិទាំងអស់ ត្រូវទទួលបាន ដោយមិនគិតថា ពួកគេជាបុរស ឬស្ត្រីក៏ដោយ ក៏បញ្ហានានារបស់ស្ត្រី ជារឿយៗ ត្រូវបានមើលរំលងដែរ។ សកម្មជនសិទ្ធិស្ត្រីបានអះអាងថា CEDAW គឺជាសន្ធិសញ្ញារបស់គេ ដើម្បីលាតត្រដាងពី វិសាលភាពពិតប្រាកដ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលនៅតែជាឧបសគ្គចំបង ចំពោះការសំរេចបានសមភាពពិតប្រាកដ។

### តើការរើសអើងប្រឆាំងនឹងស្ត្រីភេទគឺជាអ្វី?

មាត្រា១នៃអនុសញ្ញា ឲ្យនិយមន័យនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទថា "ការបែងចែក ការផាត់ចេញ ឬការរឹតត្បិតណាមួយ ផ្អែកលើភេទ ដែលមានអនុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃៈភាពនូវការទទួលស្គាល់ ការអាស្រ័យផល ឬការអនុវត្តន៍ដោយស្ត្រី ដោយមិនគិតដល់ ស្ថានភាពអាពាហ៍ពិពាហ៍របស់គេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នារវាងបុរសនិងស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត"។

ការរើសអើងអាចកើតមានឡើងជាច្រើនសណ្ឋាន៖ដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។ ការរើសអើង អាចត្រូវធ្វើដោយច្បាប់ ឬក៏យ៉ាងសាមញ្ញ ដោយការអនុវត្តន៍បែបប្រពៃណី និងវប្បធម៌។ ស្ត្រីអាចរើសអើងប្រឆាំងនឹងស្ត្រីគ្នាឯងច្រើនដូចបុរសដែរ។ តាមគ្រប់ទំរង់នៃការរើសអើង ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវតែមានការតតាំង ដើម្បីឲ្យស្ត្រីទទួលបានសិទ្ធិមនុស្សរបស់គេពេញលេញ។

អនុសញ្ញានេះមិនបានលើកឡើងឲ្យច្បាស់ពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីឡើយ។ ចាប់តាំងពីការអនុម័តអនុសញ្ញានេះមក អនុសញ្ញានេះត្រូវបានទទួលស្គាល់ថា អំពើហឹង្សាប្រឆាំងនឹងស្ត្រី គឺជាមួយទំរង់មួយនៃការរើសអើងប្រឆាំងនឹងស្ត្រី ហើយចាំបាច់ត្រូវតែរកដំណោះស្រាយ។ រដ្ឋាភិបាល ត្រូវតែចាត់វិធានការ ដើម្បីលុបបំបាត់រាល់ទំរង់នៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី ទោះជាអំពើនោះ ប្រព្រឹត្តឡើងជាសាធារណៈ ឬតាមគេហដ្ឋានឯកជនក៏ដោយ។

### តើអនុសញ្ញាCEDAWចងកាតព្វកិច្ចអ្វីខ្លះដល់រដ្ឋាភិបាល?

អនុសញ្ញានេះលើកឡើងពីបញ្ហានៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដោយតំរូវឲ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងក្នុងវិស័យសំខាន់ៗបីគឺ ៖ (១) វិធានការទូទៅ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងយ៉ាងតឹងរឹងប្រឆាំងនឹងស្ត្រីភេទក្នុងក្របខ័ណ្ឌច្បាប់ សង្គម និងវប្បធម៌របស់ប្រទេសបន្ទាប់មក នឹងមានការចាត់វិធានការជាក់លាក់ ចំពោះការទទួលបានរបស់ស្ត្រីនូវ (២) សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់គេ និង(៣) សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់គេ។ ប្រភេទទាំងបីនេះ ទាក់ទងគ្នានឹងផ្នែកទី១ ទី២ និងទី៣នៃអនុសញ្ញានេះ។

### (១) វិធានការទូទៅ ដើម្បីលុបបំបាត់ការរើសអើង

ភាគីនីមួយៗនៃអនុសញ្ញាCEDAW ត្រូវតែអនុម័តគោលនយោបាយ នៃការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ដើម្បីសំរេចគោលបំណងនេះ មាត្រា២នៃអនុសញ្ញាតំរូវឲ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងជាបន្តបន្ទាប់ដើម្បីការពារស្ត្រីប្រឆាំងនឹងការរើសអើងតាមរយៈច្បាប់ ការប្រយុទ្ធប្រឆាំងនឹងទម្លាប់នៃការរើសអើង ហើយត្រូវកែទំរង់ច្បាប់ទាំងឡាយណាដែលមានលក្ខណៈរើសអើង។

បន្ទាប់មក រដ្ឋាភិបាល ត្រូវចាប់ផ្តើមលើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី លើគ្រប់វិស័យ រួមទាំងវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ (មាត្រា៣)។ ដើម្បីសំរេចបាននូវគោលបំណងនេះ រដ្ឋាភិបាល អាចអនុម័តនូវអ្វី ដែលហៅថា "វិធានការពិសេសបណ្តោះអាសន្ន" សំដៅពន្លឿនសមភាពតាមព្រឹត្តិហេតុរវាងស្ត្រី និងបុរស(មាត្រា៤)។ នេះមានន័យថា មិនមែនជាទង្វើរើសអើងប្រឆាំងនឹងបុរសរបស់រដ្ឋាភិបាល ក្នុងការផ្តល់សេចក្តីលំអៀងដល់ស្ត្រីឲ្យបានច្រើនជាងបុរសឡើយ ដោយឈរលើមូលដ្ឋានបណ្តោះអាសន្ននេះ ដើម្បីកែតំរូវទំលាប់រើសអើង ដែលចាក់ឫសយ៉ាងជ្រៅក្នុងសង្គម ដែលបុរសត្រួតត្រាលើស្ត្រី។

អនុសញ្ញានេះ ជំរុញលើកទឹកចិត្តឲ្យរដ្ឋាភិបាលតតាំងនឹងគំនិតរើសអើងតាមបែបទំលាប់ដែលថា ភេទមួយ ទាបជាង ឬខ្ពស់ជាងភេទមួយទៀត ឬថាស្ត្រី និងបុរស ត្រូវបំពេញការងារតាមតួនាទីជាក់លាក់ដោយស្វ័យប្រវត្តិក្នុងសង្គម (មាត្រា៥)។ ឧទាហរណ៍៖ បញ្ហាមាតុភាពអនុសញ្ញានេះ តំរូវឲ្យមានការអប់រំតាមគ្រួសារ ដើម្បីលើកស្ទួយឲ្យមានការយល់ដឹងត្រឹមត្រូវនៃបញ្ហាមាតុភាព ថាជាតួនាទីរបស់សង្គម ហើយ

ត្រូវទទួលស្គាល់ថា ទាំងបុរស និងស្ត្រីត្រូវចែករំលែកការទទួលខុសត្រូវរួមគ្នា ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងការអភិវឌ្ឍន៍កូនរបស់គេឲ្យទទួលបានផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់កុមារ។

អនុសញ្ញានេះក៏តំរូវឲ្យចាត់វិធានការបង្ក្រាបការជួញដូរស្ត្រី និងការធ្វើអាជីវកម្មពេស្យាកម្មលើស្ត្រីភេទ (មាត្រា៦)។

**(២) ការទទួលបានរបស់ស្ត្រីនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

ផ្នែកទី២នៃអនុសញ្ញានេះ មានចែងពីបញ្ហាជាក់លាក់មួយចំនួនទាក់ទងនឹងការរើសអើង ដែលរាំងស្ត្រី ពីការទទួលបានពេញលេញនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយឈរលើមូលដ្ឋានដូចបុរសដែរ ដោយអំពាវនាវឲ្យចាត់វិធានការចំពោះ៖

- លើកស្ទួយការចូលរួមរបស់ស្ត្រី ក្នុងជីវភាពនយោបាយ និងសាធារណៈ ព្រមទាំងលើកស្ទួយសិទ្ធិបោះឆ្នោត កាន់តំណែងក្នុងមុខងារសាធារណៈ តាក់តែងគោលនយោបាយរបស់រដ្ឋាភិបាល និងចូលរួមក្នុងសង្គមស៊ីវិល (មាត្រា៧)។
- លើកស្ទួយឱកាសដល់ស្ត្រី ដើម្បីធ្វើជាតំណាងរដ្ឋាភិបាល លើឆាកអន្តរជាតិ និងបំរើការងារតាមអង្គការអន្តរជាតិ (មាត្រា៨)។
- ត្រូវធានាឲ្យស្ត្រីទាំងអស់មានសិទ្ធិស្មើគ្នាទទួលបានសញ្ជាតិ(មាត្រា៩)

**(៣) ការទទួលបានរបស់ស្ត្រីនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

ផ្នែកទី៣នៃអនុសញ្ញានេះ មានចែងជាលំដាប់លំដោយពីបញ្ហាជាក់លាក់មួយចំនួន ចំពោះការរើសអើង ដែលរាំងដល់ការទទួលបានរបស់ស្ត្រីនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់គេ ដោយឈរលើមូលដ្ឋានដូចគ្នា ដូចបុរសដែរ រួមទាំងតំរូវការ ឲ្យចាត់វិធានការ ដើម្បី

លុបបំបាត់ការរើសអើង និងលើកស្ទួយឱកាសស្មើគ្នាដល់៖

- ការអប់រំ៖រួមមានសិទ្ធិទទួលបានការអប់រំស្មើគ្នានៅគ្រប់កំរិតរួមទាំង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំបន្ត កម្មវិធីអប់រំ និងបទដ្ឋានអប់រំដូចគ្នា ការដកចេញក្រុមនិយមពីប្រព័ន្ធអប់រំ សិទ្ធិទទួលបានមូលនីធិស្មើគ្នាសំរាប់ការអប់រំ ចាត់វិធានការកាត់បន្ថយអត្រាសិស្សស្ត្រីបោះបង់ការសិក្សា និងផ្តល់ការអប់រំផ្នែកសុខភាព និងកម្មវិធីផែនការគ្រួសារ (មាត្រា១០)។

- ការងារ៖ រួមមានសិទ្ធិការងារ ឱកាសស្មើគ្នាក្នុងក្របខ័ណ្ឌជ្រើសរើសការងារនិងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ លក្ខខ័ណ្ឌការងារស្មើគ្នា សេរីភាពជ្រើសរើសវិជ្ជាជីវៈ ឬការងារ ការទទួលបានប្រាក់កំរៃស្មើគ្នា ទទួលបានប្រយោជន៍ពីការព្យាបាល និងសន្តិសុខសង្គម។ លើសពីនេះទៀត ស្ត្រីមិនមែនជាកម្មវត្ថុនៃការរើសអើងដោយសារតែលក្ខខ័ណ្ឌអាពាហ៍ពិពាហ៍ ឬមាតុភាពឡើយ ពួកគេ អាចទទួលប្រាក់ឧបត្ថម្ភពីការឈប់សំរាកមាតុភាព និងការជួយឧបត្ថម្ភពិសេសដើម្បីអាចឲ្យឪពុកម្តាយ មានលទ្ធភាពចងក្រងសង្គមគ្រួសារ និងការប្តេជ្ញាចិត្តក្នុងការងាររបស់គេ ហើយត្រូវការពារពីហានីភ័យនៅកន្លែងធ្វើការ នៅពេលមានផ្ទៃពោះ (មាត្រា១១)។

- ការថែទាំសុខភាព៖ រួមមានការថែទាំសមរម្យ នៅពេលមានផ្ទៃពោះ សំរាលកូន និងក្រោយពេលផ្តល់កំណើតកូន (មាត្រា១២)។

- ជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ច៖ រួមមានទទួលបានផលប្រយោជន៍គ្រួសារ សេវាកម្មធនាគារ និងសកម្មភាពកំសាន្ត កីឡា និងវប្បធម៌។

លើសពីនេះទៀត មាត្រា១៤ មានចែងពីបញ្ហាជាក់លាក់មួយ

ចំនួន ដែល ស្ត្រីនៅតាមជនបទប្រឈមមុខ។ ជារឿយៗ ពួកគេដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាដល់ការរស់រានផ្នែកសេដ្ឋកិច្ច នៃគ្រួសាររបស់គេ ស្វែងរកការធានាពីការចូលរួមរបស់ពួកគេក្នុងផែនការអភិវឌ្ឍន៍ ក្នុងសកម្មភាពក្រុមជួយខ្លួនឯង និងសហគមន៍។

**តើអនុសញ្ញានេះអនុវត្តយ៉ាងដូចម្តេចនៅប្រទេសកម្ពុជា?**

ប្រទេសកម្ពុជា បានក្លាយជាភាគីនៃអនុសញ្ញាCEDAW នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២។

មាត្រា៣១នៃរដ្ឋធម្មនុញ្ញ ធានាការពារដល់អនុសញ្ញានេះ ព្រមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀតថាជាផ្នែកមួយនៃច្បាប់របស់កម្ពុជា។ លើសពីនេះទៅទៀត មាត្រា៤៥ បញ្ជាក់យ៉ាងច្បាស់ថា "រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់" ហើយមានមាត្រាជាច្រើនទៀត នៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិ ត្រង់ជំពូក៣នៃរដ្ឋធម្មនុញ្ញចែងយ៉ាងច្បាស់ថា សិទ្ធិទាំងនេះអនុវត្តបានចំពោះពលរដ្ឋកម្ពុជាទាំងពីរភេទ"។

នៅក្នុងសេចក្តីសំរេចរបស់ខ្លួន កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នមួយបង្កើតឡើងដើម្បីការពាររដ្ឋធម្មនុញ្ញ បានបញ្ជាក់ជាថ្មី ពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិក្នុងច្បាប់ជាតិកម្ពុជា ហើយបានរំលឹកដល់ចៅក្រមថា ក្នុងការសំរេចក្តី និងការបកស្រាយច្បាប់ ចៅក្រម ត្រូវតែប្រកាន់ឲ្យបានខ្ជាប់ តាមបទបញ្ញត្តិទាំងឡាយ ក្នុងសន្ធិសញ្ញានានា រួមទាំងអនុសញ្ញា CEDAW ដែរ។

**គណកម្មាធិការCEDAW**

នៅពេលក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះ៖ រដ្ឋនេះ ធ្វើការប្តេជ្ញា

ចិត្តដែលជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះពលរដ្ឋរបស់ខ្លួន និងជាពិសេសចំពោះស្ត្រី ក៏ដូចជាចំពោះសហគមន៍អន្តរជាតិ ថាខ្លួននឹងអនុវត្តតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិស្ត្រី ដើម្បីបញ្ចប់ការរើសអើង។

តាមរយៈសន្ធិសញ្ញានេះ គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ដែលស្គាល់ជាទូទៅថា គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ជួនកាលហៅថាគណៈកម្មាធិការCEDAW) ត្រូវបានបង្កើតឡើង ដើម្បីឃ្លាំមើលការរីកចំរើន ដែលអនុវត្តដោយរដ្ឋនានា ក្នុងការបំពេញនូវការប្តេជ្ញាចិត្តរបស់ពួកគេ។ រដ្ឋទាំងអស់ ចាំបាច់ត្រូវរាយការណ៍ជូនគណៈកម្មាធិការ តាមកាលកំណត់ ពីការចាត់វិធានការអនុវត្តអនុសញ្ញានេះ។ បន្ទាប់មក គណៈកម្មាធិការ ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល សំរាប់ចាត់វិធានការបន្ថែមទៀត។

ប្រទេសកម្ពុជា បានធ្វើរបាយការណ៍ ជូនគណៈកម្មាធិការ ជាលើកដំបូង កាលពីឆ្នាំ២០០៥ ហើយគណៈកម្មាធិការ បានចេញអនុសាសន៍ នៅខែមករា ឆ្នាំ២០០៦។ រដ្ឋាភិបាល ដាក់របាយការណ៍តាមកាលកំណត់លើកទី២ កាលពីខែវិច្ឆិកា ឆ្នាំ២០០៩ ហើយរបាយការណ៍នេះ នឹងត្រូវពិនិត្យពិចារណាដោយគណៈកម្មាធិការ នៅពេលណាមួយក្នុងឆ្នាំ២០១០ ឬឆ្នាំ២០១១។

*យន្តការឃ្លាំមើលបន្ថែម ដែលមានចែងក្នុងពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ*

កាលពីខែធ្នូ ឆ្នាំ១៩៩៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តពិធីសារបន្ថែមមួយ ដែលអនុញ្ញាតឲ្យរដ្ឋនានា ជ្រើសរើស

ដើម្បីផ្តល់សិទ្ធិដល់គណៈកម្មាធិការCEDAW នៅក្រុងហ្សឺណែវ ពិនិត្យពិចារណាលើបណ្តឹងពីឯកត្តបុគ្គល ដែលអះអាងថា សិទ្ធិរបស់គេត្រូវបានរំលោភបំពាន។ គណៈកម្មាធិការ អាចទទួលបណ្តឹងបែបនេះបានតែពីបណ្តាប្រទេសណា ដែលបានជ្រើសរើស ផ្តល់សច្ចាប័នលើពិធីសារនេះប៉ុណ្ណោះ ហើយអាចពិនិត្យបណ្តឹង តែនៅពេលណា បណ្តឹងនោះបំពេញបាននូវលក្ខណៈវិនិច្ឆ័យមួយចំនួន៖ ជាពិសេស បណ្តឹងនេះ អាចយកមកពិនិត្យ បានលុះត្រាតែ ឯកត្តបុគ្គលនោះ បានប្រើប្រាស់អស់ដំណោះស្រាយក្នុងស្រុកទៅហើយ។ ពិធីសារបន្ថែមនេះក៏ផ្តល់សិទ្ធិដល់គណកម្មាធិការCEDAW ធ្វើការសាកសួរ នៅពេលមានភស្តុតាងនៃការរំលោភធ្ងន់ធ្ងរជាប្រព័ន្ធ ចំពោះបទបញ្ញត្តិនានានៃអនុសញ្ញានេះ។

ក្រោយពីគណៈកម្មាធិការ CEDAW ផ្តល់អនុសាសន៍រួចមក នាខែសីហា ឆ្នាំ២០០៩ រដ្ឋសភា បានអនុម័តច្បាប់ជាតិមួយ ដើម្បីផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ។ នៅពេលដែល នីតិវិធីច្បាប់អន្តរជាតិត្រូវបានបំពេញចប់សព្វគ្រប់ ដើម្បីធ្វើឲ្យសច្ចាប័ននេះ មានសុពលភាពតាមផ្លូវច្បាប់ នៅក្នុងច្បាប់អន្តរជាតិ នោះស្ត្រីនៅប្រទេសកម្ពុជានឹងអាចដាក់បណ្តឹងបុគ្គល ជូនគណៈកម្មាធិការ នៅក្រុងហ្សឺណែវ ប្រសិនបើពួកគេជឿជាក់ថា ជាជនរងគ្រោះ នៃការរើសអើង ដែលជាការរំលោភបំពានលើអនុសញ្ញានេះ។

ការិយាល័យឧត្តមស្នងការ

អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ការិយាល័យប្រចាំនៅកម្ពុជា

ខែមករា ឆ្នាំ២០១០

# អនុសញ្ញា ស្ដីពី
# ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិក
តាមសេចក្ដីសម្រេចចិត្តលេខ៣៤/១៨០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩
របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា២៧ (១)

## បុព្វកថា

*រដ្ឋភាគីនៃអនុសញ្ញានេះ*

*កត់សំគាល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មី នូវជំនឿលើសិទ្ធិជាមូលដ្ឋានរបស់មនុស្ស លើសេចក្ដីថ្លៃថ្នូរ និងតម្លៃជាមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញថា* សេចក្ដីប្រកាសជាសកល ស្ដីពីសិទ្ធិមនុស្ស បញ្ជាក់នូវគោលការណ៍មិនរើសអើង និងបានប្រកាសថា មនុស្សគ្រប់រូប កើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សគ្រប់រូប ត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ ដោយគ្មានការប្រកាន់ បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង ។

*កត់សំគាល់ឃើញថា* រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស មានកាតព្វកិច្ចធានាសិទ្ធិស្មើគ្នា រវាងបុរស និងស្ត្រី ក្នុងការអាស្រ័យផល សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសិទ្ធិពលរដ្ឋ និងនយោបាយ ។

*យល់ឃើញថា* អនុសញ្ញាអន្តរជាតិ ដែលបានអនុម័តក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងការលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញពី* សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងអនុសាសន៍នានា ដែលបានអនុម័ត ដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងគោលបំណងលើកស្ទួយសមភាពនៃសិទ្ធិ រវាងបុរស និងស្ត្រី ។

*មានកង្វល់ថា* ទោះបីមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើង ដ៏វិករាលដាលប្រឆាំងនឹងស្ត្រីភេទ នៅតែបន្តកើតមាន ។

*រំលឹកឡើងវិញថា* ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រី ក្នុងលក្ខខ័ណ្ឌស្មើភាពគ្នាជាមួយបុរស ក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសំបូររុងរឿងរបស់សង្គម និងគ្រួសារ ហើយបង្កឧបសគ្គដល់ការអភិវឌ្ឍន៍ពេញលេញ នៃសក្តានុភាពរបស់ស្ត្រី ក្នុងការបម្រើប្រទេសរបស់ខ្លួន និងមនុស្សជាតិ ។

*មានកង្វល់ថា* ក្នុងស្ថានភាពក្រីក្រ ស្ត្រីភេទបានទទួលតិចបំផុតនូវម្ហូបអាហារ សេវាសុខាភិបាល ការអប់រំ ការហ្វឹកហ្វឺន និងឱកាសរកការងារធ្វើ ព្រមទាំងសេចក្តីត្រូវការដទៃទៀត ។

*ជឿជាក់ថា* ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិថ្មី ផ្អែកលើមូលដ្ឋានសមភាព និងយុត្តិធម៌ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយសមភាពរវាងបុរស និងស្ត្រី។

*គូសបញ្ជាក់ថា* ការលុបបំបាត់ចោលរបបអាផាថេត គ្រប់ទម្រង់ពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ និងជិះជាន់ ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចាំបាច់ដល់ការអាស្រ័យផលពេញលេញ ពីសិទ្ធិរបស់បុរស និងស្ត្រី ។

*អះអាងថា* ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ធូរភាពតានតឹងអន្តរជាតិ សហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងអស់ ដោយមិនគិតដល់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋទាំងនោះ ការដកហូតអាវុធជាទូទៅ និងទាំងស្រុង ជាពិសេសការដកហូតអាវុធនុយក្លេអ៊ែរ ក្រោមការត្រួតពិនិត្យហ្មត់ចត់ និងដោយប្រសិទ្ធភាពពីអន្តរជាតិ ការអះអាងនូវគោលការណ៍យុត្តិធម៌ សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងប្រទេសទាំងឡាយ និងការសម្រេចបាននូវសិទ្ធិស្វ័យសម្រេច និងឯករាជ្យភាពរបស់ប្រជាជាតិក្រោមការជិះជាន់ និងអាណានិគមបរទេស និងការកាន់កាប់ដោយបរទេស ហើយនិងការគោរពអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី នឹងលើកស្ទួយវឌ្ឍនភាព និងការអភិវឌ្ឍន៍សង្គម ហើយផលនេះនឹងរួមចំណែកដល់ការធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរស និងស្ត្រី ។

*ជឿជាក់ថា* ការអភិវឌ្ឍន៍យ៉ាងពេញលេញរបស់ប្រទេសមួយ សុខុមាលភាពរបស់ពិភពលោក និងបុព្វហេតុសន្តិភាព ត្រូវការឱ្យមានការចូលរួមជាអតិបរិមារបស់ស្ត្រី ដោយសមភាពជាមួយបុរស នៅក្នុងវិស័យទាំងអស់ ។

*ចងចាំថា* វិភាគទានធំធេងរបស់ស្ត្រី ចំពោះសុខុមាលភាពគ្រួសារ និងការអភិវឌ្ឍន៍សង្គម ដែលមិនបានទទួលស្គាល់ពេញលេញមកទល់ពេលនេះ សារសំខាន់ខាងសង្គមនៃមាតុភាព និងតួនាទីរបស់ឪពុកម្ដាយក្នុងគ្រួសារ និងក្នុងការអប់រំកូន និង*ដឹងថា* តួនាទីរបស់ស្ត្រីក្នុងការបង្កើតកូនមិនគួរជាមូលហេតុនៃការរើសអើងទេ ប៉ុន្តែការអប់រំកូនតម្រូវឱ្យចែករំលែកការទទួលខុសត្រូវរវាងបុរសនិងស្ត្រីនិងសង្គមទាំងមូល,

*ដឹងថា* តួនាទីជាប្រពៃណីរបស់បុរស និងស្ត្រីនៅក្នុងសង្គម និងគ្រួសារ ចាំបាច់ត្រូវមានការផ្លាស់ប្ដូរ ដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរសនិងស្ត្រី,

*ប្ដេជ្ញាចិត្ត* អនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងសេចក្ដីប្រកាសស្ដីពីការលុបបំបាត់នូវការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហើយដើម្បីគោលបំណងនេះ

អនុម័តវិធានការចាំបាច់នានា ដើម្បីលុបបំបាត់ការរើសអើងគ្រប់ទម្រង់ និងគ្រប់ការសម្តែង ។

*បានព្រមព្រៀងគ្នាតទៅ* ៖

## ផ្នែកទី ១

### មាត្រា ១

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យ “ការរើសអើងប្រឆាំងស្ត្រីភេទ” សំដៅដល់ការប្រកាន់ បែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ ពលរដ្ឋ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬក្នុងវិស័យដទៃទៀត ។

### មាត្រា ២

រដ្ឋភាគី ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទក្នុងគ្រប់ទម្រង់ ព្រមព្រៀងថាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយឥតពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា៖

(ក) បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្របឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឱ្យគោលការណ៍នេះ បានសម្រេចជាក់ស្តែង ។

(ខ) អនុម័តបទបញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផងបើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី,

(គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាព

ជាមួយបុរស និងធានាការពារដោយស័ក្តិសិទ្ធិដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើងតាមរយៈសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត ។

(ឃ) ទប់មិនឱ្យធ្វើអំពើ ឬការអនុវត្តន៍ដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រី និងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈ ធ្វើសកម្មភាព ស្របតាមកាតព្វកិច្ចនេះ ។

(ង) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលប់បំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ ។

(ច) ចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផងដើម្បីកែប្រែ ឬដាក់ឱ្យនិរាករណ៍ច្បាប់ បទបញ្ជា ទម្លាប់ និងការអនុវត្តន៍ណា ដែលបង្កើតការរើសអើងប្រឆាំងនឹងស្ត្រី ។

(ឆ) ដាក់ឱ្យនិរាករណ៍នូវបទបញ្ញត្តិព្រហ្មទណ្ឌណា ដែលបង្កើតជាការរើសអើងប្រឆាំងនឹងស្ត្រី ។

មាត្រា ៣

ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយសមភាពជាមួយបុរស ។

មាត្រា ៤

១. ការអនុម័តដោយរដ្ឋភាគី នូវវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនការកសាងសមភាពរវាងបុរស និងស្ត្រី មិនត្រូវចាត់ទុកជាការរើសអើងដូចបានចែងក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះតាមបែបណាមួយក៏ដោយ មិនត្រូវមានន័យថា

រក្សាទុកបទដ្ឋានវិសមភាព ឬដាច់ដោយឡែកឡើយ វិធានការទាំងនេះ ត្រូវដាក់ឱ្យនិរាករណ៍នៅពេលគោលដៅខាងសមភាពនៃឱកាស និងនៃការប្រព្រឹត្តមកលើស្ត្រីបានសម្រេចហើយ ។

២. ការអនុម័តដោយរដ្ឋភាគី នូវវិធានការពិសេស រួមមានវិធានការទាំងឡាយដែលមានក្នុងអនុសញ្ញានេះផង ដើម្បីការពារមាតុភាព មិនត្រូវចាត់ទុកជាការរើសអើងឡើយ ។

### មាត្រា ៥

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បី ៖

(ក) កែប្រែឥរិយាបថសង្គម និងវប្បធម៌របស់បុរស និងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់ចោល សេចក្ដីលំអៀង និងទំលាប់ និងការអនុវត្តន៍ជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្ដីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទំលាប់សម្រាប់បុរស និងស្ត្រី ។

(ខ) ធានាថា ការអប់រំគ្រួសារ មានរាប់បញ្ចូលការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ដែលជាមុខងាររបស់សង្គម និងការទទួលស្គាល់ការទទួលខុសត្រូវរួមរបស់បុរស និងស្ត្រី ក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូន ហើយប្រការនេះ ក៏ត្រូវមានការយល់ថា ប្រយោជន៍របស់កុមារ គឺជាល័ក្ខខ័ណ្ឌចម្បងក្នុងគ្រប់ករណីទាំងអស់។

### មាត្រា ៦

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និងអាជីវកម្មពេស្យាកម្មលើស្ត្រី ។

## ផ្នែកទី ២

### មាត្រា ៧

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើស

រើសអើងប្រឆាំងនឹងស្ត្រី ក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រី នូវលក្ខខណ្ឌស្មើភាពជាមួយបុរស នូវសិទ្ធិ ៖

(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោត សម្រាប់អង្គការសាធារណៈ ដែលជ្រើសរើសដោយការបោះឆ្នោត ។

(ខ) ចូលរួមតាក់តែង គោលនយោបាយរបស់រដ្ឋ និងការអនុវត្តន៍គោលនយោបាយ កាន់មុខការសាធារណៈ និងបំពេញមុខងារសាធារណៈ នៅគ្រប់កម្រិតជាន់ថ្នាក់របស់រដ្ឋាភិបាល ។

(គ) ចូលរួមក្នុងអង្គការ និងសមាគមក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវ-ភាពសាធារណៈ និងនយោបាយរបស់ប្រទេសជាតិ ។

## មាត្រា ៨

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ ដោយផ្អែកលើលក្ខខណ្ឌស្មើភាពជាមួយបុរស និងដោយគ្មានការរើសអើង។

## មាត្រា ៩

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួលផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគីត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឱ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិ នូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឱ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឱ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ ។

## ផ្នែកទី ៣

### មាត្រា ១០

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរស ក្នុងវិស័យអប់រំ និងជាពិសេស ដើម្បីធានាដល់ស្ត្រី ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវ ៖

(ក) លក្ខខណ្ឌដូចគ្នាសម្រាប់មុខរបរ និងការណែនាំខាងវិជ្ជាជីវៈ សម្រាប់ការទទួលការសិក្សា និងសម្រាប់ការទទួលបាន នូវសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទ ទាំងនៅជនបទ ទាំងនៅទីក្រុង ។ សមភាពនេះ ត្រូវធានាឱ្យមាន ក្នុងការអប់រំមុនបឋមសិក្សា ការអប់រំចំណេះទូទៅ បច្ចេកទេសវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យម គ្រប់ផ្នែកផងដែរ ។

(ខ) សិទ្ធិទទួលកម្មវិធីសិក្សាអប់រំដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនដែលមានគុណសម្បត្តិដូចគ្នា និងបរិវេណនិងសម្ភារៈសិក្សាដែលមានគុណភាពដូចគ្នា។

(គ) ការលុបបំបាត់រាល់ទស្សនៈជាទំលាប់ ស្តីពីតួនាទីរបស់បុរស និងស្ត្រី នៅគ្រប់កម្រិត និងគ្រប់ទម្រង់នៃការអប់រំ ដោយលើកទឹកចិត្តដល់ការអប់រំរួមគ្នា និងប្រភេទផ្សេងៗទៀតនៃការអប់រំ ដែលជួយឱ្យសម្រេចគោលបំណងនេះ និងជាពិសេសដោយពិនិត្យកែប្រែឡើងវិញនូវអត្ថបទសិក្សា និងកម្មវិធីសិក្សា និងសម្របសម្រួលវិធីសាស្ត្របង្រៀន ។

(ឃ) ឱកាសដូចគ្នា ក្នុងការទទួលអាហារូបករណ៍ និងប្រាក់សម្រាប់ការសិក្សាផ្សេងៗ ។

(ង) ឱកាសដូចគ្នា ក្នុងការទទួលកម្មវិធីអប់រំអចិន្ត្រៃយ៍ រួមមានកម្មវិធីអក្ខរកម្ម សំរាប់នីតិជន និងអនក្ខរៈជនផង ជាពិសេស កម្មវិធីទាំងឡាយសំដៅកាត់បន្ថយ

ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន នូវគម្លាតណាមួយខាងការអប់រំដែលមាន រវាងបុរស និងស្ត្រី ។

(ច) ការបន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សស្រី និងការរៀបចំកម្ម-វិធីសម្រាប់យុវនារី និងស្ត្រីដែលឆាប់បោះបង់ការសិក្សា ។

(ឆ) ឱកាសដូចគ្នា ក្នុងការចូលរួមយ៉ាងសកម្មក្នុងកីឡា និងកាយសិក្សា ។

(ជ) ការទទួលបានព័ត៌មានអប់រំពិសេសជាក់លាក់ ដើម្បីជួយធានាសុខភាព និងសុខុមាលភាពគ្រួសារ រួមមានព័ត៌មាន និងដំបូន្មានស្តីពីផែនការគ្រួសារផង ។

## មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទក្នុងវិស័យការងារ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ដើម្បីធានាបាននូវសិទ្ធិដូចគ្នា និងជាពិសេស ៖

(ក) សិទ្ធិធ្វើការងារ ដែលជាសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន របស់មនុស្សជាតិគ្រប់រូប ។

(ខ) សិទ្ធិមានឱកាសធ្វើការងារដូចគ្នា រួមមានការអនុវត្តន៍លក្ខណៈវិនិច្ឆ័យដូចគ្នាផង ក្នុងការជ្រើសរើសឱ្យធ្វើការងារ ។

(គ) សិទ្ធិជ្រើសរើសដោយសេរី នូវវិជ្ជាជីវៈ និងការងារ សិទ្ធិឡើងស័ក្តិ សិទ្ធិមានស្ថិរភាពការងារ ទទួលប្រាក់បំណាច់ និងល័ក្ខខ័ណ្ឌការងារ សិទ្ធិទទួលការបណ្តុះបណ្តាល និងវិក្រឹតការវិជ្ជាជីវៈ រួមមានការហ្វឹកហាត់ការងារ សុក្រឹតការវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជាអចិន្ត្រៃយ៍ផង ។

(ឃ) សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្មើគ្នា រួមទាំងផលប្រយោជន៍ និងសិទ្ធិទទួលបានការគិតគូរស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា និងសិទ្ធិទទួលបានការគិតគូរស្មើគ្នា លើការវាយតម្លៃគុណភាពការងារ ។

(ង) សិទ្ធិទទួលបានសន្តិសុខសង្គម ជាពិសេស ផលប្រយោជន៍សម្រាប់ការចូលនិវត្តន៍ ការគ្មានការងារធ្វើ ការមានជំងឺ ការគ្មានសុពលភាព និងជរាពាធិ ឬបាត់បង់សមត្ថភាពការងារដទៃទៀត ព្រមទាំងសិទ្ធិឈប់សម្រាកដោយមានប្រាក់ឈ្នួល ។

(ច) សិទ្ធិទទួលបានការការពារសុខភាពនិងសុវត្ថិភាពក្នុងលក្ខខណ្ឌការងាររួមមានការការពារមុខងារបន្តពូជផង ។

២. ដើម្បីបង្ការការរើសអើងប្រឆាំងនឹងស្ត្រី ផ្អែកលើអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាសិទ្ធិធ្វើការងាររបស់ស្ត្រីឱ្យបានស័ក្តិសិទ្ធិ រដ្ឋភាគីសន្យាចាត់វិធានការសមស្រប ដើម្បី ៖

(ក) ហាមឃាត់ដោយដាក់ទណ្ឌកម្មនូវការបណ្តេញចេញពីការងារ ដោយមូលហេតុមានគភ៌ ឬការឈប់សម្រាកមាតុភាព និងការរើសអើងក្នុងការបណ្តេញចេញពីការងារ ដោយផ្អែកលើស្ថានភាពរៀបអាពាហ៍ពិពាហ៍ ។

(ខ) ផ្តល់ការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល ឬប្រាក់បំណាច់សង្គមកិច្ចស្មើគ្នា ដោយគ្មានការបាត់បង់ការងារ អតីតភាពការងារឬជំនួយសង្គមកិច្ច។

(គ) ជំរុញការផ្តល់សេវាគាំពារសង្គមកិច្ចចាំបាច់ ដើម្បីឱ្យឪពុកម្តាយ អាចបញ្ចូលកាតព្វកិច្ចគ្រួសារ ជាមួយនឹងការទទួលខុសត្រូវខាងវិជ្ជាជីវៈ និងការចូលរួមក្នុងជីវភាពសាធារណៈ ជាពិសេស ដោយសម្រួលដល់ការបង្កើត និងការអភិវឌ្ឍន៍បណ្តាញនៃសម្ភារៈរូបវន្តសម្រាប់ថែទាំកុមារ ។

(ឃ) ផ្តល់ការការពារពិសេសដល់ស្ត្រីកំពុងមានគភ៌ ពីប្រភេទការងារទាំងឡាយណា ដែលបញ្ជាក់ឱ្យឃើញថាមានគ្រោះថ្នាក់ដល់ពួកគេ ។

៣. ច្បាប់ការពារស្ត្រីទាក់ទងនឹងបញ្ហាដែលបានចែងក្នុងមាត្រានេះត្រូវលើកយកមកពិនិត្យឡើងវិញជាទៀងទាត់ ទៅតាមចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស និងត្រូវកែប្រែ ធ្វើនិរាករណ៍ ឬអនុវត្តបន្តទៅតាមការចាំបាច់ ។

## មាត្រា ១២

១. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យថែទាំសុខភាព ដើម្បីធានាបាននូវសិទ្ធិទទួលសេវាសុខាភិបាល រួមមានមធ្យោបាយទាក់ទងនឹងផែនការគ្រួសារផង ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ។

២. ក្រៅពីបទបញ្ញត្តិដែលចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ រដ្ឋភាគី ត្រូវធានាដល់ស្ត្រីកំពុងមានគភ៌ កំពុងសំរាលកូន និងក្រោយពេលសំរាលកូន នូវការផ្តល់សេវាសមស្រប បើចាំបាច់ ដោយឥតគិតថ្លៃ ព្រមទាំងអាហារូបត្ថម្ភគ្រប់គ្រាន់ ក្នុងរយៈពេលមានគភ៌ និងពេលបំបៅកូន ។

## មាត្រា ១៣

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យជីវភាព សេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ដើម្បីធានានូវសិទ្ធិដូចគ្នា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ជាពិសេស ៖

(ក) សិទ្ធិទទួលបានផលប្រយោជន៍សម្រាប់គ្រួសារ ។

(ខ) សិទ្ធិខ្ចីប្រាក់ពីធនាគារ អ៊ីប៉ូតែក និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ ។

(គ) សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងគ្រប់ទិដ្ឋភាពនៃជីវភាពវប្បធម៌ ។

## មាត្រា ១៤

១. រដ្ឋភាគី ត្រូវគិតគូរដល់បញ្ហាពិសេស ដែលស្ត្រីនៅជនបទប្រឈមមុខ និងតួនាទីសំខាន់របស់ស្ត្រីជនបទ ក្នុងការរក្សាភាពគង់វង្ស សេដ្ឋកិច្ចគ្រួសាររបស់ខ្លួន

រួមមានការងាររបស់ពួកគេ ក្នុងផ្នែកគ្មានចំណូលសេដ្ឋកិច្ចផង ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ចំពោះស្ត្រីនៅជនបទ ។

២. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានានូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជនបទ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី និងជាពិសេស ត្រូវធានាឱ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ ៖

(ក) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់ ។

(ខ) មានសិទ្ធិទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាល រួមទាំងព័ត៌មាន ដំបូន្មាន និងសេវាខាងផែនការគ្រួសារ ។

(គ) ទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីសន្តិសុខសង្គម ។

(ឃ) ទទួលបានការបណ្តុះបណ្តាល និងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធគ្រប់ប្រភេទ រួមមានការអប់រំអក្ខរកម្ម បង្កើតមុខរបរផង ព្រមទាំងជាពិសេស អត្ថប្រយោជន៍ខាងសេវាសហគមន៍ និងការពន្យល់ផ្សព្វផ្សាយរបស់ថ្មី ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសរបស់ស្ត្រី ។

(ង) រៀបចំក្រុម និងសហករណ៍ ជួយគ្នាទៅវិញទៅមក ដើម្បីឱ្យមានសិទ្ធិមានឱកាសខាងសេដ្ឋកិច្ចស្មើគ្នា តាមរយៈការងារមានប្រាក់ឈ្នួល ឬការងារឯករាជ្យ។

(ច) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍ ។

(ឆ) មានសិទ្ធិទទួលបានឥណទាននិងប្រាក់កម្ចីខាងកសិកម្ម សេវារកទីផ្សារ បច្ចេកវិជ្ជាសមស្រប និងការគិតគូរស្មើគ្នាក្នុងការកែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងក្នុងគម្រោងបែងចែកដីធ្លី ។

(ជ) អាស្រ័យផលល័ក្ខខ័ណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេស ទាក់ទងនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គិសនីនិងទឹក ការដឹកជញ្ជូន និងគមនាគមន៍។

## ផ្នែកទី ៤

### មាត្រា ១៥

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសមភាពជាមួយបុរសនៅចំពោះមុខច្បាប់ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូល ដូចគ្នានឹងបុរស និងមានឱកាសដូចគ្នាដើម្បីប្រើប្រាស់ឋានៈនេះ ។ ជាពិសេស រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវឱ្យមានការប្រព្រឹត្តមកលើស្ត្រីដូចគ្នាក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជំរះក្តី។

៣. រដ្ឋភាគីព្រមព្រៀងគ្នាថា កិច្ចសន្យាទាំងអស់ និងលិខិតុបករណ៍ឯកជនដទៃទៀតគ្រប់ប្រភេទ ដែលមានអានុភាពនីត្យានុកូល សំដៅរឹតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រី ត្រូវទុកជាមោឃៈ ។

៤. រដ្ឋភាគី ត្រូវឱ្យបុរស និងស្ត្រីមានសិទ្ធិដូចគ្នាចំពោះច្បាប់ដែលទាក់ទងដល់សិទ្ធិដើរហើររបស់បុគ្គល និងសេរីភាពជ្រើសរើសទីលំនៅដ្ឋាន និងលំនៅដ្ឋាន ។

### មាត្រា ១៦

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី លើរាល់បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី ត្រូវធានាឱ្យស្ត្រីនូវ៖

(ក) សិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ។

(ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តែនៅពេលណាដែលពួកគេ ព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ ។

(គ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នា នៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។

(ឃ) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា ក្នុងនាទីជាឪពុកម្តាយ លើបញ្ហាទាក់ទងនឹងកូន ដោយឥតគិតពីស្ថានភាពគ្រួសារ ហើយអត្ថប្រយោជន៍របស់កូន ត្រូវស្ថិតជាចម្បងនៅគ្រប់ករណីទាំងអស់ ។

(ង) សិទ្ធិដូចគ្នាក្នុងការសម្រេចចិត្តដោយសេរី និងដោយស្មារតីទទួលខុសត្រូវ ក្នុងការសម្រេចអំពីចំនួន និងការពន្យាកំណើតកូន និងក្នុងការទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយ ដើម្បីឱ្យស្ត្រី អាចប្រើប្រាស់សិទ្ធិទាំងនេះ ។

(ច) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា ចំពោះអាណាព្យាបាលភាព ការការពារ ការគ្រប់គ្រង និងការទទួលចិញ្ចឹមកូនអ្នកដទៃ ឬក្នុងការអនុវត្តន៍ស្រដៀងគ្នានេះ បើគំនិតទាំងនេះមានស្រាប់នៅក្នុងច្បាប់ជាតិ ។ នៅគ្រប់ករណីទាំងអស់ អត្ថប្រយោជន៍របស់កូន ត្រូវចាត់ទុកជាចម្បង ។

(ឆ) សិទ្ធិបុគ្គលដូចគ្នារវាងប្តី និងប្រពន្ធ រួមមានសិទ្ធិជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរផង ។

(ជ) សិទ្ធិដូចគ្នាសម្រាប់ទាំងពីរនាក់ប្តី និងប្រពន្ធ ចំពោះកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី ។

២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍កូន មិនត្រូវមានអានុភាពផ្លូវច្បាប់ទេ ហើយគេ ត្រូវចាត់វិធានការចាំបាច់ទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីកំណត់អាយុអប្បបរមា សម្រាប់រៀបអាពាហ៍ពិពាហ៍ ហើយចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីជាផ្លូវការ ។

## ផ្នែកទី ៥

### មាត្រា ១៧

១. ក្នុងគោលបំណង ពិនិត្យការវិវឌ្ឍន៍ទៅមុខ នៃការអនុវត្តន៍អនុសញ្ញានេះ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ ការរើសអើងប្រឆាំងនឹងស្ត្រីមួយ ត្រូវបានបង្កើតឡើង (ចាប់ពីនេះទៅប្រើត្រឹមពាក្យ "គណៈកម្មាធិការ") ។ គណៈកម្មាធិការនេះ មានអ្នកជំនាញការ១៨រូប នៅពេលដែលអនុសញ្ញានេះចូលជាធរមាន និងនៅពេលបន្ទាប់ពីរដ្ឋភាគីទី៣៥ បានឱ្យសច្ចាប័ន ឬបានចូលជាសមាជិក នៃអនុសញ្ញានេះ គណៈកម្មាធិការនេះ នឹងមានអ្នកជំនាញការចំនួន២៣រូប ដែលមានសីលធម៌ និងមានសមត្ថកិច្ចខ្ពស់ក្នុងវិស័យដែលត្រូវអនុវត្តអនុសញ្ញានេះ។ អ្នកជំនាញការ ត្រូវបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ដោយធ្វើការពិចារណាបែងចែកទៅតាម ភូមិសាស្ត្រ ដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

២. សមាជិករបស់គណៈកម្មាធិការត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ពីបញ្ជីបេក្ខជនដែលស្នើដោយរដ្ឋភាគី ។ រដ្ឋភាគីនីមួយៗ អាចដាក់ស្នើបេក្ខជនម្នាក់ ក្នុងចំណោមជនជាតិរបស់ខ្លួន ។

៣. ការបោះឆ្នោតដំបូងបង្អស់ ត្រូវធ្វើឡើង៦ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។ យ៉ាងតិច៣ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញរដ្ឋភាគី ឱ្យដាក់ស្នើនាមបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល២ខែ ។ អគ្គលេខាធិការ ត្រូវរៀបចំតាមលំដាប់អក្សរក្រម នូវបញ្ជីឈ្មោះបេក្ខជនដែលស្នើដោយរដ្ឋភាគី ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជនទាំងនោះ ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគី ។

៤. ការបោះឆ្នោតជ្រើសរើស ត្រូវធ្វើឡើងក្នុងសម័យប្រជុំរបស់រដ្ឋភាគី តាមការកោះអញ្ជើញ ដោយអគ្គលេខាធិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគី ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

៥. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល៤ឆ្នាំ។ ប៉ុន្តែ អាណត្តិសមាជិក៩រូប ដែលជាប់នៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗ បន្ទាប់ពីការបោះឆ្នោតលើកទី១ ។

៦. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការបន្ថែម៥រូប នឹងត្រូវធ្វើឡើងស្របតាមបទបញ្ញត្តិច្បាប់ក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃមាត្រានេះ បន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកលើកទី៣៥។ អាណត្តិសមាជិក២រូប នៃសមាជិកបន្ថែមដែលជាប់ឆ្នោត នឹងត្រូវផុតកំណត់ ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង២រូបនេះ ត្រូវជ្រើសរើសតាមការចាប់ឆ្នោតដោយប្រធានគណៈកម្មាធិការ ។

៧. ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីណាដែលមានអ្នកជំនាញការរបស់ខ្លួនឈប់បំពេញមុខងារជាសមាជិកគណៈកម្មាធិការត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀត ពីចំណោមជនជាតិខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ។

៨. សមាជិកគណៈកម្មាធិការ ត្រូវទទួលថវិកា ពីធនធានរបស់អង្គការសហប្រជាជាតិ តាមចំណែក និងលក្ខខណ្ឌដែលកំណត់ដោយមហាសន្និបាត អាស្រ័យលើសារសំខាន់នៃការងាររបស់គណៈកម្មាធិការ ។

៩. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ដល់បុគ្គលិក និងសម្ភារៈបរិក្ខារ ដែលចាំបាច់សម្រាប់ គណៈកម្មាធិការបំពេញមុខងារឱ្យបានស័ក្ដិសិទ្ធិ ស្របតាមអនុសញ្ញានេះ ។

## មាត្រា ១៨

១. រដ្ឋភាគី សន្យាដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការ ពិនិត្យរបាយការណ៍ស្ដីពីវិធានការខាងនីតិកម្ម តុលាការ រដ្ឋបាល ឬវិធានការផ្សេងៗ ដែលបានអនុម័ត ផ្ដល់អានុភាពដល់បទបញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងការរីកចម្រើនដែលសម្រេចបាន ៖

(ក) ក្នុងរយៈពេល១ឆ្នាំ ក្រោយពីការចូលជាធរមាននៃអនុសញ្ញា ចំពោះរដ្ឋដែលពាក់ព័ន្ធ ។

(ខ) បន្ទាប់មក យ៉ាងហោចណាស់រៀងរាល់៤ឆ្នាំម្ដង និងរបាយការណ៍បន្ថែម បើមានសេចក្ដីស្នើសុំរបស់គណៈកម្មាធិការ ។

២. របាយការណ៍ អាចបញ្ជាក់ពីកត្តា និងការលំបាក ដែលនាំឱ្យប៉ះពាល់ដល់ការបំពេញកាតព្វកិច្ច ស្របតាមអនុសញ្ញានេះ ។

## មាត្រា ១៩

១. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

២. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើស មន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ ។

## មាត្រា ២០

១. គណៈកម្មាធិការ ត្រូវជួបប្រជុំជាធម្មតាមិនលើសពី ២សប្ដាហ៍ក្នុងមួយឆ្នាំៗ ដើម្បីពិនិត្យរបាយការណ៍ដែលស្នើឡើង ស្របតាមមាត្រា១៨ នៃអនុសញ្ញានេះ។

២. សម័យប្រជុំគណៈកម្មាធិការ ត្រូវប្រារព្ធធ្វើជាធម្មតា នៅទីស្នាក់ការ នៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របមួយផ្សេងពីនេះ អាស្រ័យដោយការកំណត់របស់គណៈកម្មាធិការ ។

## មាត្រា ២១

១. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនមហាសន្និបាតអង្គការសហប្រជាជាតិ អំពីសកម្មភាពរបស់ខ្លួន និងអាចផ្តល់យោបល់ និងផ្តល់អនុសាសន៍ទូទៅ ផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ ការផ្តល់យោបល់ និងអនុសាសន៍ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ អមដោយមូលវិចារណ៍របស់រដ្ឋភាគី ប្រសិនបើមាន ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរបាយការណ៍របស់គណៈកម្មាធិការ ទៅគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ដើម្បីជ្រាបជាព័ត៌មាន។

## មាត្រា ២២

អង្គការឯកទេស មានសិទ្ធិមានជាតំណាង នៅពេលពិនិត្យការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។ គណៈកម្មាធិការ អាចអញ្ជើញអង្គការឯកទេសនានា ឱ្យដាក់របាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។

## វគ្គទី ៦

## មាត្រា ២៣

គ្មានចំណុចណាមួយក្នុងអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិ ដែលនាំឱ្យសម្រេចបាននូវអត្ថប្រយោជន៍ខាងសមភាពរវាងបុរស និងស្ត្រី ដែលអាចមានច្រើនជាងនេះ នៅក្នុង ៖

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) អនុសញ្ញា សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ដែលនៅជាធរមានក្នុងរដ្ឋនោះ ។

### មាត្រា ២៤

រដ្ឋភាគីសន្យាអនុម័តគ្រប់វិធានការចាំបាច់ថ្នាក់ជាតិ ដើម្បីធ្វើឱ្យសម្រេចបាននូវការប្រើប្រាស់ឱ្យបានពេញលេញនូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។

### មាត្រា ២៥

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចាត់តាំងជាអ្នកទទួលដំកល់ទុកអនុសញ្ញានេះ ។

៣. អនុសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់សុំចូលជាសមាជិក ។ ការសុំចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍ សុំចូលរួមជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

### មាត្រា ២៦

១. រដ្ឋភាគី អាចសុំសើរើអនុសញ្ញានេះបាននៅគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវសម្រេចលើវិធានការដែលត្រូវចាត់ ប្រសិនជាមាន តាមសេចក្ដីសុំនោះ ។

## មាត្រា ២៧

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. សម្រាប់រដ្ឋនីមួយៗដែលឱ្យសច្ចាប័នលើអនុសញ្ញានេះ ឬសុំចូលជាសមាជិក ក្រោយពីការតំកល់លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ អនុសញ្ញានេះ នឹងត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ២៨

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយដល់រដ្ឋទាំងអស់ នូវអត្ថបទនៃខសំកូចំណូដែលរដ្ឋបានធ្វើ នៅខណៈពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ។

២. ល័ក្ខខ័ណ្ឌដែលមិនស្របតាមកម្មវត្ថុ និងគោលបំណង នៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ ។

៣. ល័ក្ខខ័ណ្ឌទាំងឡាយអាចដកចេញទៅវិញបាននៅគ្រប់ពេលវេលាដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវជូនដំណឹងនេះបន្តដល់រដ្ឋទាំងអស់ ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវមានប្រសិទ្ធភាពនៅថ្ងៃដែលបានទទួល ។

## មាត្រា ២៩

១. វាលវិវាទរវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ ស្ដីពីការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយតាមរយៈការចរចារបាន ត្រូវដាក់ឱ្យ

មានការសម្រេចដោយអាជ្ញាកណ្តាល តាមសំណើរបស់ភាគីណាមួយនៃគូវិវាទនេះ។ បើក្នុងរយៈពេល៦ខែ គិតចាប់ពីថ្ងៃស្នើឱ្យមានអាជ្ញាកណ្តាល ភាគីវិវាទ មិនឯកភាពលើការរៀបចំអាជ្ញាកណ្តាលទេ ភាគីណាមួយនៃភាគីវិវាទទាំងនោះ អាចលើករឿងវិវាទទៅតុលាការយុត្តិធម៌អន្តរជាតិតាមសេចក្តីស្នើសុំ ស្របតាមលក្ខន្តិកៈរបស់តុលាការ.

២. រដ្ឋភាគីនីមួយៗ នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ អាចប្រកាសថា ខ្លួនមិនជាប់កាតព្វកិច្ចនឹងកថាខណ្ឌ១ នៃមាត្រានេះទេ ។ រដ្ឋភាគីឯទៀត នឹងមិនជាប់កាតព្វកិច្ចក្នុងកថាខណ្ឌ១ នេះ ជាមួយរដ្ឋភាគីណាដែលបានធ្វើលំកូខ័ណ្ឌនេះឡើយ ។

៣. រដ្ឋភាគីណាដែលធ្វើលំកូខ័ណ្ឌស្របតាមកថាខណ្ឌ២ នៃមាត្រានេះ អាចដកលំកូខ័ណ្ឌរបស់ខ្លួនវិញគ្រប់ពេល ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៣០

អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា នឹងត្រូវតំកល់ទុកនៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ជាបន្ទាល់នៃអនុសញ្ញានេះ បុណ្ណទូតដែលមានហត្ថលេខាខាងក្រោម ហើយដែលបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

# ពិធីសារបន្ថែមលើអនុសញ្ញា ស្តីពី
# ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចចិត្តលេខ:A.៥៤/៤ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៩ និងបើកឱ្យចុះហត្ថលេខា នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៩ ក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ និងចូលជាធរមាននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០

*រដ្ឋភាគីនៃពិធីសារនេះ*

*កត់សំគាល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មី នូវជំនឿលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញផងដែរថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សប្រកាសថា មនុស្សគ្រប់រូប កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សគ្រប់រូបត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង ។

*រំលឹកឡើងវិញថា* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស សេចក្តីសំរេចចិត្តលេខ ២២០០A(XXI) ឧបសម្ព័ន្ធ និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ហាមឃាត់ការរើសអើងខាងផ្លូវភេទ ។

*រំលឹកឡើងវិញផងដែរថា* អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ("អនុសញ្ញា") ដែលរដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទ ក្នុងគ្រប់ទម្រង់ និងការព្រមព្រៀងគ្នាអនុវត្តគោល

នយោបាយ តាមមធ្យោបាយសមស្រប និងដោយគ្មានការពន្យាពេល ដើម្បីឈាន ទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ។

*អះអាងជាថ្មី* ការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីធានាឱ្យស្ត្រីទទួលបានយ៉ាងពេញលេញ និងស្មើភាពគ្នា នូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ និងចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភលើសិទ្ធិសេរីភាពទាំងនេះ ។

បានព្រមព្រៀងគ្នាដូចតទៅ ៖

## មាត្រា ១

រដ្ឋភាគីនៃពិធីសារនេះ ( "រដ្ឋភាគី") អាចប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (គណៈកម្មាធិការ) ក្នុងការទទួល និងពិនិត្យបណ្តឹងដែលបានបញ្ជូន ស្របតាមមាត្រា២ ។

## មាត្រា ២

បុគ្គល អាចដាក់ពាក្យបណ្តឹងរបស់ខ្លួន ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គលផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋភាគី ដែលបុគ្គលអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ ប្រសិនបើបណ្តឹងមួយ ធ្វើឡើងក្នុងនាមបុគ្គល ឬក្រុមបុគ្គល បណ្តឹងនេះ ត្រូវតែមានការយល់ព្រមពីបុគ្គលទាំងនោះ បើពុំនោះទេ អ្នកប្តឹងអាចបញ្ជាក់អះអាងលើពាក្យបណ្តឹងក្នុងនាមពួកគេ ដោយមិនចាំបាច់មានការយល់ព្រមឡើយ ។

## មាត្រា ៣

បណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយមិនត្រូវជាបណ្តឹងអនាមិកឡើយ។ គណៈកម្មាធិការ មិនទទួលបណ្តឹងមកពិនិត្យទេ បើបណ្តឹងនោះ ពាក់ព័ន្ធនឹងរដ្ឋភាគីនៃអនុសញ្ញា ដែលមិនមែនជាភាគីនៃពិធីសារនេះ ។

## មាត្រា ៤

១. គណៈកម្មាធិការមិនទទួលពិនិត្យបណ្តឹងទេលើកលែងតែមានការបញ្ជាក់ច្បាស់ថា បានប្រើប្រាស់អស់នូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក បើពុំនោះទេ ការប្រើប្រាស់ដំណោះស្រាយនេះ បានអូសបន្លាយរយៈពេលយូរហួសហេតុ ឬមិនទំនងជានាំមកនូវការជួយឱ្យធូរស្បើយបានស័ក្តិសិទ្ធិ ។

២. គណៈកម្មាធិការត្រូវប្រកាសថាមិនទទួលដោះបណ្តឹងទេប្រសិនបើ ៖

ក. បញ្ហាដដែលនេះត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ ឬត្រូវបាន និងកំពុងពិនិត្យ ស្របតាមនីតិវិធីនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ ។

ខ. ជាប្រការផ្ទុយនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

គ. មិនបានបញ្ជាក់មូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សំរាប់ធ្វើជាអំណះអំណាង ។

ឃ. ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ។

ង. អង្គហេតុដែលជាកម្មវត្ថុនៃបណ្តឹងបានកើតមាន នៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះសំរាប់ រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេលុះត្រាតែអង្គហេតុនោះបានបន្តរហូតដល់ក្រោយកាលបរិច្ឆេទនៃពិធីសារនេះ។

## មាត្រា ៥

១. នៅគ្រប់ពេល បន្ទាប់ពីការទទួលបណ្តឹង និងនៅមុនពេលឈានដល់ការសំរេចលើអង្គសេចក្តី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់ លើសំណើដែលរដ្ឋភាគីចាត់វិធានការបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជៀសវាងការអាចកើតមាននូវការគេចវេះ មិនជួសជុលសំណងការខូចខាត ដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលអះអាងថាបានទទួលរងការរំលោភ ។

២. ប្រសិនបើគណៈកម្មាធិការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ នោះមិនបានបញ្ជាក់ថាជាការសំរេចទទួលយក ឬការសំរេចលើអង្គសេចក្ដីនៃបណ្ដឹងឡើយ ។

## មាត្រា ៦

១. ប្រសិនបើគណៈកម្មាធិការយល់ថា មិនអាចទទួលពាក្យបណ្ដឹង ដោយមិនបញ្ជូនបណ្ដឹងនោះ ទៅរដ្ឋភាគីពាក់ព័ន្ធ ហើយបុគ្គលម្នាក់ ឬច្រើននាក់យល់ព្រមបង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់រដ្ឋភាគីនោះ គណៈកម្មាធិការ ត្រូវផ្ដល់ដំណឹងជាសំងាត់ដល់រដ្ឋភាគីពាក់ព័ន្ធអំពីបណ្ដឹងដែលបានបញ្ជូនមកឱ្យខ្លួនស្របតាមពិធីសារនេះ។

២. ក្នុងរយៈពេល៦ខែ រដ្ឋចុងចំលើយត្រូវបញ្ជូនការពន្យល់ជាលាយលក្ខណ៍អក្សរ ឬសេចក្ដីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះ ប្រសិនជាមាន ទៅគណៈកម្មាធិការ ។

## មាត្រា ៧

១. គណៈកម្មាធិការ ត្រូវពិនិត្យបណ្ដឹងដែលទទួលបាន ស្របតាមពិធីសារនេះ ចំពោះព័ត៌មានដែលផ្ដល់មកឱ្យខ្លួន ដោយបុគ្គល ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ហើយព័ត៌មាននេះត្រូវបានបញ្ជូនទៅភាគីពាក់ព័ន្ធដទៃទៀត ។

២. គណៈកម្មាធិការ ត្រូវប្រជុំជាសម្ងាត់ នៅពេលពិនិត្យបណ្ដឹង ស្របតាមពិធីសារនេះ ។

៣. បន្ទាប់ពីពិនិត្យបណ្ដឹងរួច គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញអំពីបណ្ដឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួន ទៅភាគីពាក់ព័ន្ធប្រសិនជាមាន ។

៤. រដ្ឋភាគី ត្រូវធ្វើការពិនិត្យឱ្យបានត្រឹមត្រូវ ចំពោះការយល់ឃើញរបស់

គណៈកម្មាធិការ រួមជាមួយអនុសាសន៍របស់ខ្លួន ប្រសិនជាមាន ហើយត្រូវបញ្ជូនចំលើយជាលាយល័ក្ខណ៍អក្សរទៅគណៈកម្មាធិការក្នុងរយៈពេល៦ខែ រួមទាំងព័ត៌មានស្តីពីវិធានការដែលបានចាត់ឡើង ទាក់ទងនឹងការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ។

៥. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគី ឱ្យផ្តល់ព័ត៌មានបន្ថែមស្តីពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឡើង ឆ្លើយតបទៅនឹងការយល់ឃើញ និងអនុសាសន៍របស់ខ្លួន ប្រសិនជាមាន តាមដែលគណៈកម្មាធិការយល់ថា សមស្រប នៅក្នុងរបាយការណ៍បន្តបន្ទាប់មកទៀតរបស់រដ្ឋភាគី ស្របតាមមាត្រា១៨នៃអនុសញ្ញានេះ។

## មាត្រា ៨

១. ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មានគួរឱ្យទុកចិត្ត ដែលបង្ហាញឱ្យឃើញពីការរំលោភធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ដោយរដ្ឋភាគីទៅលើសិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះ ឱ្យសហការពិនិត្យព័ត៌មាន និងផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានពាក់ព័ន្ធ ។

២. តាមការពិនិត្យសេចក្តីសង្កេត ដែលរដ្ឋភាគីពាក់ព័ន្ធបញ្ជូនមក រួមមានព័ត៌មានពាក់ព័ន្ធសមស្របផ្សេងទៀតផង គណៈកម្មាធិការ អាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ ឱ្យស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។ ប្រសិនជាចាំបាច់ និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបអង្កេតនេះ អាចរួមទាំងការធ្វើទស្សនកិច្ចទៅកាន់ទឹកដីនៃរដ្ឋនោះ ។

៣. ក្រោយពីការពិនិត្យសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតនេះ គណៈកម្មាធិការ ត្រូវបញ្ជូនសេចក្តីសន្និដ្ឋានទាំងនេះទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ ឬអនុសាសន៍ ។

៤. ក្នុងរយៈពេល៦ខែ នៃការទទួលសេចក្ដីសន្និដ្ឋាន ការផ្ដល់យោបល់ និង អនុសាសន៍ ដែលគណៈកម្មាធិការបានបញ្ជូន រដ្ឋភាគីពាក់ព័ន្ធត្រូវបញ្ជូនសេចក្ដីសង្កេតរបស់ខ្លួនទៅគណៈកម្មាធិការ ។

៥. ការស៊ើបអង្កេតនេះ ត្រូវធ្វើជាសំងាត់ និងត្រូវស្វែងរកកិច្ចសហការពីរដ្ឋភាគី នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ ។

## មាត្រា ៩

១. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ ឱ្យបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន ស្របតាមមាត្រា១៨នៃអនុសញ្ញានេះ នូវព័ត៌មានលម្អិតពីវិធានការដែលខ្លួនបានអនុម័ត ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតដែលបានធ្វើឡើង ស្របតាមមាត្រា៨ នៃពិធីសារនេះ ។

២. ប្រសិនជាចាំបាច់ បន្ទាប់ពីផុតរយៈពេល៦ខែ ដូចមានចែងក្នុងមាត្រា ៨.៤ គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្ដល់ព័ត៌មានមកខ្លួន អំពីវិធានការដែលបានចាត់ឡើង ឆ្លើយតបទៅនឹងការស៊ើបអង្កេតនេះ ។

## មាត្រា ១០

១. នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារនេះ រដ្ឋភាគីនីមួយៗ អាចប្រកាសថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា៨ និងមាត្រា៩ ។

២. រដ្ឋភាគីណាមួយដែលបានធ្វើសេចក្ដីប្រកាស ស្របតាមកថាខណ្ឌទី១ នៃមាត្រានេះអាចដកសេចក្ដីប្រកាសនេះវិញបានគ្រប់ពេលវេលា តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ ។

### មាត្រា ១១

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មិនមែនជាកម្មវត្ថុនៃការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ ឬការបំភិតបំភ័យ ដោយសារតែខ្លួនបានប្ដឹងទៅគណៈកម្មាធិការ ស្របតាមពិធីសារនេះ ។

### មាត្រា ១២

គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ក្រោមមាត្រា២១នៃអនុសញ្ញានេះ នូវសេចក្ដីសង្ខេបស្ដីពីសកម្មភាពរបស់ខ្លួន ស្របតាមពិធីសារនេះ ។

### មាត្រា ១៣

រដ្ឋភាគីនីមួយៗមានភារៈកិច្ចផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជាសាធារណៈអំពីអនុសញ្ញា និងពិធីសារនេះ និងដើម្បីជួយសម្រួលដល់ការទទួលបានព័ត៌មានអំពីការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ជាពិសេសអំពីបញ្ហាដែលពាក់ព័ន្ធនឹងរដ្ឋភាគីនោះ ។

### មាត្រា ១៤

គណៈកម្មាធិការ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សម្រាប់អនុវត្ត នៅពេលបំពេញតួនាទីដែលពិធីសារនេះបានប្រគល់ឱ្យខ្លួន ។

### មាត្រា ១៥

១. ពិធីសារនេះ បើកឱ្យចុះហត្ថលេខា ដោយរដ្ឋភាគីដែលបានចុះហត្ថលេខាឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ដោយរដ្ឋណាមួយដែលបាន ឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ បើកឱ្យចូលជាសមាជិកដោយរដ្ឋភាគីណាមួយ ដែលបាន ឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

៤. ការចូលជាសមាជិក ត្រូវចូលជាធរមាន ដោយការតំកល់លិខិតុបករណ៍ ចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៦

១. ពិធីសារនេះ ចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃ ការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី១០ នៅនឹងអគ្គលេខាធិការ អង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬចូលជាសមាជិក បន្ទាប់ពីពិធីសារ នេះចូលជាធរមាន ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាល បរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ១៧

មិនអនុញ្ញាតឱ្យមានលក្ខខណ្ឌណាមួយ ចំពោះពិធីសារនេះឡើយ ។

## មាត្រា ១៨

១. រដ្ឋភាគីអាចស្នើសុំធ្វើវិសោធនកម្មពិធីសារនេះ និងដាក់សេចក្ដីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្ដីស្នើ វិសោធនកម្មទៅរដ្ឋភាគីទាំងអស់ ដោយស្នើសុំឱ្យរដ្ឋភាគីទាំងនោះបញ្ជាក់ប្រាប់ខ្លួនថា តើរដ្ឋភាគីយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើ

សេចក្តីស្នើសុំឬទេ ។ ក្នុងករណីមានសំលេង១ភាគ៣ យ៉ាងតិច នៃរដ្ឋភាគី ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មត្រូវចូលជាធរមាន នៅពេលវិសោធនកម្មនេះ ទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយកដោយសំលេងភាគច្រើន២ភាគ៣នៃរដ្ឋភាគីនៃពិធីសារនេះ អាស្រ័យតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះនឹងក្លាយជាកាតព្វកិច្ចសំរាប់រដ្ឋភាគី ដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែចងភ្ជាប់ដោយបទបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលរដ្ឋភាគីនោះ បានយល់ព្រមទទួលយក ។

## មាត្រា ១៩

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួន មានអានុភាពក្នុងរយៈពេល៦ខែ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានការជូនដំណឹង ។

២. ការប្រកាសដកខ្លួននេះ មិនត្រូវឱ្យប៉ះពាល់ដល់ការបន្តអនុវត្តបទបញ្ញត្តិនៃពិធីសារនេះចំពោះបណ្តឹងណាមួយដែលបានស្នើឡើងក្រោមមាត្រា២ ឬការស៊ើបអង្កេតណាមួយដែលបានផ្តើមធ្វើ ស្របតាមមាត្រា៨ នៅមុនកាលបរិច្ឆេទចូលជាធរមាននៃការប្រកាសដកខ្លួននេះឡើយ ។

# ឧបសម្ព័ន្ធទី២

# ផ្នែកទី៥. សកម្មភាពការងារ

## យុទ្ធសាស្ត្រស្នូល៖ គ្រប់គ្រងការប្រើប្រាស់យេនឌ័រ

**គោលបំណង៖** ពង្រឹងសមត្ថភាពយន្តការនៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការតាក់តែងនិងអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងតាមវិស័យនៅគ្រប់កម្រិត ប្រកបដោយសមធម៌និងបរិយាបន្ន និងពង្រីកកម្មវិធីផ្លាស់ប្តូរឥរិយាបថរបស់សង្គម ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១.ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវនិងប៉ាន់ប្រមាណស្ថានភាពយេនឌ័រ ព្រមទាំងការរៀបចំ និងអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងកម្មវិធីតាមវិស័យ | ចំនួនឯកសារស្តីពីការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា ត្រូវបានចងក្រង និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា (ជ្រើសរើសទីប្រឹក្សាបច្ចេកទេស កិច្ចប្រជុំពិភាក្សាផ្ទៃក្នុង កិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ កែសម្រួលបញ្ចប់ និងបោះពុម្ព) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | | | ✓ | ✓ |
| | គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័ត និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំ និងតាក់តែងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ (កិច្ចប្រជុំពិភាក្សាផ្ទៃក្នុង កិច្ចប្រជុំជាមួយដៃគូពាក់ព័ន្ធ កែសម្រួល និងបោះពុម្ព) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល វិស័យឯកជន | ✓ | ✓ | | | | ✓ | ✓ |
| | -ចំនួនប្រភេទសម្ភារៈផ្សព្វផ្សាយដែលបានរៀបចំ<br>-ចំនួនប្រព័ន្ធផ្សព្វផ្សាយដែលបានប្រើប្រាស់<br>-ចំនួនអ្នកចូលរួមក្នុងសិក្ខាសាលា ផ្សព្វផ្សាយ | រៀបចំសម្ភារៈសម្រាប់ផ្សព្វផ្សាយលើឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិលនិងវិស័យឯកជន | | ✓ | ✓ | | | ✓ | ✓ |
| | | រៀបចំសិក្ខាសាលាផ្សព្វផ្សាយឯកសារការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រដល់គ្រប់អ្នកពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល | | ✓ | ✓ | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ការងារចុះអភិបាល | | | | | | | | |
| | កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ ដែលមានសមាសភាព និងសូចនាករជាក់លាក់ ដែលឆ្លើយតបនឹងយេនឌ័រ ក្នុងរដ្ឋបាលសាធារណៈ<br><br>ចំនួនលិខិតបទដ្ឋាន និងកម្មវិធីនានា ក្នុងក្របខណ្ឌកម្មវិធីជាតិ ដែលឆ្លើយតបយេនឌ័រ | គាំទ្របច្ចេកទេស ក្នុងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ នៅក្នុងការរៀបចំ និងអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០២០-២០៣០<br><br>បញ្ជ្រាបយេនឌ័រនៅក្នុងលិខិតបទដ្ឋាន និងកម្មវិធីនានា ក្នុងក្របខណ្ឌកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០ | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនក្រសួង ស្ថាប័នដែលមានប្រព័ន្ធតាមដាននិងវិភាជថវិកាសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព ស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ ដល់ក្រុមការងារយេនឌ័រក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញថវិកា<br><br>ចងក្រងមេរៀនបទពិសោធន៍ និងឧត្តមានុវត្តន៍នានា ក្នុងការរៀបចំថវិកាដែលឆ្លើយតបយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័ន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣.ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពយន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិតរួមទាំងការគាំទ្រដល់ក្រុមការងារ | -គោលការណ៍ណែនាំ និងឧបករណ៍ ត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយ | រៀបចំគោលការណ៍ណែនាំ និងឧបករណ៍អនុវត្តស្តីពីការបញ្ជ្រាបនិងធ្វើស្ថាប័នីយកម្មយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងក្រសួង-ស្ថាប័ន | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូពាក់ព័ន្ធ | | ✓ | ✓ | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. ជំរុញ និងសម្របសម្រួលការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខណ្ឌផែនការយុទ្ធ-សាស្ត្រ តាមវិស័យនិងកម្មវិធីជាតិ រួមទាំងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ចំនួនលិខិតបទដ្ឋានគតិយុត្តដែលឆ្លើយតបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ដែលបានរៀបចំ | គាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័នក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់លើលិខិតបទដ្ឋានគតិយុត្ត ឱ្យឆ្លើយតបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>លេខាធិការដ្ឋានគ.ជ.អ.ប | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | របាយការណ៍តាមដាន និងវាយតម្លៃ លើការអនុវត្តផែនការយុទ្ធសាស្ត្រ បានរៀបចំ និងផ្សព្វផ្សាយ | សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ជំរុញ តាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខដំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនសវនកម្មយេនឌ័រដែលបានធ្វើ<br>ចំនួនរបាយការណ៍សវនកម្មដែលបានចងក្រង បោះពុម្ព និងផ្សព្វផ្សាយ | ភាពជាដៃគូជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ធ្វើសវនកម្មយេនឌ័រក្នុងការអនុវត្តផអ៣ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | | | ✓ | | | ✓ | ✓ |
| | ចំនួនដងនៃការចុះអភិបាល ផ្តល់ការគាំទ្របច្ចេកទេសដល់មន្ទីរកិច្ចការនារី គ.ក.ស.ក និង គ.ក.ន.ក<br>ចំនួនមន្ត្រីដែលបានទទួលការគាំទ្របច្ចេកទេសដោយក្រសួង | ផ្តល់ការគាំទ្របច្ចេកទេស និងពង្រឹងសមត្ថភាព មន្ទីរកិច្ចការនារី គ.ក.ស.ក និងគ.ក.ន.ក ក្នុងការបញ្ជ្រាបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋានគ.ជ.អ.ប<br>មន្ទីរកិច្ចការនារី គ.ក.ស.ក<br>គ.ក.ន.ក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បញ្ជ្រាបយេនឌ័រ តាមក្រសួង-ស្ថាប័ន ក្រុមការងារបច្ចេកទេសយេនឌ័រ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់និងដៃគូពាក់ព័ន្ធ | -ចំនួនរបាយការណ៍ស្រាវជ្រាវបានចងក្រងនិងផ្សព្វផ្សាយ<br><br>-កម្មវិធីអភិវឌ្ឍសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ | សិក្សាស្រាវជ្រាវ និងរៀបចំក្របខណ្ឌអភិវឌ្ឍសមត្ថភាព ដល់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ | | | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនក្រុមការងារយេនឌ័រ ក្រសួង ស្ថាប័ន ដែលបានទទួលការអភិវឌ្ឍសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | អភិវឌ្ឍសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារ និងគណនេយ្យភាពលើការអនុវត្តគោលនយោបាយស្តីពីសមភាពយេនឌ័រ តាមរយៈក្របខណ្ឌអភិវឌ្ឍសមត្ថភាព និងការអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ | ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ និងក្រោមជាតិ | | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនក្រសួង ស្ថាប័នដែលបានទទួលការគាំទ្រក្នុងការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី<br><br>-ចំនួនក្រសួង ស្ថាប័នដែលមាន ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (GMAPs) និងបានធ្វើបច្ចុប្បន្នភាព | គាំទ្របច្ចេកទេសដល់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ នៅថ្នាក់ជាតិ និងក្រោមជាតិក្នុងការបញ្ជ្រាបយេនឌ័រ ក៏ដូចជាក្នុងការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងការបញ្ជ្រាបយេនឌ័រក្នុងសេចក្តីព្រាងគោលនយោបាយ កម្មវិធីតាមវិស័យ (តាមរយៈកិច្ចប្រជុំ ការចុះអភិបាល.) | ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ និងក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | -ចំនួនកិច្ចប្រជុំប្រចាំឆមាស និងឆ្នាំរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័នដែលបានរៀបចំ<br>-ចំនួនរបាយការណ៍កិច្ចប្រជុំដែលបានចងក្រង | រៀបចំកិច្ចប្រជុំបណ្តាញក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័នប្រចាំឆមាស និងឆ្នាំ ដើម្បីឆ្លុះបញ្ចាំង និងចែករំលែកអំពីវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅបន្ត | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង ស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារបច្ចេកទេសយេនឌ័រ និង ក្រុមការងារ TWG-WLG ដែលបានរៀបចំ | រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងគាំទ្រដំណើរការការងាររបស់ក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) និងក្រុមការងារ ក្នុងក្របខណ្ឌសូចនាករតាមដានរូមស្តីពីយេនឌ័រ | លេខាធិការដ្ឋាន TWG-G<br>ក្រសួង ស្ថាប័ននិងដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនអង្គភាព និងមន្ត្រីជំនាញក្នុងក្រសួងកិច្ចការនារី ដែលរីកចម្រើនលើជំនាញវិភាគនិងបញ្ជ្រាបយេនឌ័រតាមវិស័យ ដោយអនុវត្តស្របតាមក្របខណ្ឌអភិវឌ្ឍសមត្ថភាពស្ថាប័ន | សម្របសម្រួលរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញអង្គភាពនិងស្ថាប័នក្រសួងកិច្ចការនារី ក្នុងការវិភាគ និងបញ្ជ្រាបយេនឌ័រតាមវិស័យ | លេខាធិការដ្ឋាន TWG-G<br>ក្រសួង និងមន្ទីរកិច្ចការនារី<br>ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. លើកកម្ពស់ការចូលរួមរបស់យុវជន និងស្ត្រីវ័យក្មេង | ចំនួនកម្មវិធីភាពជាអ្នកដឹកនាំសម្រាប់យុវជន និងស្ត្រីវ័យ | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាព និងអនុវត្តន៍គំនិតផ្តួចផ្តើមនានា ក្នុងការ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ដែលឆ្លើយតបនឹងយេនឌ័រ | ក្មេង ដែលបានអនុវត្ត ក្រោមកិច្ចសម្របសម្រួល ដោយក្រសួងកិច្ចការនារី ចំនួនយុវជន និងស្ត្រីវ័យក្មេង ដែលចូលរួមក្នុងកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំ និងយេនឌ័រ ក្រោមកិច្ចសម្របសម្រួល ដោយក្រសួងកិច្ចការនារី | អភិវឌ្ឍភាពជាអ្នកដឹកនាំ អភិបាលកិច្ច ដែលឆ្លើយតបយេនឌ័រដល់យុវជន និងស្ត្រីវ័យក្មេង (វគ្គបណ្តុះបណ្តាល ការចុះកម្មសិក្សា ការបោះជំរុំ ទស្សនកិច្ចសិក្សា និងតាមមធ្យោបាយបច្ចេកវិទ្យានានា) | ក្រសួងអប់រំយុវជននិងកីឡា សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | | | | | | | |
| | ចំនួនយុវជន និងស្ត្រីវ័យក្មេង ដែលបានចូលរួមការងារស្ម័គ្រចិត្ត ហាត់ការ និងដែលបានបង្ហាញពីសក្តានុពល ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំ ក្នុងកម្មវិធីរបស់ក្រសួងកិច្ចការនារី | សម្របសម្រួល និងអនុវត្តកម្មវិធីផ្តល់ឱកាសដល់យុវជន និងស្ត្រីវ័យក្មេង ចូលរួមធ្វើការស្ម័គ្រចិត្ត និងបង្ហាញពីសក្តានុពល ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំនៅតាមមូលដ្ឋាន និងស្ថាប័ន | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន ដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនយុទ្ធនាការ/វេទិកាចែករំលែកបទពិសោធន៍ | យុទ្ធនាការ វេទិកាចែករំលែកបទពិសោធន៍ក្នុងភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័ររវាងយុវជនជំនាន់មុន នាបច្ចុប្បន្ន និងជំនាន់ក្រោយ | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន សាកលវិទ្យាល័យ ដៃគូពាក់ព័ន្ធ និងសង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី៦៖ ការបញ្ជ្រាបយេនឌ័រ ក្នុងការប្រែប្រួលអាកាសធាតុ

**គោលបំណង៖** លើកកម្ពស់សមភាពយេនឌ័រ ក្នុងដំណើរការតាក់តែង និងអនុវត្តគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| ១.ពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | -ឯកសារបណ្តុះបណ្តាល ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ បានរៀបចំនិងធ្វើបច្ចុប្បន្នភាព<br>-ចំនួនអ្នកទទួលផលផ្ទាល់ពីការអនុវត្តសកម្មភាពការកសាងសមត្ថភាពបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-ចំនួនឯកសារ សម្ភារៈផ្សព្វផ្សាយដែលបានផលិត និងប្រើប្រាស់ ដោយបណ្តាញនិងដៃគូតាមរយៈប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងកិច្ចការនារី | -រៀបចំឯកសារស្តីពីការវិភាគនិងបញ្ជ្រាបយេនឌ័រ ក្នុងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (សម្រាប់អ្នកតាក់តែងគោលនយោបាយនិងសាធារណៈជន)<br>-អភិវឌ្ឍសមត្ថភាពពាក់ព័ន្ធយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-រៀបចំកម្មវិធីបង្កើនការយល់ដឹង និងផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យា និងមធ្យោបាយទំនើបលើការលើកកម្ពស់សមភាពយេនឌ័រក្នុងការឆ្លើយតបការប្រែប្រួល អាកាសធាតុ ការអភិវឌ្ឍបៃតង និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រសួងបរិស្ថាន<br>ក្រសួងមហាផ្ទៃ<br>គ.ជ.អ.ប<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២. បញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែងនិងអនុវត្តគោលនយោបាយ កម្មវិធី និង | គោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ | -សម្របសម្រួលនិងគាំទ្របច្ចេកទេសក្នុងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងដំណើរការរៀបចំ និងអនុវត្តគោល | ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញបឹងទន្លេសាប និងទន្លេមេគង្គមានភាពប្រសើរឡើង | ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងតំបន់ជុំវិញទន្លេសាប និងទន្លេមេគង្គដែលឆ្លើយតបនឹងយេនឌ័រ | នយោបាយ កម្មវិធី ផែនការយុទ្ធសាស្ត្រវិស័យពាក់ព័ន្ធអាទិភាព<br>-សហការជាមួយដៃគូអភិវឌ្ឍន៍បង្កើតសូចនាករ ឧបករណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងយេនឌ័រ នៅក្នុងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ប្រែប្រួលអាកាសធាតុ<br>អាកាសធាតុ ក្រសួងបរិស្ថាន<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | | | | | |
| ៣. គាំទ្រ និងបង្កើតគំនិតផ្តួចផ្តើមនានា ក្នុងការឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមស្ត្រី ក្មេងស្រីដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | ចំនួនកម្មវិធីជាក់លាក់ ដែលឆ្លើយតបនឹងតម្រូវការស្ត្រី និងក្រុមងាយរងគ្រោះ បានដោះស្រាយនៅក្នុងដំណើរការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (កិច្ចការដែលស្ថិតនៅក្រោមការសម្របសម្រួល និងដឹកនាំដោយក្រសួងកិច្ចការនារី) | -សិក្សាស្រាវជ្រាវស្វែងរកពីតម្រូវការជាក់លាក់របស់ស្ត្រីនិងក្រុមងាយរងគ្រោះ និងរៀបចំអនុសាសន៍ឆ្លើយតប<br>-គាំទ្រកម្មវិធី គម្រោងគំនិតផ្តួចផ្តើមថ្មីៗ ដែលឆ្លើយតបតម្រូវការជាក់ស្តែងសម្រាប់ស្ត្រីនិងក្រុមងាយរងគ្រោះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីគ្រប់គ្រងនិងឆ្លើយតបគ្រោះមហន្តរាយ កម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង | ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>ក្រសួងវិស័យពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. រៀបចំប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងចែករំលែកព័ត៌មាននិងការសិក្សាស្រាវជ្រាវថ្មីៗ ស្តីពីផលប៉ះពាល់យេនឌ័រដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ | ចំនួនសិក្សាស្រាវជ្រាវស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដែលបានរៀបចំ និងចែករំលែកដោយកកន និងដៃគូអភិវឌ្ឍន៍ | -ភាពជាដៃគូក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទថ្មីៗពាក់ព័ន្ធយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>-រៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រ ក្នុងការផលិត ចែករំលែកព័ត៌មានឱ្យបាន | ក្រសួងកិច្ចការនារី<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង<br>ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ទូលំទូលាយ ស្របតាមបច្ចេកវិទ្យាទំនើប និងដល់ដៃអ្នកប្រើប្រាស់ | ក្រសួងបរិស្ថាន CDRI, CARDI, RUPPដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល | | | | | | | |

## យុទ្ធសាស្ត្រគាំទ្រស្ថាប័ន៖ ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន

**គោលបំណង៖** លើកកម្ពស់សមត្ថភាពរបស់ក្រសួងកិច្ចការនារី និងអង្គភាពចំណុះ ក្នុងការពង្រឹងភាពស្អាតស្អំ លើរដ្ឋបាលសាធារណៈ និងពង្រឹងប្រសិទ្ធភាពក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ក្នុងការអនុវត្តការងារ ព្រមទាំងយន្តការគ្រប់គ្រងនិងផ្សព្វផ្សាយព័ត៌មានឱ្យឆ្លើយតបយេនឌ័រ និងបរិយាបន្ន ។

| យុទ្ធសាស្ត្រ | សូចនាករ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០១៩-២០២៣) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១៩ | ២០ | ២១ | ២២ | ២៣ | ជាតិ | ដៃគូ |
| វិបារណកម្មមុខងារ និងភារកិច្ចនិងការអនុវត្តការងារផ្អែកលើលទ្ធផល | | | | | | | | | | |
| ១. វិបារណកម្មមុខងារ និងភារកិច្ច និងការអនុវត្តការងារផ្អែកលើលទ្ធផល | មន្ត្រីត្រូវបានតែងតាំងនិងសម្រួលភារកិច្ច ស្របតាមជំនាញអតីតភាពការងារ និងកន្លែងទំនេរ | ដំណើរការប្រព័ន្ធវាយតម្លៃ និងធ្វើសំណើសុំតម្លើងឋានៈ និងសម្រួលភារកិច្ចទៅតាមនិតិវិធី និងឋានានុក្រម អនុវត្តតាមលិខិតបទដ្ឋានគតិយុត្ត ជាធរមាន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | | |
| | ការតែងតាំងនាមុខតំណែង (ថ្នាក់ជាតិ និងក្រោមជាតិ) ត្រូវបានដាក់ឱ្យអនុវត្តន៍ | រៀបចំតែងតាំងនាមុខតំណែងភារកិច្ចរបស់អង្គភាពចំណុះក្រសួង និងតាមមុខតំណែងនីមួយៗ | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | | | | |
| | អនុក្រឹត្យស្តីពីការរៀបចំការនិងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារីត្រូវបានធ្វើវិសោធនកម្ម | រៀបចំវិសោធនកម្ម និងផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការរៀបចំការនិងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី | អន្តរនាយកដ្ឋាន | ✓ | ✓ | | | | | |
| | របាយការណ៍វឌ្ឍនភាព សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងកិច្ចការនារី ផ្តោតលើការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបទ្ទាត់គណនេយ្យភាពច្បាស់លាស់របស់អង្គភាពនីមួយៗ | ពង្រឹងប្រព័ន្ធមុខងារ និងដំណើរការធ្វើអធិការកិច្ច សវនកម្ម ការអនុវត្តផែនការ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងកិច្ចការនារី ក្នុងស្មារតីពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបទ្ទាត់គណនេយ្យភាពច្បាស់លាស់របស់អង្គភាពនីមួយៗ | អគ្គាធិការដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២. អភិវឌ្ឍធនធានមនុស្ស និងនវានុវត្តមុខងាររបស់ស្ថាប័ន និងអង្គភាពចំណុះ | -សមិទ្ធិផលរបស់ក្រសួង ប្រធានបទថ្មីៗ ពាក់ព័ន្ធនឹងការវិវត្តន៍ថ្មីរបស់សង្គម និងជាសាកល បានដាក់បញ្ចូលក្នុងកិច្ចប្រជុំផ្ទៃក្នុងក្រសួង<br>-ចំនួនមន្ត្រីថ្នាក់ជាតិ ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ស្ថាប័នពាក់ព័ន្ធបានចូលរួមក្នុងកិច្ចប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី | រៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រសួង និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ដែលមានការដាក់បញ្ចូលនូវប្រធានបទថ្មីៗ ដែលមានបច្ចុប្បន្នភាពពាក់ព័ន្ធការវិវត្តថ្មីៗរបស់សង្គម | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីទទួលបន្ទុករដ្ឋបាល និងមន្ត្រីក្របខណ្ឌថ្មីទាំងថ្នាក់ជាតិ និងក្រោមជាតិ ត្រូវបានអភិវឌ្ឍសមត្ថភាពលើការងារ គ្រប់គ្រងរដ្ឋបាល | អភិវឌ្ឍន៍សមត្ថភាព និងជំនាញគ្រប់គ្រងរដ្ឋបាល ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល សហលក្ខន្តិកៈដោយឡែក ច្បាប់ លិខិតបទដ្ឋានគតិយុត្តិស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | -ក្រុមអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកិច្ចការនារី បានបង្កើន ក្រោមក្របខណ្ឌ ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ<br>-ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានមន្ត្រីរាជការ និងអង្គភាពចំណុះក្រសួងកិច្ចការនារី ដែលបានទទួលកម្មវិធីអភិវឌ្ឍសមត្ថភាពស្របតាមភារកិច្ចរបស់ខ្លួន<br>-ចំនួនវិធានការណ៍ និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ដែលស្ថិត | -រៀបចំបង្កើតអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់មន្ត្រីក្រសួងកិច្ចការនារី និងផ្ដល់ការអភិវឌ្ឍសមត្ថភាព ឱ្យស្របតាមមុខងាររបស់ស្ថាប័ន និងក្នុងនាមជាអ្នកជំនាញឯកទេស វិភាគ និងបញ្ញាបយេនឌ័រ<br>-សម្របសម្រួល និងគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រី និងក្រសួងកិច្ចការនារី<br>-រៀបចំ និងដំណើរការប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ និងអង្គភាពដែលទទួលបានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការអនុវត្តភារកិច្ចរបស់ខ្លួន | ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | នៅក្រោមការសម្របសម្រួលរបស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស | អភិវឌ្ឍសមត្ថភាពមន្ត្រីថ្មីនូវវគ្គជាកាតព្វកិច្ចសម្រាប់មន្ត្រីក្រសួងកិច្ចការនារី និងអភិវឌ្ឍភាពជាអ្នកដឹកនាំ ដល់ថ្នាក់ដឹកនាំកម្រិតគ្រប់គ្រង | | | | | | | | |
| | ចំនួនកម្មវិធីថ្មីៗ អនុវត្តដោយក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួងកិច្ចការនារី | បង្កើន និងដំណើរការក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់យុវជន ក្នុងការចូលរួមក្នុងស្ថាប័ន និងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ក្រុមបណ្ដាញមន្ត្រីយែនឌ័រ ក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣. ពង្រីកការអនុវត្តកម្មវិធីគុណភាពជីវិត គ្រួសារនិងការងារ និងបរិយាកាសមេត្រីភាពឆ្លើយតបនឹងយេនឌ័រនៅកន្លែងការងារ ក្នុងស្ថាប័ន និងអង្គភាពចំណុះ | ចំនួនទារក និងកុមារប្រចាំឆ្នាំដែលបានទទួលសេវាពីកម្មវិធីទារកដ្ឋាន<br><br>ចំនួនវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់គុណភាពជីវិត គ្រួសារនិងការងារនៅក្នុងស្ថាប័ន | អភិវឌ្ឍកម្មវិធីទារកដ្ឋាន ក្នុងការមើលថែទាំទារកនិងកុមារតូចៗ សម្រាប់ជួយសម្រាលបន្ទុកដល់មន្ត្រី ដើម្បីមានឱកាសនិងពេលវេលាក្នុងការបំពេញតួនាទីនិងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព | នាយកដ្ឋានរដ្ឋបាល បុគ្គលិក នាយកដ្ឋានស្ត្រីនិងការអប់រំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | បណ្តុះបណ្តាល និងដាក់វិធានការ ក្នុងការទប់ស្កាត់ផ្លូវភេទដែលមិនអាចទទួលយកបានដែលពាក់ព័ន្ធនឹងយេនឌ័រ ក្នុងស្ថាប័ន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | កម្មវិធីលើកទឹកចិត្ត និងភ្ជាប់ទំនាក់ទំនងជាមួយមន្ត្រីចូលនិវត្តន៍ | នាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រុមបណ្ដាញមន្ត្រីយែនឌ័រ អង្គភាពពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំនិងអនុវត្តវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់គុណភាពជីវិត គ្រួសារនិងការងារនៅក្នុងស្ថាប័ន | នាយកដ្ឋានរដ្ឋបាល បុគ្គលិក អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤.ពង្រឹងប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន និង | ប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន និងវាយតម្លៃផ្អែកលើលទ្ធ | រៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធផែនការអនុវត្ត ស្ថិតិ និងពិនិត្យតាម | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| វាយតម្លៃផ្អែកលើលទ្ធផលការងារ | ផលការងារត្រូវបានពង្រឹងប្រកបដោយគុណភាពនិងប្រសិទ្ធភាព | ដាននិងវាយតម្លៃ ផ្អែកលើលទ្ធផលដែលមានគុណភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | | | | | | | | |
| | | បង្កើត និងដំណើរការក្រុមការងារតាមដាន និងវាយ តម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ធាតុចូលការលើកកម្ពស់សមភាពយេនឌ័រ ត្រូវបានបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កម្មវិធី និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | រៀបចំធាតុចូល និងសមិទ្ធផលទាក់ទងការលើកកម្ពស់សមភាពយេនឌ័រនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( NSDP 2019-2023 ) ផែនការសកម្មភាព គោលនយោបាយប្រជាជន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលទាក់ទងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | សមត្ថភាពមន្ត្រីកិច្ចការនារីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ ស្ថិតិ តាមដានត្រួតពិនិត្យ និងវាយតម្លៃនិងផ្តល់អនុសាសន៍ ក្នុងគោលនយោបាយ ផែនការ កម្មវិធីឆ្លើយតបយេនឌ័រមានការកើនឡើង | ពង្រឹងសមត្ថភាពមន្ត្រីកិច្ចការនារី ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីការរៀបចំផែនការ ស្ថិតិ និងការត្រួតពិនិត្យនិងវាយតម្លៃឆ្លើយតបយេនឌ័រ (រួមទាំងការប្រមូល វិភាគ ចងក្រង ផលិតផ្សព្វផ្សាយ និងការតាក់តែងគោលនយោបាយ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ស្ថិតិយេនឌ័រសំខាន់ៗ ត្រូវបានប្រមូល ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ | ធ្វើបច្ចុប្បន្នភាពខិតប័ណ្ណ និងសៀវភៅស្ថិតិយេនឌ័រសំខាន់ៗនៅកម្ពុជា និងផ្សព្វផ្សាយ | ក្រសួង/មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ការអង្កេតនានាឆ្លើយតបនឹងយេនឌ័រ | សិក្សា និងចងក្រងនូវអង្កេតជាតិនានាដែលឆ្លើយតបនឹងយេនឌ័រ<br>បញ្ចូលទស្សនៈយេនឌ័រទៅក្នុងកម្រងសំណួរនៃការអង្កេតនានា | ក្រសួងកិច្ចការនារី<br>ក្រសួងផែនការ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនឯកសារនិងការសិក្សាស្រាវជ្រាវថ្មីៗដែលអាចបម្រើដល់មហាជនក្នុងមណ្ឌលព័ត៌មាននិងបណ្ណាល័យនានាដែលជាជំនួយរបស់ក្រសួង | ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងចែករំលែកព័ត៌មាន ការសិក្សាពាក់ព័ន្ធនឹងយេនឌ័រនិងស្ថានភាពស្ត្រីក្នុងមណ្ឌលព័ត៌មានក្រសួងកិច្ចការនារីនិងភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវនិងគ្រឹះស្ថានសិក្សានានា | ក្រសួងកិច្ចការនារី<br>វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានសិក្សាអប់រំ ពីដៃគូនានា | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥. ពង្រឹងយន្តការសម្របសម្រួល ប្រាស្រ័យទាក់ទង និងគ្រប់គ្រងព័ត៌មាន ផ្សព្វផ្សាយតាមប្រព័ន្ធទំនើប និងស្របតាមបរិបទសង្គម | ចំនួនប្រព័ន្ធផ្ទៃក្នុង ក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានរបស់ក្រសួងកិច្ចការនារី បានរៀបចំ និងកំពុងដំណើរការ | អភិវឌ្ឍ និងដំណើរការប្រព័ន្ធផ្ទៃក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបរបស់ក្រសួងកិច្ចការនារីនៅថ្នាក់ជាតិ និងក្រោមជាតិ | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានរដ្ឋបាល បុគ្គលិក<br>នាយកដ្ឋានផែនការនិងស្ថិតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនសមាជិកទំព័របណ្តាញសង្គមក្រសួងកិច្ចការនារី មានកើនឡើង | -ពង្រឹងសមត្ថភាព និងដំណើរការក្រុមការងារអន្តរនាយកដ្ឋានការងារគ្រប់គ្រងបណ្តាញសង្គមក្រសួងកិច្ចការនារី<br>-ពង្រឹងគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ក្រសួងកិច្ចការនារី ជាពិសេសតាមរយៈប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងមធ្យោបាយទំនើប | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានរដ្ឋបាល បុគ្គលិក<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្តាញសង្គម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | -ចំនួនសម្ភារៈ និងកម្មវិធីផ្សព្វផ្សាយ ដោយផ្អែកលើគោលនយោបាយជាតិ ស្ដីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | ផលិតព័ត៌មាន និងសម្ភារៈផ្សព្វផ្សាយ ដោយផ្អែកលើគោលនយោបាយជាតិ ស្ដីពីសមភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ តាមប្រព័ន្ធបច្ចេកវិទ្យា និងមធ្យោបាយ ដែលឆ្លើយតបតម្រូវការសង្គម | នាយកដ្ឋានព័ត៌មាន<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្ដាញសង្គម<br>ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | -ចំនួនព្រឹត្តិការណ៍ និងសកម្មភាពជួបពិភាក្សាជាមួយនឹងបណ្ដាញអ្នកសារព័ត៌មាន ក្នុងការពិភាក្សាលើការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ<br>-ចំនួនអ្នកចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពស្ដីពីយេនឌ័រជាមួយអ្នកសារព័ត៌មាន ដែលស្ថិតនៅក្រោមក្របខណ្ឌរបស់ក្រសួងកិច្ចការនារី | ពង្រឹងទំនាក់ទំនង និងអភិវឌ្ឍសមត្ថភាពដល់បណ្ដាញសារព័ត៌មាន និងគ្រឹះស្ថានបណ្ដុះបណ្ដាលអ្នកផ្សព្វផ្សាយ និងព័ត៌មានក្នុងការលើកកម្ពស់សមភាពយេនឌ័រ | នាយកដ្ឋានព័ត៌មាន<br>ក្រុមអន្តរនាយកដ្ឋានការងារបណ្ដាញសង្គម<br>ក្លឹបអ្នកសារសែត<br>ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានរកឃើញក្នុងសារព័ត៌មាន ដោយក្រុមការងារក្រសួងកិច្ចការនារី និងចំនួនដែលបានឆ្លើយតបទាន់ពេលវេលា | តាមដានព័ត៌មានប្រចាំ តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាពលើករណីអំពើហិង្សាលើស្ត្រីនិងក្មេងស្រីដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គមនិងតម្លៃស្ត្រី និងលើកកម្ពស់ការអនុវត្តក្រមប្រតិបត្តិរាយការណ៍ករណីអំពើហិង្សាលើស្ត្រី និងឆ្លើយតបឱ្យបានសមស្របទាន់ពេលវេលា | នាយកដ្ឋានព័ត៌មាន<br>នាយកដ្ឋានការពារផ្លូវច្បាប់<br>គណៈកម្មការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ<br>ក្រសួងព័ត៌មាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. ពង្រឹងយន្តការក្នុងការពង្រីកកិច្ចសហប្រតិបត្តិការ | ចំណេះដឹងរបស់មន្ត្រីរាជការកិច្ចការនារីស្ដីពីការទំនាក់ទំនង | ពង្រឹងសមត្ថភាពមន្ត្រីកិច្ចការនារី ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ដីពីការងារ | ក្រសួង មន្ទីរកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ជាតិ ថ្នាក់តំបន់និងសកលនិងភាពជាដៃគូរជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់និងកិច្ចការពារសិទ្ធិស្ត្រីនិងកុមារ។ | អន្តរជាតិកើនឡើង | ស្ត្រីនិងអាស៊ាន និងសារៈសំខាន់ នៃការធ្វើលិខិតគាំទ្រ ដើម្បីចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍ | | | | | | | | |
| | | អភិវឌ្ឍសមត្ថភាពស្តីពីទំនាក់ទំនងអន្តរជាតិ និងខ្លឹមសារលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិសំខាន់ៗ | ក្រសួង មន្ទីរកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | អនុស្សរណៈនៃការយល់ឃោគគ្នារវាងក្រសួងកិច្ចការនារី ជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងដៃគូពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព ក្រោមក្របខណ្ឌនារីរតនៈទី៥ | សម្របសម្រួល ក្នុងការរៀបចំឯកសារស្នើសុំចុះអនុស្សរណៈរបស់អង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងវិស័យឯកជនជាមួយក្រសួងកិច្ចការនារី | ក្រសួង មន្ទីរកិច្ចការនារី អង្គការពាក់ព័ន្ធ វិស័យឯកជន | √ | √ | √ | √ | √ | √ | √ |
| | | ចុះតាមដាន និងវាយតម្លៃលើការអនុវត្តអនុស្សរណៈ ដែលបានចុះកិច្ចព្រមព្រៀងរវាងក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ | ក្រសួង មន្ទីរកិច្ចការនារី អង្គការពាក់ព័ន្ធ វិស័យឯកជន | √ | √ | √ | √ | √ | √ | √ |
| | កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់និងសកល ក្នុងការលើកកម្ពស់ស្ថានភាព និងការពារសិទ្ធិស្ត្រីនិងកុមារមានភាពប្រសើរជាលំដាប់។ | រៀបចំ និងចូលរួមអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី ( ACW ) និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ ( ACWC ) | ក្រសួងកិច្ចការនារី ប្រទេសក្នុងតំបន់ និងសកល | √ | √ | √ | √ | √ | √ | √ |
| | | ពង្រឹងកិច្ចសហការរបស់នាយកដ្ឋានជំនាញក្នុងការផ្តល់ធាតុចូលលើឯកសារអន្តរជាតិពាក់ព័ន្ធកិច្ចការនារី | អន្តរនាយកដ្ឋាន | √ | √ | √ | √ | √ | √ | √ |
| | | ពង្រឹងកិច្ចសហការរៀបចំរបាយការណ៍ជាតិពាក់ព័ន្ធកិច្ចការនារី និងសមភាពយេនឌ័រ ស្របតាមកាតព្វកិច្ច | អន្តរនាយកដ្ឋាន | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | របស់ផ្ទៃនិងចែករំលែកក្នុងព្រឹត្តិការណ៍និងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធ | | | | | | | | |
| ៧. ពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័នក្នុងការឆ្លើយតបប្រកបដោយបរិយាបន្ន ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ | -ក្រុមការងារទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រីនិងក្មេងស្រីប្រកបដោយបរិយាបន្ន បានបង្កើត និងប្រជុំជាទៀតទាត់<br>-ក្របខណ្ឌយុទ្ធសាស្ត្រ និងឧបករណ៍ ក្នុងការឆ្លើយតបបញ្ហាបរិយាប័ន្នរបស់ក្រុមស្ត្រីនិងក្មេងស្រីងាយរងគ្រោះ នៅតាមអង្គភាព និងនាយកដ្ឋានក្រសួងកិច្ចការនារី | -បង្កើត និងដំណើរការក្រុមការងារទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រី និងក្មេងស្រីប្រកបដោយបរិយាបន្ន<br>-រៀបចំ និងជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្ររបស់ក្រុមការងារ និងឧបករណ៍ឆ្លើយតបប្រកបដោយបរិយាប័ន្ននៅតាមអង្គភាព និងនាយកដ្ឋានក្រសួងកិច្ចការនារី | ក្រុមការងារ ទទួលបន្ទុកឆ្លើយតបក្រុមងាយរងគ្រោះជាស្ត្រីនិងក្មេងស្រីប្រកបដោយបរិយាបន្ន | √ | √ | √ | √ | √ | √ | √ |
| | ចំនួនកើនឡើងនៃមន្ត្រីពិការជាស្ត្រី ដែលមានពិការភាព | ជំរុញការអនុវត្តគោលការណ៍នានាក្នុងការជ្រើសរើសនិងគាំទ្រដល់ការជ្រើសរើសមន្ត្រីដែលមានពិការភាព | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | ចំនួនវិធានការដាក់លាក់ដែលឆ្លើយតបការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពពាក់ព័ន្ធយេនឌ័ររបស់ក្រសួងកិច្ចការនារី | រៀបចំ និងដំណើរការយន្តការ និងឧបករណ៍ ក្នុងការបញ្ចូលបញ្ហាពិការភាពទៅក្នុងការងាររបស់អង្គភាព និងនាយកដ្ឋានជំនាញ | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |
| | ចំនួនកម្មវិធីអភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ និងបញ្ហាពិការដល់មន្ត្រីក្រសួងកិច្ចការនារី និងដៃគូ ក្នុងលទ្ធភាពដើម្បីឈានទៅអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រនិង | អភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ និងបញ្ហាពិការ ដល់មន្ត្រីក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ ក្នុងលទ្ធភាពដើម្បីឈានទៅអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រក្នុងពិការភាពនិងភាពអង់អាចរបស់ស្ត្រី និង | ក្រុមការងារសកម្មភាពជនពិការ ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីមានភាពពិការ | ក្មេងស្រីមានភាពពិការ | | | | | | | | |
| ៨. អនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់ស្ថាប័ន | មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ ត្រូវបានតម្លើងថ្នាក់និងឋានន្តរស័ក្តិ | រៀបចំវាយតម្លៃ និងដាក់ឱ្យមន្ត្រីឡើងឋានន្តរស័ក្តិ ថ្នាក់តាមវេន អតីតភាពការងារ កម្រិតសញ្ញាបត្រ និងគ្រឿងឥស្សរិយយស | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសដាក់ឱ្យចូលនិវត្តន៍ | រៀបចំលិខិតបញ្ជាក់អតីតភាពប្រវត្តិការងារ និងប្រកាសដាក់ឱ្យមន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ ចូលនិវត្តន៍ទៅតាមអតីតភាពការងារដែលត្រូវចូលនិវត្តន៍ និងតាមការស្ម័គ្រចិត្ត | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | មន្ត្រីថ្មីត្រូវបានចូលបំរើការងារក្នុងក្របខណ្ឌក្រសួងកិច្ចការនារី | រៀបចំផែនការជ្រើសរើសមន្ត្រី និងដំណើរការជ្រើសរើសនិស្សិត មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីរាជការឱ្យចូលបំរើការងារក្របខណ្ឌក្រសួងកិច្ចការនារី | នាយកដ្ឋានរដ្ឋបាល បុគ្គលិក | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីនិងប្រភេទមុខងាររបស់ក្រសួងកិច្ចការនារី ដែលបានផ្ទេរនិងអនុវត្ត ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រសិទ្ធភាព ក្រោមក្របខណ្ឌការងាររបស់កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ | រៀបចំគោលការណ៍ និងអនុវត្តផែនការ គាំទ្រដល់ការផ្ទេរមុខងាររបស់ក្រសួងកិច្ចការនារី ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមក្របខណ្ឌការងារវិមជ្ឈការនិងវិសហមជ្ឈការ | អន្តរនាយកដ្ឋាន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ផែនការសកម្មភាពរួមដំណាក់កាលទី៣ និងទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | កិច្ចប្រជុំសម្របសម្រួលរៀបចំជាមួយក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្ម | ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងកិច្ចការនារី អង្គភាពថវិកា នៃក្រសួងកិច្ច | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ | ភាពរួមផ្សំណាក់កាលទី៣ និងទី៤ | ការនារី | | | | | | | |
| | ចំនួនមន្ត្រីដែលមានសមត្ថភាពរៀបចំថវិកាឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រនារីរតនៈ | សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្រសួងកិច្ចការនារី ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកា ស្របតាមគោលនយោបាយ និងឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនមន្ត្រីដែលមានចំណេះដឹង និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានល្អ | ចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធព័ត៌មានវិទ្យា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) | នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់<br>អង្គភាពលទ្ធកម្ម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

# ផ្នែកទី៦

## ធនធានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ពឹងផ្អែកលើធនធានពីរសំខាន់ៗ គឺថវិការដ្ឋ និងការចូលរួមចំណែកពីដៃគូពាក់ព័ន្ធ ។

តម្លៃប៉ាន់ស្មានតម្រូវការជាក់ស្តែង ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ នឹងមានកំណត់នៅក្នុងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី ។ ដោយការងារលើកកម្ពស់សមភាពយេនឌ័រ គឺជារបៀបវារៈអន្តរវិស័យរបស់រាជរដ្ឋាភិបាល ការប៉ាន់ប្រមាណតម្រូវការធនធានសរុប សម្រាប់អនុវត្តន៍ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ មិនបានរាប់បញ្ចូលនូវថវិកាដែលឆ្លើយតបយេនឌ័រតាមវិស័យពាក់ព័ន្ធ។

ការប៉ាន់ស្មាននេះបានធ្វើឡើង តាមវិស័យនិងកម្មវិធីជាយុទ្ធសាស្ត្រនីមួយៗ ដូចខាងក្រោម៖

| ក្របខណ្ឌយុទ្ធសាស្ត្រនីមួយៗ | ប្រភពមូលនិធិ[3] |
| --- | --- |
| **ការបញ្ជ្រាបយេនឌ័រ** | ថវិកាជាតិ, UNDP, UNW, Sida, JICA, DFAT, UNFPA និងដៃគូផ្សេងទៀត |
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | ថវិកាជាតិ រួមជាមួយ, UNDP, JICA, UN-ESCAP, Oxfam, WEDU, APHEDA និងដៃគូផ្សេងទៀត |
| ការអប់រំស្ត្រីនិងក្មេងស្រី | ថវិកាជាតិ រួមជាមួយ UNICEF, UNSCO, ACTION AID, SAVE THE CHILDREN, World Bank, PLAN INTERNATIONAL, UNDP និងដៃគូផ្សេងទៀត |
| ការលើកកម្ពស់សុខភាពសម្រាប់ស្ត្រីនិងកុមារី | ថវិកាជាតិ រួមជាមួយ Fred Hollow Foundation, Global Fund, UNFPA, UN Women និងដៃគូផ្សេងទៀត |
| កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី | ថវិកាជាតិ រួមជាមួយ UN Women, UNFPA, UNICEF DFAT, Care International និងដៃគូផ្សេងទៀត |
| ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច | ថវិកាជាតិ រួមជាមួយនឹង UNDP, UNFPA, Oxfam, SIDA, UN Women និងដៃគូផ្សេងទៀត |
| ការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ | ថវិការដ្ឋ រួមជាមួយនឹង ADB, EU, SIDA, UNDP, GEF, UN Women, FAO និងដៃគូផ្សេងទៀត |
| ការពង្រឹងស្ថាប័ននិងសមត្ថភាព | ថវិកាជាតិ រួមជាមួយដៃគូអភិវឌ្ឍ ទាំងអស់ដែលគាំទ្រដល់ក្រសួងកិច្ចការនារី ជាពិសេស UNDP, SIDA, UNFPA, UN Women, JICA, GIZ |

[3] នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ក្រុមការងាររៀបចំបានទទួលព័ត៌មានអំពីប្រភពធនធានដែលមានសក្តានុពល តាមវិស័យ និងកម្មវិធីនីមួយៗ ។ ក្រសួងកិច្ចការនារី នឹងបន្តស្វែងរកការគាំទ្រពីប្រភពផ្សេងទៀត នៅក្នុងពេលដំណើរការអនុវត្ត ។

# ផ្នែកទី៧

# ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

## ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ

ដោយផ្អែកលើផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** ក្នុងការចូលរួម និងសម្របសម្រួលក្នុងការអនុវត្ត **គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ** ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ នឹងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដោយស្របតាមអណត្តិ និងភារកិច្ចដែលកំណត់ដោយច្បាប់។ កិច្ចការនេះនឹងដំណើរការតាមរយៈភាពជាដៃគូ ក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសយេនឌ័រ និងដៃគូពាក់ព័ន្ធ ដោយមាននាយកដ្ឋានផែនការនិងស្ថិតិ ក្រសួងកិច្ចការនារីជាសេនាធិការ ។ ការរៀបចំនិងពិនិត្យឡើងវិញនូវផែនការសកម្មភាពប្រចាំឆ្នាំ ធ្វើឡើងនៅអំឡុងចុងនិងដើមឆ្នាំនីមួយៗ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ជាមួយគោលនយោបាយ និងកម្មវិធីនានា និងស្របតាមស្ថានភាពជាក់ស្តែង។ ម្យ៉ាងវិញទៀត ក្រសួងកិច្ចការនារី នឹងដើរតួជាអ្នកសម្របសម្រួលក្នុងដំណើរការនេះ តាមរយៈការរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ និងលើកផែនការបន្ត ។

## ការត្រួតពិនិត្យ និងតាមដាន

ដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងធ្វើការត្រួតពិនិត្យឡើងវិញនូវការរីកចម្រើន ក្នុងរយៈពេលខ្លី និងមធ្យម។

ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ នឹងសម្របសម្រួល ក្នុងការរៀបចំរបាយការណ៍រីកចម្រើនលើការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រជាប្រចាំ ដើម្បីចែករំលែកដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍។ ដូចនេះ ការត្រួតពិនិត្យ និងតាមដាននូវការរីកចម្រើនលើការអនុវត្តយុទ្ធសាស្ត្រ**នារីរតនៈទី៥** ក៏ត្រូវផ្សារភ្ជាប់នៅក្នុងរបាយការណ៍ទាំងនោះផងដែរ ។

## ការវាយតម្លៃ

ដើម្បីពិនិត្យលើប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ក្រសួងកិច្ចការនារីនិងដៃគូពាក់ព័ន្ធនឹងរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងសន្និបាតជាតិបូកសរុបលទ្ធផលការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥**។ រាល់ដៃគូពាក់ព័ន្ធនឹងចូលរួមយ៉ាងទូលំទូលាយក្នុងការវាយតម្លៃលទ្ធផលការងារទាំងនេះ និងលើកទិសដៅបន្ត។

សន្និបាតជាតិបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** និងរៀបចំឡើងនៅពេលបញ្ចប់អាណត្តិនៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៥** តាមរយៈការចូលរួមពីភ្នាក់ងារអនុវត្ត និងដៃគូពាក់ព័ន្ធ ដើម្បីបូកសរុបអំពីលទ្ធផលដែលបានអនុវត្ត និងជាមួយនូវផលប៉ះពាល់ជាវិជ្ជមាននៃផែនការយុទ្ធសាស្ត្រនេះ។ ចំណុចសំខាន់ដែលអាចផ្ទៀងផ្ទាត់អំពីលទ្ធផលនៃការសម្រេចនេះ តាមរយៈការធ្វើបច្ចុប្បន្នកម្មនៃការ ប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា និងពិនិត្យលើការសម្រេចនូវចំណុចដៅ នៃសូចនាករសំខាន់ៗដែលពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។

*ក្រសួងកិច្ចការនារី* នឹងបង្កើតក្រុមការងារតាមដាននិងវាយតម្លៃ និងរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃនៃ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** ដែលមានគូសបញ្ជាក់អំពីតួនាទីរបស់ក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ នៅក្នុងន័យនេះ តាមការរៀបចំនិងដាក់ឱ្យដំណើរការក្របខណ្ឌតាមដាន និងវាយតម្លៃ គឺជាអភិក្រមនិងកិច្ចការចាំបាច់មួយរបស់**នារីរតនៈទី៥** ក្នុងការពង្រឹងស្ថាប័នរបស់ក្រសួងកិច្ចការនារី ក្នុងការរៀបចំប្រព័ន្ធ និងដំណើរការប្រព័ន្ធតាមដាន និងវាយតម្លៃ ជាពិសេសលើការគ្រប់គ្រងការងារ ដែលផ្អែកតាមលទ្ធផល។ ការសិក្សា និងរៀបចំឱ្យទិន្នន័យមូលដ្ឋាន និងការកំណត់ចំណុចដៅជាក់លាក់សម្រាប់សូចនាករ ដែលមាននៅក្នុងតារាងផែនការសកម្មភាព៥ឆ្នាំ (២០១៩-២០២៣) របស់ក្រសួងកិច្ចការនារី ក៏ត្រូវគិតគូរនិងដាក់បញ្ចូលក្នុងក្របខណ្ឌ។ ក្នុងករណីចាំបាច់ សូចនាករនៅក្នុងតារាងសកម្មភាពនេះ ក៏អាចនឹងកែសម្រួល ឬកំណត់ថ្មី តាមលទ្ធភាពសមស្រប ។

ជាមួយគ្នានេះ ដើម្បីឱ្យស៊ីចង្វាក់គ្នាជាមួយនឹងការចង្អុលបង្ហាញ ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ដែលនឹងអនុម័តនាពេលខាងមុខនេះ ក្រសួងកិច្ចការនារី ត្រូវសហការជាមួយនឹងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងការរៀបចំនិងអនុវត្តការងារតាមដាន និងវាយតម្លៃរបស់គោលនយោបាយជាតិ និងចូលរួមជាមួយក្រសួង-ស្ថាប័ន ក្នុងការពង្រឹងសមត្ថភាព និងប្រព័ន្ធតាមដានតាមវិស័យ ឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ព្រមទាំងសូចនាករជាតិ និងតាមវិស័យសំខាន់ៗ។

ការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥** នឹងចូលរួមក្នុងសម្រេចតាមសូចនាករជាតិ សំខាន់ៗ ក៏ដូចមានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងសូចនាករ តាមវិស័យសំខាន់ៗ ដូចខាងក្រោម៖

## សូចនាករតាមដានត្រួតពិនិត្យសំខាន់ៗ ២០១៩-២០២៣

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **ការបញ្ជ្រាបយេនឌ័រ** | | | | | | | | | |
| ១. | គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័ត ដោយរាជរដ្ឋាភិបាល | ចំនួន | ០ | | ១ | | | | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ២. | ចំនួនច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្តសម្រាប់លើកកម្ពស់ការអនុវត្ត និងតាមដានត្រួតពិនិត្យការលើកកម្ពស់សមភាពយេនឌ័រ និងការមិនរើសអើងភេទ | ចំនួន | ៥០ | | | | | ៥៥ | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| ៣. | ឯកសារប៉ាន់ប្រមាណយេនឌ័រតាមវិស័យបានរៀបចំ និងផ្សព្វផ្សាយ | ចំនួន | ៣ | | ៤ | | | | ក្រសួងកិច្ចការនារី |
| ៤. | ក្រសួង-ស្ថាប័នដែលមានប្រព័ន្ធតាមដាននិងវិភាជន៍ថវិកាសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ចំនួន | ០ | ៣ | ៤ | ៤ | ៥ | ៥ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៥. | ក្រសួង-ស្ថាប័នដែលបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ | ចំនួន | ៨ | ៨ | ៩ | ១០ | ១១ | ១២ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៦. | កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលមានកំណត់សមាសភាព និងសូចនាករជាក់លាក់ដែលឆ្លើយតបនឹងយេនឌ័រ | ចំនួន | ០ | | ១ | | | | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| ៧. | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់សមាសភាព និងសូចនាករជាក់លាក់ដែលឆ្លើយតបយេនឌ័រ | ចំនួន | ១ | ១ | | ២ | | | គ.ជ.អ.ប |
| ៨. | ចំនួនសវនកម្មយេនឌ័រ តាមវិស័យ | ចំនួន | ២ | ៣ | ៤ | ៥ | ៦ | ៧ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **ការបង្កើនភាពអត់ធន់ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី** | | | | | | | | | |
| ១. | អត្រាស្ត្រីដែលមានការងារធ្វើ អាយុពី១៥-៦៤ឆ្នាំ | ភាគរយ | ៧៩,៩ (២០១៧) | ៨២,០ | ៨៤,០ | ៨៥,០ | ៨៧,០ | ៩០ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| ២. | ចំណែករបស់ស្ត្រី ចូលរួមក្នុងការងារមានប្រាក់កម្រៃ អាយុពី១៥-៦៤ឆ្នាំ | | | | | | | | អង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| | *កសិកម្ម* | ភាគរយ | ៣៥,០ (២០១៧) | ៣៧,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | |
| | *ឧស្សាហកម្ម* | ភាគរយ | ២៧,៣ (២០១៧) | ៣៩,០ | ៣០,០ | ៣១,០ | ៣៣,០ | ៣៥,០ | |
| | *សេវាកម្ម* | ភាគរយ | ៣៧,៦ (២០១៧) | ៣៨,០ | ៣៩,០ | ៤១,០ | ៤៣,០ | ៤៥,០ | |
| ៣. | ចំនួនវិធានការផ្លូវច្បាប់ និងគោលនយោបាយដែល ដោះស្រាយ និងទទួលស្គាល់នូវគុណភាពជីវិត និងការងារ (ការផ្ទះ និងការថែទាំដែលមិនមានកម្រៃ) និងលើកកម្ពស់ការទទួលបាន កាន់តែច្រើននូវការងារសមរម្យសម្រាប់ស្ត្រី | ចំនួន | ៥ (២០១៦) | | | | | ៩ | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| ៤. | កម្មវិធីស្តីពីការអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រី បានដាក់តែង និងទទួលបានថវិកាជាតិនិងធនធានពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្ត | ចំនួន | ០ | | | ១ | | | ក្រសួងកិច្ចការនារី |
| ៥. | បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជាត្រូវបានបង្កើត និងដំណើរការ | ចំនួន | ០ | | ១ | | | | ក្រសួងកិច្ចការនារី |
| ៦. | មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលបានធ្វើពិពិធកម្មមុខងារ ត្រូវបានធ្វើឱ្យប្រសើរឡើង | ចំនួន | ៥ | ៥ | ៦ | ៧ | ៧ | ៧ | ក្រសួងកិច្ចការនារី |
| ៧. | លទ្ធភាពទទួលសេវាកម្មហិរញ្ញវត្ថុផ្លូវការរបស់ស្ត្រី | ភាគរយ | ៦០ | | | | | ៦៥ | ធនាគារជាតិ |

| | សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | កើនឡើង | | | | | | | | នៃកម្ពុជា |
| **ការអប់រំរបស់ស្ត្រី និងក្មេងស្រី** | | | | | | | | | |
| ១. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ភាគរយ | ៤២,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ | |
| | *ស្រី* | | ៥១,១ | ៥២,៥ | ៥៣,៣ | ៥៤,៣ | ៥៥,៣ | ៥៦,៣ | |
| ២. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | ភាគរយ | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | ភាគរយ | ១៣,៣ | ១៤,៣ | ១៥,៥ | ១៦,៦ | ១៧,៨ | ១៨,៩ | |
| | *ស្រី* | ភាគរយ | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ | |
| ៣. | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះ បណ្ដាលផ្នែកស្ទែម | ភាគរយ | ២៧,១ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | ៣២,០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ប្រុស* | | ៣៦,៧ | ៣៧,១ | ៣៧,៥ | ៣៧,៨ | ៣៨,២ | ៣៨,៦ | |
| | *ស្រី* | | ១៧,៤ | ១៨,៤ | ១៩,៤ | ២០,៥ | ២១,៥ | ២២,៥ | |
| ៤. | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ចំនួន | ១ ៤៧១ | ១ ៧៧៧ | ២ ០៨៣ | ២ ៣៨៨ | ២ ៦៩៤ | ៣ ០០០ | ក្រសួងអប់រំ យុវជន និងកីឡា |
| | *ចំនួនសិស្សស្រី* | ចំនួន | ៥២៦ | ៥៤៥ | ៥៦៤ | ៥៨៣ | ៦០២ | ៦២១ | |
| **សុខភាពស្ត្រី និងក្មេងស្រី** | | | | | | | | | |
| ១. | អត្រាមរណភាពមាតា ក្នុង១០០ពាន់ទារកកើតរស់ | ក្នុងទារកកើតរស់ ១០០ ពាន់នាក់ | ១៧០ | | ១៣០ | | | ១០០ (គោលដៅឆ្នាំ២០២៥) | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ២. | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩ឆ្នាំ) | ភាគរយ | | | ៦២ | | | ៦៥ | ផែនការយុទ្ធសាស្ត្រ |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្ត នឹង មធ្យោបាយពន្យារកំណើតទំនើប | | | | | | | (គោលដៅឆ្នាំ២០២៥) | អភិវឌ្ឍន៍ជាតិ |
| ៣. | ស្ត្រីវ័យជំទង់អាយុ ១៥-១៩ ឆ្នាំមានគភ៌ | ភាគរយ | | | ៨ | | | | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ៤. | ស្ត្រី អាយុពី៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិច១លើក | ភាគរយ | | ៤ | ៦ | ៨ | ១០ | ១២ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ៥. | ច្បាប់ គោលនយោបាយ ផែនការនិងលិខិតបទដ្ឋាន គតិយុត្តដែលធានាឱ្យស្ត្រីគ្រប់រូប មានលទ្ធភាពទទួលបានព័ត៌មានការអប់រំនិងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ | ចំនួន | ១០ (២០១៦) | | | | ១៥ | | គោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព |
| **កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី**<br>**(សូចនាករផ្សេង-ទៀត មានកំណត់នៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ដែលនឹងអនុម័តដោយរាជរដ្ឋាភិបាល)** | | | | | | | | | |
| ១. | ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានធ្វើបច្ចុប្បន្នភាព និងអនុម័ត | ចំនួន | ២ | | ៣ | | | | ក្រសួងកិច្ចការនារី |
| ២. | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី មានអាយុ១៥ឆ្នាំឡើងដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវចិត្ត ឬអតីត ក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមទម្រង់នៃអំពើហិង្សានិងតាមអាយុ | ភាគរយ | ៣០,០ (២០១៦) | | | | | ២៨,០ | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| ៣. | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវភេទ ពីអ្នកមិនមែនជាដៃគូក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមភេទ | ភាគរយ | ០,១ (២០១៦) | | | ០,០៨ | | | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |

| សូចនាករជាតិ និងតាមវិស័យគន្លឹះៗ | | ឯកតា | ស្ថានភាព | ចំណុចដៅ | | | | | ប្រភពទិន្នន័យ និងព័ត៌មាន |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៤. | សមាមាត្ររបស់ស្ត្រី អាយុពី២០-២៤ឆ្នាំ ដែលរៀបការ ឬរស់នៅជាមួយគ្នាមុន អាយុ១៨ឆ្នាំ | ភាគរយ | ១,៩ (២០១៦) | | | | | ១,៧ | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| ៥. | ចំនួនមណ្ឌលសេវាចម្រុះសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ ដើម្បីសម្រួលការផ្តល់សេវា ផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាសុខភាព និងសេវាផ្សេងៗ ជូនជនរងគ្រោះ | ចំនួន | ០ | ១ | ២ | ៣ | ៤ | ៥ | ក្រសួងកិច្ចការនារី |
| **ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ** | | | | | | | | | |
| ១. | ភាគរយអាសនៈរបស់ស្ត្រី ក្នុងស្ថាប័ននីតិប្បញ្ញត្តិ | | ២៥ | ២៥ | | | | ៣០ | ក្រសួងកិច្ចការនារី |
| ២. | សមាមាត្រស្ត្រីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | ភាគរយ | ២១ | ២១ | | | | ២៦ | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣. | ភាគរយស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ | ភាគរយ | ១៦,៧ | ១៦,៧ | | | | ២៥ | គ.ជ.ប |
| ៤. | ស្ត្រីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈ ថ្នាក់ជាតិ និងក្រោមជាតិ (អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងប្រធានមន្ទីរ) | ភាគរយ | ១៤ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ក្រសួងមុខងារសាធារណៈ |
| ៥. | ភាគរយស្ត្រីថ្នាក់ដឹកនាំនៅថ្នាក់ក្រុង ស្រុក ខណ្ឌកាន់មុខតំណែងគ្រប់គ្រង | | ២៥ | ២៧ | ២៨ | ២៩ | ៣០ | ៣២ | ក្រសួងមហាផ្ទៃ |
| ៦. | មន្ត្រីរាជការជាស្ត្រី ក្របខណ្ឌមុខងារសាធារណៈ | ភាគរយ | ៤១ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ | ក្រសួងមុខងារសាធារណៈ |

# សទ្ទានុក្រម

**សមភាពយេនឌ័រ** សំដៅដល់គោលការណ៍គ្មានការរើសអើងទៅលើភេទណាមួយ និងគោលដៅដើម្បីឱ្យបុរស-ស្ត្រី កូនប្រុស-កូនស្រី មានឱកាស តម្លៃ ធនធាននិងផលប្រយោជន៍ដូចៗគ្នា ដោយពិតប្រាកដនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម

**សមធម៌យេនឌ័រ** សំដៅដល់គោលការណ៍ យុទ្ធសាស្ត្រ មធ្យោបាយ ឬវិធានការវិជ្ជមានដែលបង្កលក្ខណៈ ឬផ្ដល់ឱកាសដល់បុគ្គល ឬក្រុមណាមួយនៃបុរស-ស្ត្រី ក្នុងការកាត់បន្ថយគម្លាត និងដើម្បីឈានទៅសម្រេចសមភាពយេនឌ័រ យ៉ាងពិតប្រាកដ

**វិសមភាពយេនឌ័រ** សំដៅដល់ផ្នត់គំនិត និងឥរិយាបថរើសអើងទៅលើភេទណាមួយ និងបញ្ហាឬគម្លាតរវាងបុរស-ស្ត្រី កូនប្រុស-កូនស្រី ដែលកើតមានក្នុងសង្គម សហគមន៍ ស្ថាប័ន និងគ្រួសារ

**ការបញ្ជ្រាបយេនឌ័រ** យុទ្ធសាស្ត្រ និងវិធានការឆ្លើយតបនឹងវិសមភាពយេនឌ័រ ក្នុងគោលនយោបាយ តាមវិស័យ កម្មវិធី លិខិតបទដ្ឋានគតិយុត្ត ស្ថាប័ននិងគ្រួសារ។ល។

**ការបង្កើនភាពអង់អាចដល់ស្ត្រី** សំដៅដល់វិធានការដើម្បីបង្កើនសមត្ថភាព អភិវឌ្ឍន៍សក្ដានុពល និងការការពារផលប្រយោជន៍ដល់ស្ត្រី

**បរិយាបន្ន** សំដៅដល់ការដាក់បញ្ចូល ការយកចិត្តទុកដាក់ និងឆ្លើយតបដល់គ្រប់ក្រុមគោលដៅ នៅក្នុងសង្គម ស្ថាប័ន និងគ្រួសារ ដោយសំដៅ «មិនឱ្យអ្នកណាម្នាក់នៅឯកោ» លើក្រុមគោលដៅដែលងាយរងគ្រោះ និងបាត់បង់ឱកាសនានានៅក្នុងសង្គម ដូចជាជនពិការ ក្រុមស្រឡាញ់ភេទដូចគ្នា (LGBTIQ) ជនជាតិដើមភាគតិច កុមារ ស្ត្រីជនចាស់ជរាជាដើម

**វិភាគបញ្ហាយេនឌ័រ** សំដៅដល់ការវិភាគឱ្យឃើញនូវឫសគល់ និងផលប៉ះពាល់នៃវិសមភាពយេនឌ័រ ដែលមានក្នុងសង្គម តាមវិស័យ និងអង្គភាព

**ផលប៉ះពាល់យេនឌ័រតាមវិស័យ** សំដៅដល់ប្រភេទ និងទំហំនៃផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតឡើងពីវិសមភាពយេនឌ័រលើសង្គម ស្ថាប័ន តាមវិស័យ និងនៅក្នុងគ្រួសារ

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** សំដៅដល់ការរំលោភបំពានទៅលើភេទណាមួយ ដែលគេគិតថាទន់ខ្សោយជាងខ្លួនហើយដែលនាំឱ្យមាន ឬក៏ទំនងជានាំឱ្យមានសេចក្តីអន្តរាយ លើរូបកាយផ្លូវភេទ ផ្លូវចិត្ត ឬខាងសេដ្ឋកិច្ច ដោយផ្អែកលើយេនឌ័រ នៃបុគ្គលណាមួយ។

**វិធានការតុល្យភាពជីវិត** សំដៅដល់វិធានការរបស់ស្ថាប័ន និងរដ្ឋ ក្នុងការគាំទ្រដល់បុគ្គលិក និងគ្រួសារ ក្នុងគោលដៅឱ្យមានតុល្យភាពនៃគុណភាពការងារ និងគុណភាពជីវិត ដែលក្នុងនោះមានដូចជាការគិតគូរនិងឆ្លើយតបការសម្រាកមាតុភាព និងបិតុភាព ការសម្រាកថែទាំគ្រួសារ ការរៀបចំកន្លែងថែទាំកុមារនៅកន្លែងធ្វើការ ការរៀបចំការងារដែលមានភាពបត់បែន។

**សវនកម្មយេនឌ័រ** ឧបករណ៍ និងវិធីសាស្ត្រ ក្នុងការពិនិត្យនិងប៉ាន់ប្រមាណ លើវឌ្ឍនភាព បញ្ហាប្រឈម គម្លាត កាលានុវត្តភាព និងអនុសាសន៍ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័ន ឬវិស័យណាមួយ តាមរយៈការប្រៀបធៀបរវាងការប្តេជ្ញាចិត្តនិងគោលនយោបាយរបស់ស្ថាប័ន ឬវិស័យ ជាមួយនឹងស្ថានភាពជាក់ស្តែង ។

**ការឆ្លើយតបយេនឌ័រ** សំដៅលើការយកចិត្តទុក ការគិតគូរ និងដោះស្រាយអំពីបញ្ហាវិសមភាពយេនឌ័រ នៅក្នុងគ្រប់ដំណាក់កាលនិងផ្នែកនៃដំណើរការ ឬកិច្ចការ ឬស្ថាប័នណាមួយ។ ឧទាហរណ៍ គោលនយោបាយ ដែលឆ្លើយតបយេនឌ័រសំដៅលើគោលនយោបាយ ដែលបានគិតគូរ និងដោះស្រាយបញ្ហាវិសមភាព យេនឌ័រនៅក្នុងដំណាក់កាលតាក់តែង តាមរយៈការវិភាគយេនឌ័រ និងមានវិធានការជាក់លាក់ក្នុងការឆ្លើយតបវិសមភាពយេនឌ័រ ក្នុងគោលនយោបាយនោះ។

## គំនូសបំព្រួញផែនការយុទ្ធសាស្ត្រនារីរតនៈទី៥

# ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣

ដើម្បីសម្រេចសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីគ្រប់រូបនៅកម្ពុជា

**ការបញ្រ្ជាបយេនឌ័រ**

ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

| យុទ្ធសាស្ត្រទី ១ | យុទ្ធសាស្ត្រទី ២ | យុទ្ធសាស្ត្រទី ៣ | យុទ្ធសាស្ត្រទី ៤ | យុទ្ធសាស្ត្រទី ៥ | យុទ្ធសាស្ត្រទី ៦ |
|---|---|---|---|---|---|
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ការលើកកម្ពស់ការអប់រំរបស់ស្ត្រីនិងក្មេងស្រី | ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី | ភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាធារណៈនិងនយោបាយ | ការបញ្រ្ជាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ |

**ការពង្រឹងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន**

ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ការធ្វើទំនើបកម្មស្ថាប័ន អភិវឌ្ឍន៍ធនធានមនុស្ស ប្រព័ន្ធតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងកិច្ចសហប្រតិបត្តិការ